**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# រដ្ឋបាលស្រុកបាទី និងសមិទ្ធផលសំខាន់ៗដែល ទទួលបានពីឆ្នាំ ២០១៧ រហូតដល់ ឆ្នាំ២០១៩

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **ក. ណាល់ លីនដា** | **លោក យូ តូនី** |
| **ក. អ៊ុំ ស្រីឡី** | |
| ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** | ឆ្នាំចូលរៀន ២០១៦ |
| ជំនាន់ទី១៣ | ឆ្នាំសរសេរសារណា ២០២០ |

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីររូបឈ្មោះ **ណាល់ លីនដា** និង **អ៊ុំ ស្រីឡី** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈ ជំនាន់ទី១៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិង វិទ្យាសាស្រ្តសេដ្ឋកិច្ច។

ជាដំបូងសូមធ្វើគារវកិច្ចសម្តែងនូវកតញ្ញូតាធម៌ចំពោះ លោកអ្នកមានគុណទាំងពីរដែលបានចិញ្ចឹមបីបាច់ ថែរក្សារូបកូនកន្លងមក និងចង់ឃើញកូនៗដើរក្នុងផ្លូវមួយដែលល្អសម្រាប់ខ្លួនឯងលោកទាំងពីរ និងសង្គមជាតិ។ លោកទាំងពីរបានលើកទឹកចិត្ត ទាំងផ្លូវកាយ និងផ្លូវចិត្ត ដោយមិនខ្លាចភាពនឿយហត់គ្រប់បែបយ៉ាងចំពោះកូន ថែមទាំងហ៊ានលះបង់អ្វីគ្រប់យ៉ាង ទាំងផ្នែកស្មារតី ធនធាន និងផ្នែកសម្ភារៈ ដើម្បីអោយកូនទទួលបានភាពជោគជ័យក្នុងជីវិត។ គុណលោកទាំងពីរពុំអាចយកអ្វីប្រៀបផ្ទឹមបានទេ យើងខ្ញុំទាំងពីរនាក់នឹងចងចាំជានិច្ចមិនអាចបំភ្លេចបាន ។

យើងខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងលោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានដឹកនាំសម្រួបសម្រួលបង្ហាត់បង្រៀន យ៉ាងយកចិត្តទុកដាក់ និងចំណាយពេលដ៏មានតម្លៃ តម្រង់ទិសនិងចែករំលែកនូវចំណេះដឹងជាច្រើន ថែមទាំងបទពិសោធន៍ថ្មីៗ សម្រាប់បំពេញចំណេះវិជ្ជាចាប់តាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់បញ្ចប់ការសិក្សា ។

សូមថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះសាស្ត្រាចារ្យណែនាំ **យូ តូនី** ដែលបានជួយពន្យល់ណែនាំក្នុងការសរសេរបញ្ចប់ការសិក្សាមួយនេះ ដោយបានចំណាយពេលវេលាដ៏មានតម្លៃ ទាំងកម្លាំងកាយ កម្លាំងចិត្ត និងផ្តល់ជាគំនិតយោបល់ត្រួសត្រាយផ្លូវ ដើម្បីលេចចេញនូវរូបរាងសារណាបញ្ចប់ការសិក្សានេះយ៉ាងល្អប្រសើរ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ លោកអភិបាល **ភួន ឈឹម** នៃគណៈអភិបាលស្រុកបាទី ព្រមទាំងសមាជិកទាំងអស់ ដែលបានចូលរួមសកម្មភាពជួយជ្រោមជ្រែង ស្មារតី គំនិត ដោយលោកបានចំណាយពេលដ៏មានតម្លៃនិងយកចិត្តទុកដាក់ក្នុងដំណើរការ ស្រាវជ្រាវព្រមទាំងផ្តល់នូវឯកសារដែលពាក់ព័ន្ធជួយកែនូវកុហុសឆ្គង ថែមទាំងជំរុញឲ្យយើងខិតខំបន្តនូវការស្រាវជ្រាវរហូតបានសម្រេច។

# អារម្ភកថា

បន្ទាប់ពីការសិក្សាថ្នាក់បរិញ្ញាប័ត្រអស់រយៈពេល បួនឆ្នាំកន្លងមកលើផ្នែករដ្ឋបាលសាធារណៈនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសេដ្ឋកិច្ច យើងខ្ញុំបានយល់ជ្រាបច្បាស់អំពី ការអភិវឌ្ឍសំខាន់ៗជាច្រើនតាមរយៈលោកគ្រូអ្នកគ្រូនិងសាស្រ្តចារ្យដែលបានខិតខំបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ផ្នែករដ្ឋបាលសាធារណៈ។

ដូចនេះដោយមានការចង់ហ្វឹកហាត់ ពីសមត្ថភាពរបស់ខ្លួនឯងបន្ថែមទៀតនោះដែរយើងខ្ញុំទាំងពីរនាក់ក៏បានសម្រេចចិត្តដើម្បីធ្វើការសិក្សាស្រាវជ្រាវធ្វើសារណាលើប្រធានបទស្តីអំពី « **រដ្ឋបាលស្រុកបាទី និងសមិទ្ធផលសំខាន់ៗដែលទទួលបានពីឆ្នាំ ២០១៧ ដល់ ឆ្នាំ ២០១៩** » ដើម្បីយកមករៀបចំជាអត្ថបទ និងជាការបញ្ជាក់អំពីសមត្ថភាពបញ្ជាក់ពីកំរិតនៃចំណេះដឹងផងដែរ។

មូលហេតុសំខាន់ ដែលនាំឲ្យយើងទាំងពីរនាក់ ជ្រើសរើសយកប្រធានបទ មួយនេះយកមក ធ្វើការបកស្រាយព្រោះយើងមានគោលបំណងនិង ចូលរួមចំណែកដ៏តូចមួយអាចជួយតម្រង់ទិសដល់និស្សិតជំនាន់ក្រោយឲ្យយល់ដឹងច្បាស់ពីសារៈសំខាន់ក្នុងការអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធ លើគ្រប់វិស័យនិងលើកកម្ពស់ប្រជាពលរដ្ឋក្នុងការបង្កើនផលកសិកម្មទទួលបានប្រាក់ចំណូលក្នុងគ្រួសារ រួមទាំងសេដ្ឋកិច្ចសង្គមជាតិទាំងមូលផងដែរ។ម្យ៉ាងវិញទៀតអោយស្របតាមយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល និងរបស់មន្ត្រីគ្រប់ជាន់ថ្នាក់នៅក្នុងស្រុកបាទី។ ទទឹមនឹងនេះដែរយើងខ្ញុំសង្ឃឹមថាសារណាបញ្ចប់ការសិក្សានេះមានអត្ថប្រយោជន៍សម្រាប់អ្នកអានអោយយល់ដឹងកាន់តែច្បាស់លើវិស័យរដ្ឋបាលសាធារណៈនិងការអភិវឌ្ឍន៍។

ជាចុងបញ្ចប់នេះ យើងខ្ញុំទាំងពីរនាក់ក៏សូមអភ័យទោសនូវចំណុចដែលខ្វះខាតណាមួយ ឬក៏កុហុសឆ្គងពាក្យពេចន៏ទាំងឡាយណាដែលមាននៅក្នុងការស្រាវជ្រាវនេះ

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ............ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ............ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ............ ២

៣. គោលបំណងនៃការស្រាវជ្រាវ ............ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ............ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ............ ២

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ............ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ ៣

**ជំពូកទី១**

**រចនាសម្ព័ន្ធនៃរដ្ឋបាលស្រុកបាទី**

**ផ្នែកទី១៖ ក្រុមប្រឹក្សាស្រុកបាទី** ............ ៤

**កថាខណ្ឌទី១៖ ក្រុមប្រឹក្សាស្រុក និងវិមជ្ឈការ** ............ ៤

ក. សមាសភាព និងលក្ខខណ្ឌនៃការជ្រើសរើសក្រុមប្រឹក្សាស្រុក ............ ៤

ខ. តួនាទី ភារកិច្ច និងសិទ្ធិអំណាចក្រុមប្រឹក្សាស្រុក ............ ៧

គ. វិមជ្ឈការនៃក្រុមប្រឹក្សាស្រុកបាទី ............ ៨

**កថាខណ្ឌទី២៖ គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា** ............ ១០

ក. គណៈកម្មាធិកាសម្របសម្រួលបច្ចេកទេស ............ ១១

ខ. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ............ ១៤

គ. គណៈកម្មាធិការលទ្ធកម្ម ............ ១៨

**ផ្នែកទី៣៖ គណៈអភិបាលស្រុកបាទី** ............ ២០

**កថាខណ្ឌទី១៖ គណៈអភិបាលស្រុក និងវិសហមជ្ឈការ** ............ ២០

ក. សមាសភាព លក្ខខណ្ឌនៃការជ្រើសតាំង និងការបញ្ចប់តួនាទី ............ ២០

ខ. តួនាទី ភារកិច្ចរបស់គណៈអភិបាលស្រុក ........ ២២

គ. វិសហមជ្ឈការនៃគណៈអភិបាលស្រុក ........ ២៣

**កថាខណ្ឌទី២៖ ទំនាក់ទំនងរវាងគណៈអភិបាលស្រុក និងក្រុមប្រឹក្សាស្រុក** ........ ២៥

ក. ទំនាក់ទំនងរវាងគណៈអភិបាលស្រុក និងក្រុមប្រឹក្សាស្រុក........ ២៥

ខ. ទំនាក់ទំនងរវាងគណៈអភិបាល និងក្រុមប្រឹក្សាស្រុក........ ២៦

**ផ្នែកទី៤៖ អង្គភាពចំណុះសាលាស្រុកបាទី** ........ ២៨

**កថាខណ្ឌទី១៖ នាយករដ្ឋបាល និងនាយករងរដ្ឋបាលសាលាស្រុក** ........ ២៨

ក. លក្ខខណ្ឌជ្រើសរើស ........ ២៨

ខ. តួនាទី ភារៈកិច្ច ........ ២៨

**កថាខណ្ឌទី២៖ ការិយាល័យចំណុះសាលាស្រុក**........ ៣០

ក. ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ........ ៣១

ខ. ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ........ ៣២

គ. ការិយាល័យអន្តរវិស័យ ........ ៣៣

ឃ. ការិយាល័យច្រកចេញចូលតែមួយ ........ ៣៤

ង. អង្គភាពលទ្ធកម្ម ........ ៣៤

## ជំពូកទី ២

## សមិទ្ធផលដែលទទួលបានពីឆ្នាំ ២០១៧ ដល់ ឆ្នាំ ២០១៩

**ផ្នែកទី១៖ សមិទ្ធផលដែលសម្រេចបានក្នុងវិស័យសំខាន់ក្នុងឆ្នាំ ២០១៧** ........ ៣៧

**កថាខណ្ឌទី១៖ លទ្ធផលការងាររដ្ឋបាល និងសន្តិសុខសង្គម** ........ ៣៧

ក. ការងាររដ្ឋបាលដែលសម្រេចបាន ........ ៣៧

ខ. ការងារសន្តិសុខសណ្តាប់សាធារណៈ........ ៣៩

**កថាខណ្ឌទី២៖ លទ្ធផលទទួលបានក្នុងវិស័យអភិវឌ្ឍន៍ជនបទ និងការរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាល** ........ ៣៩

ក. លទ្ធផលការងារនៃការអភិវឌ្ឍស្រុក........៤០

ខ. ការរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាល ..... ៤១

**កថាខណ្ឌទី៣៖ លទ្ធផលការងារក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌** ..... ៤២

ក. ការសម្រេចបានការងារក្នុងវិស័យសេដ្ឋកិច្ច ..... ៤២

ខ. ការសម្រេចបានការងារសង្គមកិច្ច និងវប្បធម៌ ..... ៤៣

**ផ្នែកទី២៖ សមិទ្ធផលដែលសម្រេចបានក្នុងវិស័យសំខាន់ក្នុងឆ្នាំ ២០១៨** ..... ៤៤

**កថាខណ្ឌទី១៖ លទ្ធផលការងាររដ្ឋបាល និងសន្តិសុខសង្គម** ..... ៤៤

ក. ការងាររដ្ឋបាលដែលសម្រេចបាន ..... ៤៤

ខ. ការងារសន្តិសុខសណ្តាប់សាធារណៈ ..... ៤៥

**កថាខណ្ឌទី២៖ លទ្ធផលទទួលបានក្នុងវិស័យអភិវឌ្ឍន៍ជនបទ និងរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាល** ..... ៤៦

ក. លទ្ធផលការងារនៃការអភិវឌ្ឍស្រុក ..... ៤៦

ខ. ការរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាល ..... ៤៨

**កថាខណ្ឌទី៣៖ លទ្ធផលការងារក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌** ..... ៤៩

ក. ការសម្រេចបានការងារក្នុងវិស័យសេដ្ឋកិច្ច ..... ៤៩

ខ. ការសម្រេចបានការងារសង្គមមិច្ច និងវប្បធម៌ ..... ៥០

**ផ្នែកទី២៖ សមិទ្ធផលសម្រេចបានក្នុងវិស័យសំខាន់ៗក្នុងឆ្នាំ២០១៩** ..... ៥១

**កថាខណ្ឌទី១៖ លទ្ធផលការងាររដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** ..... ៥១

ក. ការងាររដ្ឋបាលដែលសម្រេចបាន ..... ៥១

ខ. ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ..... ៥៣

**កថាខណ្ឌទី២៖ លទ្ធផលទទួលក្នុងវិស័យអភិវឌ្ឍន៍ជនបទ និងរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាល** ..... ៥៤

ក. លទ្ធផលការងារនៃការអភិវឌ្ឍស្រុក ..... ៥៤

ខ. ការរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាល ..... ៥៦

**កថាខណ្ឌទី៣៖ លទ្ធផលការងារក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌** ..... ៥៧

ក. ការងារសម្រេចបានក្នុងវិស័យសេដ្ឋកិច្ច ........ ៥៧
ខ. ការងារសម្រេចបានក្នុងវិស័យសង្គមកិច្ច ........ ៥៨
**សេចក្តីសន្និដ្ឋាន** ........ ៦១
**អនុសាសន៍** ........ ៦៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ស្រុកបាទី ជាស្រុកមួយក្នុងចំណោមស្រុកទាំងប្រាំបួន និងក្រុងមួយនៃខេត្តតាកែវ មានព្រំប្រទល់ខាងកើតជាប់ស្រុកស្អាង ខេត្តកណ្តាល ខាងលិចជាប់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ខាងជើងជាប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ខាងត្បូងជាប់ ស្រុកសំរោង ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ស្រុកចែកជា១៥ ឃុំ១៦៨ ភូមិមានផ្ទៃសរុប ៣៦៩គម² មានប្រជាជនសរុប១៥០.២៩៧នាក់នៅក្នុងនោះស្រី ៧៦.៩៩១នាក់ ត្រូវជា ៣០.២៦៧ គ្រួសារ មានដង់ស៊ីតេ ៤០៧ នាក់១គម² ។ ប្រជាជនប្រមាណ ៩០.៤១ ភាគរយជាកសិកររស់នៅពឹងផ្អែកវិស័យកសិកម្ម ដែលជាវិស័យចម្បង ក្នុងការទ្រទ្រង់ជីវភាពរស់ នៅរបស់ប្រជាពលរដ្ឋស្រុកបាទី។ ក្រៅពី វិស័យកសិកម្ម ដែលជាស្នូល និងជាចម្បងក៏មានវិស័យផ្សេងៗទៀតដូចជា តម្បាញសារុងហូលផលិតកញ្ជើល្អីផ្តៅវល្លិ៍ និងលក់ដូរនៅផ្សារ ។ល។ដែលជាមូលដ្ឋានបង្កើតការងារជូនប្រជាពលរដ្ឋ។

ស្រុកបាទីជានីតិបុគ្គល និងសមូហភាពដែនដីរបស់រដ្ឋក្នុងការបម្រើសេវាកម្មរដ្ឋបាលសាធារណៈជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានស្រុកបាទី ដែលស្របតាមឋានានុក្រម រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងគោលបំណងធានាអោយមាន សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយល្អ និងបម្រើផលប្រយោជន៍ទូទៅ។ យោងមាត្រា១៤៥ (ថ្មី) នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ទឹកដីព្រះរាជាណាចក្រកម្ពុជាត្រូវបានបែងចែកជារាជធានី និងខេត្ត។ រាជធានីចែកចេញជាខណ្ឌ។ ខណ្ឌចែកចេញជាសង្កាត់។ ខេត្តចែកចេញជាក្រុង និងស្រុក។ ក្រុងចែកចេញជាសង្កាត់។ ស្រុកចែកចេញជាឃុំ និងជាសង្កាត់។ ដើម្បីអាចសម្រេចបានទៅលើ ការលើកស្ទួយវិស័យកសិកម្មការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍន៍ផ្នែកឯកជន ការងារអភិបាលកិច្ចល្អការកសាងសមត្ថភាព ការអភិវឌ្ឍន៍ធនធានមនុស្ស ប្រកបដោយប្រសិទ្ធិភាព និងគុណភាពខ្ពស់ពិសេស គឺយកចិត្តទុកដាក់អោយបានច្រើនបំផុតទៅលើការអប់រំបច្ចេកទេសកសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្មកែច្នៃខ្នាតតូចមធ្យម និងការងារអប់រំគ្រប់កម្រិត ដើម្បីឲ្យមានបច្ចេកទេស និងវិជ្ជាជីវៈត្រឹមត្រូវ ទៅតាមជំនាញដែលសង្គមត្រូវការចាំបាច់បំផុត។ ដើម្បីឈានដល់ការប្រើប្រាស់បច្ចេកវិទ្យាទំនើបៗ គ្រប់ប្រភេទទៅតាមការរីកចម្រើននៃបច្ចេកវិទ្យាថ្មី និងទំនើបៗរបស់បណ្តាប្រទេសនានា នៅលើពិភពលោកបច្ចុប្បន្ននេះរាជរដ្ឋាភិបាល បានយកចិត្តទុកដាក់បំផុតលើការអប់រំបណ្តុះបណ្តាល និងការអភិវឌ្ឍន៏ធនធានមនុស្សគ្រប់កម្រិត។ ជាក់ស្តែងស្រុកបាទីរបស់ខេត្តតាកែវ ទាំងមូលជាសរសៃឈាមមួយ របស់សង្គមក៏ជាគន្លឹះ នៃការអភិវឌ្ឍន៍មូលដ្ឋានមួយរបស់ខេត្ត និងស្រុកបាទីហើយក៏ជាជំហានដំបូងឈានទៅរកភាពជោគជ័យទាំងកាត់បន្ថយភាពក្រីក្រនៅមូលដ្ឋានស្រុកបាទីផងដែរ។ ម៉្យាងទៀតនៅស្រុកបាទីនៃខេត្តតាកែវ ទាំងមូលផងដែរ គឺជាសរសៃឈាម នៃសង្គមជាតិដែលធ្វើអោយមានការអភិវឌ្ឍន៍មូលដ្ឋានមួយរបស់

ខេត្ត ហើយក៏អាចជាជំហានដំបូងនៃ ការកាត់បន្ថយនូវភាពក្រីក្ររបស់ ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ស្រុកបាទី។

ដូច្នេះហើយ ក៏មានសមិទ្ធផលជាច្រើនក៏បានកើតឡើងលូតលាស់ រីកចម្រើនជាបន្តបន្ទាប់មកដោយសារតែការគ្រប់គ្រង អនុវត្តន៍ការងាររបស់រដ្ឋបាលស្រុកបាទី ក្នុងការកសាងស្តារអភិវឌ្ឍន៏ទៅលើ គ្រប់វិស័យទាំងអស់នៅក្នុងមូលដ្ឋានរបស់ខ្លួនដែលទទួលបានលទ្ធផលគួរជាទីគាប់ប្រសើរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នាពេលបច្ចុប្បន្ននេះបញ្ហាចោទជាច្រើនកំពុងតែកើតឡើង ជាបន្តបន្ទាប់នៅក្នុងខេត្តតាកែវដែលជាខេត្តមួយកំពុងរៀបចំអភិវឌ្ឍន៏វិស័យទាំងនោះឱ្យមានភាពជឿនលឿនស្របតាមស្ថានការណ៍ ហើយថ្នាក់ដឹកនាំកំពុងពង្រឹងប្រព័ន្ធរដ្ឋបាល ពីព្រោះប្រព័ន្ធរដ្ឋបាល គឺជាស្នូលយ៉ាងសំខាន់សម្រាប់ការ អភិវឌ្ឍន៍ជាតិទាំងមូល។ ជាក់ស្តែងបើយើងក្រឡេកមកមើលស្រុកបាទីវិញ គឺអ្នកដឹកនាំអភិវឌ្ឍន៍ស្រុកបាទីទាំងមូលឱ្យមានការរីកចម្រើនសុវត្ថិភាពភូមិឃុំ និងដោះស្រាយរាល់បញ្ហាដែលកើតឡើង។ តើរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលស្រុកបាទីមានលក្ខណៈដូចម្តេច? តើសមិទ្ធផលសំខាន់ៗដែលទទួលបាននៅស្រុកបាទីមានអ្វីខ្លះ ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាលើប្រធានបទនេះ ( រដ្ឋបាលស្រុកបាទី និងសមិទ្ធផលសំខាន់ៗដែលទទួលបាន ពីឆ្នាំ ២០១៧ ដល់ឆ្នាំ ២០១៩ ) ក្នុងគោលបំណងស្វែងយល់ ពីការបែងចែករចនាសម្ព័ន្ធ នៃការគ្រប់គ្រងអំពីតួនាទីភារកិច្ច និងសិទ្ធិអំណាចរួមទាំងសមិទ្ធផលដែលទទួលបានពីវិស័យ សេដ្ឋកិច្ច សង្គមកិច្ច កសិកម្ម និងធនធានទឹក អប់រំ វប្បធម៌ និងសិល្បៈកិច្ចការនារីធ្វើអោយមានកា រអភិវឌ្ឍន៏រីកចម្រើន ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងស្រុកបាទីក៏កាន់តែ ធូរធារងាយស្រួល ក្នុងការប្រកបមុខរបបរកស៊ីចិញ្ចឹមជីវិត។ តាមរយៈ ការសិក្សាស្រាវជ្រាវនេះសមាជិកក្រុមប្រឹក្សាស្រុកបាទី បានខិតខំអនុវត្តន៍ការងារ បានយ៉ាងល្អតាមតួនាទី និងភារកិច្ចរៀងៗខ្លួនដើម្បីអោយប្រទេសជាតិមានការអភិវឌ្ឍជឿនលឿនប្រកបដោយចីរភាពទូទាំងផ្ទៃប្រទេសផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាប្រធានបទដែលបានកំណត់ខាងក្រោម គឺរដ្ឋបាលស្រុកបាទីនិងសមិទ្ធផលសំខាន់ៗដែលទទួលបានពីឆ្នាំ ២០១៧ ដល់ ឆ្នាំ ២០១៩ ផ្តោតសំខាន់ទៅលើសកម្មភាពថ្នាក់ដឹកនាំ និងសកម្មភាពការងាររដ្ឋបាលមានការអភិឌ្ឍន៍ ក្នុងមូលដ្ឋានសមត្ថកិច្ចរបស់ខ្លួន ដែលធានាបាននូវការលើកកម្ពស់ស្មារតី ទទួលខុសត្រូវរបស់ស្រុកផងដែរ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ក្រោយពីបានសិក្សាស្រាវជ្រាវលើប្រធានបទនេះ ពិតជាបានផ្តល់នូវសារៈសំខាន់ទៅកាន់ប្រជាពលរដ្ឋ និង

សិស្សនិស្សិត ជំនាន់ក្រោយៗទៀតឱ្យ មានការយល់ដឹងកាន់តែច្បាស់ អំពី អត្ថន័យថា តើអ្វីទៅជា វិមជ្ឈការ? និង អ្វីទៅជា វិសហមជ្ឈការ? ដែលប្រទេសកម្ពុជាយើងអនុវត្តន៏តាមក្របខណ្ឌគោលនយោបាយសម្រាប់កំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការក្នុងការគ្រប់គ្រងរដ្ឋ។ ហើយយើងខ្ញុំសង្ឃឹមថាសារណាស្រាវជ្រាវនេះប្រៀបដូចជាអ្នក នាំពាក្យរបស់ស្រុកបានបង្ហាញឃើញនូវតម្លៃ នៃសកម្មភាពរបស់ស្រុកបម្រើប្រជាពលរដ្ឋ និងមានទស្សនៈរួមក្នុង ការអភិវឌ្ឍន៏រីកចម្រើនទៅមុខជានិរន្តរ៍របស់ស្រុកនៃប្រទេសកម្ពុជា។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវ និងអនុវត្តន៍តាមរយៈ នៃការប្រមូលទិន្នន័យពីផ្សេងគ្នា ដែលពាក់ព័ន្ធ ជួបសម្ភាសជាមួយ គណៈអភិបាលស្រុកក្រុមប្រឹក្សាស្រុកនិងសាកសួរមន្ត្រីមួយចំនួនពីររបៀបផ្សេងទៀតនៃការប្រមូលទិន្នន័យ។ យើង ខ្ញុំបានប្រមូលទិន្នន័យ២ គឺ ទិន្នន័យចម្បង( Primary data) និងទិន្នន័យបន្ទាប់បន្សំ( Secondary data) គឺត្រូវបាន ប្រមូលឯកសារសម្រាប់ស្រាវជ្រាវ។

**ទិន្នន័យចម្បង( Primary data)**

ប្រមូលបានតាមរយៈការចុះស្រាវជ្រាវ ដោយផ្ទាល់ទៅដល់កន្លែងធ្វើការ និងត្រូវបានផ្តល់នូវការសម្ភាសន៍ ជាមួយអភិបាលស្រុកបាទី អង្គភាពរដ្ឋបាលស្រុក ក្រុមប្រឹក្សាការិយាល័យជុំវិញស្រុក និងស្ថាប័ននានាដែលនៅជុំ វិញស្រុក។

**ទិន្នន័យបន្ទាប់បន្សំ(Secondary data)**

- ឯកសារដែលបានមកពីអភិបាលស្រុកផ្តល់ឲ្យ
- ឯកសារស្រាវជ្រាវបានមកពីប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- ឯកសារជាលិខិតបទដ្ឋានគតិយុត្ត
- ឯកសារស្រាវជ្រាវរបស់និស្សិតជំនាន់មុននៅក្នុងបណ្ណាល័យ
- ឯកសារស្រាវជ្រាវតាមរយៈបណ្តោញសង្គមអ៊ីនធឺណេត( Internet )
- របាយការណ៍អនុវត្តន៍ការងារឆ្នាំ ២០១៧ដល់ ឆ្នាំ ២០១៩ របស់ក្រុមប្រឹក្សាស្រុកបាទី។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវត្រូវបានបែងចែកជា២ជំពូកគឺ

ជំពូកទី១៖ រចនាសម្ព័ន្ធនៃរដ្ឋបាលស្រុកបាទី

ជំពូកទី២៖ សមិទ្ធផលសំខាន់ៗដែលទទួលបានពីឆ្នាំ ២០១៧ ដល់ឆ្នាំ ២០១៩

# ជំពូកទី១

# រចនាសម្ព័ន្ធ នៃរដ្ឋបាលស្រុកបាទី

ការគ្រប់គ្រង មួយអាចប្រកបទៅដោយប្រសិទ្ធភាព គឺអាស្រ័យទៅលើថ្នាក់ដឹកនាំរបស់ខ្លួនដែលមាសមត្ថ-ភាពក្នុងការដឹកនាំត្រូវបានធ្វើការបែងចែកនូវតួនាទីភារកិច្ច ទៅតាមផ្នែកជំនាញបច្ចេកទេសរបស់បុគ្គលិក។ ម្យ៉ាងទៀតការគ្រប់គ្រងរដ្ឋបាលវិញ ក៏មិនខុសគ្នាដែរ គឺត្រូវមានការបែងចែករចនាសម្ព័ន្ធនៃការគ្រប់គ្រង ហើយមានការកំណត់ពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចឲ្យបានច្បាស់លាស់។

ជាក់ស្តែងរដ្ឋបាលស្រុកបាទី ដើម្បីឲ្យការគ្រប់គ្រង មានភាពងាយស្រួល និងឆាប់រហ័សនោះ ក្រុមប្រឹក្សាដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ផ្នែកទី១៖ ក្រុមប្រឹក្សាស្រុកបាទី

### កថាខណ្ឌទី១៖ ក្រុមប្រឹក្សាស្រុក និងវិមជ្ឈការ

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជារដ្ឋបាលវិសហមជ្ឈការរបស់រដ្ឋ ដែលត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ច្បាប់ស្តីពីការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។ ការបង្កើតក្រុមប្រឹក្សានេះត្រូវបានធ្វើឡើងតាមរយៈ ការបោះឆ្នោតជាអសកលដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបានប្រព្រឹត្តិឡើងជាលើកដំបូងកាលពីថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០០៩។

ជាក់ស្តែងស្រុកបាទីក៏បានបង្កើតឲ្យមានជាក្រុមប្រឹក្សារបស់ខ្លួន ដើម្បីឲ្យស្របតាមច្បាប់កំណត់ និងក្នុងគោលដៅ លើកកម្ពស់លទ្ធប្រជាធិបតេយ្យ និងសម្រេចបាននូវ នយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋា-ភិបាល ដោយលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

#### ក. សមាសភាព និងលក្ខខណ្ឌនៃការជ្រើសរើសក្រុមប្រឹក្សាស្រុក

##### ក.១. សមាសភាព

ក្រុមប្រឹក្សាមានអាណត្តិ ០៥ ឆ្នាំត្រូវផុតកំណត់នៅពេល ក្រុមប្រឹក្សាថ្មីចូលកាន់ដំណែង។[1] អាណត្តិរបស់ក្រុមប្រឹក្សា ត្រូវគិតចាប់ពីថ្ងៃបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់ថ្ងៃបោះឆ្នោតបន្ទាប់។[2] ក្នុងពេលរង់ចាំ

[1] មាត្រា ១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨
[2] មាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

ក្រុមប្រឹក្សាថ្មីចូលកាន់មុខតំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិ មានសិទ្ធិអនុវត្ត តែកិច្ចការរដ្ឋបាលប្រចាំថ្ងៃតែប៉ុណ្ណោះ។ ក្រុមប្រឹក្សានីមួយៗត្រូវមានប្រធានម្នាក់។ ប្រធានក្រុមប្រឹក្សាគឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជន ដែលមានអាសនៈច្រើនជាងគេ នៅក្នុងក្រុមប្រឹក្សា។ ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សាត្រូវជ្រើសរើសយកបេក្ខជន ដែលមានលេខរៀង លើគេនៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ។[3] ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជារាស្ត្រ និងកត្តាភូមិសាស្ត្រ។[4] សមាសភាពជាក់ស្តែង របស់ក្រុមប្រឹក្សា ស្រុកបាទី នៃខេត្តតាកែវក្នុងអាណត្តិទី៣ ដូចមានរាយនាមខាងក្រោមៈ[5]

១. លោក **អ៊ូ សុខជា** ជាប្រធានក្រុមប្រឹក្សាស្រុក

២. លោក **សុខ សារ៉ាន់** ជាសមាជិកក្រុមប្រឹក្សាស្រុក

៣. លោកស្រី **ម៉ែន សយ** ជាសមាជិកក្រុមប្រឹក្សាស្រុក

៤. លោក **គឹម សុខ** ជាសមាជិកក្រុមប្រឹក្សាស្រុក

៥. លោកស្រី **ឈឹន សុវណ្ណ** ជាសមាជិកក្រុមប្រឹក្សាស្រុក

៦. លោក **ឯម វុទ្ធី** ជាសមាជិកក្រុមប្រឹក្សាស្រុក

៧. លោក **ប៉ៅ ឈិន** ជាសមាជិកក្រុមប្រឹក្សាស្រុក

៨. លោក **ប៊ិច គឹមផុង** ជាសមាជិកក្រុមប្រឹក្សាស្រុក

៩. លោក **ឃួន យ៉ុង** ជាសមាជិកក្រុមប្រឹក្សាស្រុក

១០. លោក **ខាត់ ឌិន** ជាសមាជិកក្រុមប្រឹក្សាស្រុក

១១. លោក **ញ៉ែម ហ៊ែល** ជាសមាជិកក្រុមប្រឹក្សាស្រុក

១២. លោក **ប៉ែន សឿន** ជាសមាជិកក្រុមប្រឹក្សាស្រុក

១៣. លោក **អ៊ុំ និវឌ្ឍន៍** ជាសមាជិកក្រុមប្រឹក្សាស្រុក

១៤. លោក **លឿង សុង** ជាសមាជិកក្រុមប្រឹក្សាស្រុក

១៥. លោក **ប៉ាត យន** ជាសមាជិកក្រុមប្រឹក្សាស្រុក

[3] មាត្រា ១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

[4] មាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

[5] មាត្រា ១ នៃអនុក្រឹត្យលេខ ៧៤៨ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកបាទី នៃខេត្តតាកែវ

១៦. លោកស្រី **យ៉ែម វណ្ណា** ជាសមាជិកក្រុមប្រឹក្សាស្រុក

១៧. លោក **ចាន់ សុភា** ជាសមាជិកក្រុមប្រឹក្សាស្រុក

១៨. លោក **ហង់ ង៉** ជាសមាជិកក្រុមប្រឹក្សាស្រុក

១៩. លោក **ពេជ ឌឿន** ជាសមាជិកក្រុមប្រឹក្សាស្រុក

២០. លោក **ឌុយ បូរិន** ជាសមាជិកក្រុមប្រឹក្សាស្រុក

២១. លោក **ឡាំង វាសនា** ជាសមាជិកក្រុមប្រឹក្សាស្រុក

### ក.២. លក្ខខណ្ឌនៃការជ្រើសរើស និងការបាត់បង់សមាជិកភាពក្រុមប្រឹក្សា

ប្រជាពលរដ្ឋខ្មែរ ទាំងពីរភេទ មានសិទ្ធឈរឈ្មោះ ជាបេក្ខភាពក្រុមប្រឹក្សាលុះត្រាតែបានបំពេញលក្ខខណ្ឌមួយចំនួន ដែលបានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។ ជាក់ស្តែងក្រុមប្រឹក្សាស្រុកបាទីក៏មិនខុសគ្នានោះទេ គឺអនុវត្តតាមច្បាប់ទាំងស្រុងទាក់ទងនឹងលក្ខខណ្ឌនៃការជ្រើសរើសនិងការបាត់បង់សមាជិកភាពនេះ។

❖ **លក្ខខណ្ឌនៃការជ្រើសរើសក្រុមប្រឹក្សាស្រុក**

តាមរយៈច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានកំណត់ឱ្យបេក្ខជនទាំងអស់ ដែលមានបំណងឈរឈ្មោះជាបេក្ខភាពក្រុមប្រឹក្សាត្រូវមានលក្ខណៈសម្បត្តិមួយចំនួនដូចខាងក្រោម៖ [6]

- មានសញ្ជាតិខ្មែរពីកំណើត
- ត្រូវមានអាយុយ៉ាងតិច២៥ ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត
- ត្រូវបានបោះឆ្នោត និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់ស្តីការបោះឆ្នោះជ្រើសរើសក្រុមប្រឹក្សា។

❖ **ការបាត់បង់សមាជិកភាព**

ទោះបីក្លាយជាសមាជិកក្រុមប្រឹក្សាហើយក៏ដោយ ក៏អាចបាត់បង់សមាជិកភាពរបស់ខ្លួនពីក្រុមប្រឹក្សាផងដែរ

[6] មាត្រា ២១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

ក្នុងករណីមួយចំនួនដូចខាងក្រោមៈ[7]

- សាមីខ្លួនបាត់បង់លក្ខណៈសម្បត្តិ និងលក្ខខណ្ឌសម្រាប់ឈរឈ្មោះជាបេក្ខជន
- សាមីខ្លួនសុំលាឈប់ពីក្រុមប្រឹក្សា
- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនមិនអាចចូលរួមក្នុងកិច្ចប្រជុំសាមញ្ញជាប់គ្នាចាប់ពី០២ ដងឡើងទៅដោយគ្មានការអនុញ្ញាត
- សាមីខ្លួនត្រូវបណ្តេញចេញពីសមាជិកក្រុមប្រឹក្សា
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬ ជម្លឹមណាមួយ
- សាមីខ្លួនបាត់បង់នូវសមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន។

បន្ទាប់ពី បាត់បង់នូវសមាជិកភាព ក្រុមប្រឹក្សាហើយនោះ ក្រុមប្រឹក្សាត្រូវមាននីតិវិធានការបន្ទាន់ក្នុងការជ្រើសរើសសមាជិកថ្មីមកជំនួសវិញ គឺត្រូវជ្រើសរើសបេក្ខជន ដែលមានលេខរៀងបន្ទាប់ពីក្នុងបញ្ជី បេក្ខជនជាមួយមកជំនួសក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[8]

### ក.៣. លក្ខខណ្ឌរំសាយក្រុមប្រឹក្សា និង ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឡើងវិញ

គ ជ ប ត្រូវរៀបចំការបោះឆ្នោតឡើងវិញ ដើម្បី ជ្រើសរើសក្រុមប្រឹក្សា ក្នុងករណីណាមួយដូចខាងក្រោមៈ[9]

- ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានបង្កើតថ្មី ដូចមានចែងក្នុងមាត្រា ៦ និង មាត្រា ៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ២៤០ ថ្ងៃ ។
- ក្រុមប្រឹក្សាដែលត្រូវរំសាយត្រូវធ្វើឡើងយ៉ាងយូរ១២០ថ្ងៃ។ ក្រុមប្រឹក្សាដែលបង្កើតឡើងដោយការបោះឆ្នោត
- ឡើងវិញត្រូវមានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សានោះ។ ការបោះឆ្នោតឡើងវិញមិនអនុញ្ញាតឲ្យធ្វើឡើយប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាមានរយៈពេលមិនសើលពី១៨០ថ្ងៃ។
- ក្នុងករណីនេះរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់វិធានការ ដើម្បីគ្រប់គ្រងជំនួសរហូតដល់មានក្រុមប្រឹក្សាថ្មីចូលមកជំនួសតំណែង ។

## ខ. តួនាទី ភារកិច្ច និងសិទ្ធិអំណាចក្រុមប្រឹក្សាស្រុក

### ខ.១. តួនាទីរបស់ក្រុមប្រឹក្សា

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជំរុញ

---

[7] មាត្រា ២២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

[8] មាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

[9] សៀវភៅមេរៀននីតិរដ្ឋបាល របស់លោកសាស្ត្រាចារ្យ **យូ តូនី** ឆ្នាំ ២០១៩ ទំព័រទី ៩-១០

និងការធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់។[10]

### ខ.២. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

ក្រុមប្រឹក្សាស្រុកមានសិទ្ធិអំណាចពីរ គឺធ្វើសេចក្ដីសម្រេចខាងបញ្ញត្តិ និងធ្វើសេចក្ដីសម្រេចខាងប្រតិបត្តិ ប្រធានក្រុមប្រឹក្សាស្រុកក្នុងនាមក្រុមប្រឹក្សាស្រុករបស់ខ្លួនមានសិទ្ធិចុះហត្ថលេខានិងប្រថាប់ត្រារដ្ឋបាលស្រុក៖[11]

- ដីកា ឬសេចក្ដីសម្រេចដែលក្រុមប្រឹក្សាស្រុកបានអនុម័តរួច
- សេចក្ដីសម្រេចបង្កើតគណៈកម្មាធិការឬអនុគណៈកម្មាធិការ ឬ ក្រុមការងារតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាស្រុក
- កំណត់ហេតុប្រជុំដែលអង្គប្រជុំក្រុមប្រឹក្សាស្រុកបានអនុម័ត
- សំណើដកហូត អភិបាលស្រុក ឬ អភិបាលរងស្រុកចេញពីមុខតំណែងតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាស្រុក

គណៈអភិបាលស្រុក ត្រូវជួយក្រុមប្រឹក្សាស្រុករបស់ខ្លួនក្នុងការរៀបចំឯកសារខាងលើនេះលើកលែងតែឯកសារសម្រាប់រៀបចំកិច្ចប្រជុំទាក់ទង និងសំណើដកហូតអភិបាលស្រុក ឬអភិបាលរងស្រុកចេញពីមុខតំណែង។

ក្រុមប្រឹក្សាត្រូវបំពេញមុខងារ និងភារកិច្ច ដោយធ្វើសេចក្ដីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្ដីសម្រេចនោះត្រូវបានអនុវត្ត។

### គ. ទិសដ្ឋភាពនៃក្រុមប្រឹក្សាស្រុកបាទី

យោងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ត្រង់មាត្រា ២ បានចែងថា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍រដ្ឋបាលឯកភាព ដើម្បីបង្កើតជម្រុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ ហើយរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្លាយទៅជានីតិបុគ្គលសាធារណៈតាមរយៈគោលនយោបាយ ដូច្នេះវាពិតប្រាដកណាស់ថាចាំបាច់ត្រូវតែមាន ក្រុមប្រឹក្សាសម្រាប់ធ្វើកាគ្រប់គ្រងដឹកនាំនីតិបុគ្គលនេះ។ ក្រុមប្រឹក្សាមានអំណាចក្នុងការធ្វើសេចក្ដីសម្រេចផ្សេងៗទៅបាន គឺអាស្រ័យដោយរដ្ឋបាលថ្នាក់ជាតិបានធ្វើវិមជ្ឈការដល់ការពួកគេ ហើយត្រូវកំណត់ដោយច្បាប់ និងលិខិតបទដ្ឋាននានា។

---

[10] មាត្រា ២៩ នៃច្បាប់ស្ដីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

[11] មាត្រា ១៣១ នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ចុះថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ ២០០៩

ការផ្តល់និយមន័យ ទាក់ទងទៅនឹងវិមជ្ឈការ គឺមានលក្ខណៈខុសៗប្លែកពីគ្នាទៅតាមទស្សនៈរៀងៗខ្លួន។

លោកសាស្ត្រាចារ្យ **ហៀងសាង** បានឲ្យនិយមន័យថាវិមជ្ឈការថា គឺជាប្រព័ន្ធគ្រប់គ្រងរដ្ឋបាលមួយដែលអាជ្ញាធររដ្ឋបាល ទទួលស្គាល់នូវសិទ្ធិអំណាចនៅក្នុងការសម្រេចរបស់ អាជ្ញាធររដ្ឋបាលមូលដ្ឋានដោយមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់នានា។ ម៉្យាងទៀត វិមជ្ឈការ គឺជាការផ្ទេរអំណាចរបស់រដ្ឋទៅឲ្យនីតិបុគ្គលសាធារណៈខុសពីរដ្ឋ។ នីតិបុគ្គលសាធារណៈនេះ មានស្វ័យភាពតិច ឬ ច្រើនទៅតាមកម្រិតនៃវិមជ្ឈការស្វ័យភាពថវិកាផ្ទាល់ ហើយដែលស្ថិតនៅក្រោមការតាមដាន របស់រដ្ឋដែលជាអាជ្ញាធរអាណាព្យាបាល។[12] ម៉្យាងវិញទៀត តាមសន្ទានក្រុមនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ វិញបានឲ្យនិយមន័យថា វិមជ្ឈការ សំដៅលើអ្វីដែលរាជរដ្ឋបាលភិបាលបានប្រគល់ឲ្យក្រុមប្រឹក្សានូវភាពជាម្ចាស់ លើមុខងារ សិទ្ធិអំណាច និងធនធានដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់មូលដ្ឋាន ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាព ចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនោះ។

សរុបសេចក្តីមក វិមជ្ឈការ គឺជាប្រព័ន្ធមួយដែលអាជ្ញាធររដ្ឋបាលកណ្តាលទទួលស្គាល់នូវសិទ្ធិអំណាចក្នុងការសម្រេចរបស់អាជ្ញាធរថ្នាក់មូលដ្ឋាន លើកិច្ចការណាដែលជាប្រយោជន៍របស់សមូហភាពដែនដីនោះហើយសិទ្ធិអំណាចនោះត្រូវបានបែងចែកក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់នានា។

នៅក្នុងការគ្រប់គ្រងរដ្ឋបាល តាមប្រព័ន្ធវិមជ្ឈការគឺទោះបីទម្រង់នៃការរៀបចំនេះបានផ្ទេរទៅឲ្យសមូហភាពដែនដីនូវសិទ្ធអំណាច ក្នុងការសម្រេចប្រកបដោយស្វ័យភាព។ តែទោះជាយ៉ាងណាក៏ដោយក៏នៅមានកិច្ចការធំៗ និង សំខាន់ៗចាំបាច់ផ្សេងទៀត ដែលអាជ្ញាធររដ្ឋបាលកណ្តាល ឱបក្រសោបផ្តាច់មុខមិនឲ្យអាជ្ញាធរ វិមជ្ឈការដែនដីនេះក្នុងការសម្រេចដែរយើងឃើញមាននោះគឺ[13]៖

- អំណាចកិច្ចការពារប្រទេសជាតិ (កងទ័ព)
- អំណាចកិច្ចការសន្តិសុខជាតិ (នគរបាល)
- អំណាចកិច្ចការការទូត
- អំណាចកិច្ចការពាណិជ្ជកម្មក្រៅប្រទេស
- អំណាចបោះពុម្ពក្រដាសប្រាស់
- អំណាចកិច្ចការតុលាការ

[12] សៀវភៅនីតិរដ្ឋបាលទូទៅរបស់សាស្ត្រចារ្យ ហៀង សាង បោះពុម្ពលើកទី៥(ទំព័រទី១៦៦និង១៦៧)
[13] សៀវភៅនីតិរដ្ឋបាលទូទៅរបស់សាស្ត្រចារ្យ ហៀង សាង បោះពុម្ពលើកទី៥(ទំព័រទី១៦៨)

- អំណាចកិច្ចការធ្វើច្បាប់
- អំណាចកិច្ចការអត្រានុកូលដ្ឋាន និងអំណាចផ្សេងៗទៀតដែលច្បាប់រដ្ឋបានកំណត់ ។

បច្ចេកទេសនៃការគ្រប់គ្រង តាមប្រព័ន្ធវិមជ្ឈការ មានលក្ខណៈសំខាន់ៗ០៣ យ៉ាងគឺ[14]៖

➢ **បុគ្គលភាពគតិយុត្ត**

អង្គការវិមជ្ឈការមានបុគ្គលភាពគតិយុត្តខុសពីរដ្ឋ។ អង្គការទាំងនេះជាប្រធាននៃនីតិផ្សេងពីរដ្ឋ។អង្គការទាំងនេះមានសិទ្ធិ និងកាតព្វកិច្ចផ្ទាល់ខ្លួនមានគោលដៅផ្ទាល់ មានទ្រព្យសម្បត្តិផ្ទាល់(ចលនទ្រព្យ និងអចលនាទ្រព្យ) ។

➢ **សមត្ថកិច្ចផ្ទាល់ខ្លួន**

- អង្គការវិមជ្ឈការមានសមត្ថកិច្ចខុសពីសមត្ថកិច្ចរបស់រដ្ឋ។ មានលក្ខណៈគតិយុត្តពីរៈ
- មិនមែនជាសមត្ថកិច្ចជាគោលការណ៍ទេប៉ុន្តែជាសមត្ថកិច្ចដែលកំណត់(ដោយច្បាប់)។ប្រកាសនេះទាញចេញពីលក្ខណៈឯកភាពរបស់រដ្ឋ។
- នៅពេលរដ្ឋកំណត់ភារកិច្ចឲ្យហើយរដ្ឋមិនអាចចូលធ្វើអន្តរាគមន៏បានទេ។ សមត្ថកិច្ចត្រូវអនុវត្តន៍ក្នុងនាមនៃអង្គការវិមជ្ឈការ។

➢ **ការប្រើសមត្ថកិច្ចស្វយ័ត**

- គ្មានការរណបឋានានុក្រមទេរវាងរដ្ឋ និងអង្គការវិមជ្ឈការ ។ គ្មានអំណាចបង្គាប់បញ្ជាទេ។ ប៉ុន្តែការត្រួតពិនិត្យ របស់អំណាចកណ្តាលនៅតែមាននៅឡើយព្រោះរដ្ឋនៅតែជារដ្ឋទោលដដែល។ ហើយស្វ័យភាព មិនមែនជាឯករាជ្យភាពទេ ។ ការត្រួតពិនិត្យនេះត្រូវបានធ្វើឡើងតាមរបៀបពីរយ៉ាងទៅតាមអង្គការត្រួតពិនិត្យ គឺការត្រួតពិនិត្យដោយតុលាការឬការត្រួតពិនិត្យដោយតុលាការជាអាជ្ញាធររដ្ឋបាល ។

**កថាខណ្ឌទី២៖ គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា**

ដើម្បីជួយជំរុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យហើយនិងជួយសម្រួលការងារជូនក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលឱ្យមានដំណើរការប្រព្រឹត្តទៅយ៉ាងរលូនប្រកបដោយប្រសិទ្ធភាពតម្លាភាពតាមបែបលទ្ធិប្រជាធិបតេយ្យ។ ហេតុដូច្នេះច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ បានតម្រូវឲ្យមានការរៀបចំបង្កើតឡើងនូវគណៈ-

[14] សៀវភៅនីតិរដ្ឋបាលទូទៅរបស់សាស្ត្រាចារ្យ ឌៀក ពិដោរ បោះពុម្ពលើកទី២(ទំព័រទី៦២និង៦៣)

កម្មាធិការ សំខាន់ៗចំនួន០៣ មានដូចជាគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារគណៈ កម្មាធិការសម្របសម្រួលបច្ចេកទេស និងគណៈកម្មាធិការលទ្ធកម្ម។[15]

ដើម្បីយល់កាន់តែច្បាស់ នៃគណៈកម្មាធិការនានា របស់ក្រុមប្រឹក្សានោះ យើងសូមលើកយក នូវគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សានៃស្រុកបាទី ខេត្តតាកែវ យកមកបង្ហាញសមាសភាពជាក់ស្តែងដូចខាងក្រោម៖

**ក. គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

ក្រុមប្រឹក្សាស្រុកត្រូវរៀបចំឱ្យមានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ខ្លួន ដើម្បីជួយសិក្សា និងផ្តល់យោបល់ដល់ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុករបស់ខ្លួនលើបញ្ហាទាក់ទង នឹងការងារផែនការថវិកា ការសម្របសម្រួលកិច្ចការ នានាជាមួយមន្ទីរអង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងក្រុមប្រឹក្សាប្រភេទផ្សេងទៀតនិងបញ្ហាទាក់ទងនិងមុខងារធនធានដែលបានប្រគល់ឬបានធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សាស្រុក។

**ក.១. សមាសភាពនៃកម្មាធិការសម្របសម្រួលបច្ចេកទេស**

ដោយផ្អែកទៅលើមាត្រា ២១ នៃអនុក្រឹត្យលេខ:២១៨.អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង គណៈកម្មាធិ-ការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក។ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មានសមាសភាពដូចខាងក្រោម ៖

- អភិបាលស្រុក ជាប្រធាន
- អភិបាលរងស្រុក០១រូប ជាអនុប្រធាន
- នាយករដ្ឋបាលសាលាស្រុក ជាសមាជិកអចិន្ត្រៃយ៍
- សមាជិកក្រុមប្រឹក្សាស្រុកយ៉ាងតិច០២រូប ជាសមាជិក
- ប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានា របស់រាជរដ្ឋាភិបាលដែលប្រចាំនៅស្រុក ជាសមាជិក
- ប្រធានការិយាល័យទាំងអស់របស់សាលាស្រុក ជាសមាជិក
- មេឃុំ ចៅសង្កាត់ទាំងអស់នៅក្នុងស្រុក ជាសមាជិក
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាស្រុក ០១ រូបជាសមាជិក

[15] មាត្រា១១៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

ដោយផ្អែកតាមសេចក្តីសម្រេចលេខ ០៧ សសរ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ( គ.ជ.ប)ចុះថ្ងៃទី ២៧ខែសីហា ឆ្នាំ២០១៩ស្តីពីទទួលស្គាល់ប្រធានអនុប្រធាន និងសមាជិកគណៈកម្មាធិការ សម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាស្រុកបាទី ប្រធានក្រុមប្រឹក្សាស្រុកបាទីមានរាយនាមដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. លោក **ភួន ឈឹម** | អភិបាលស្រុក | ប្រធាន |
| ២. លោកស្រី **ជា ណារ៉េម** | អភិបាលរងស្រុក | អនុប្រធាន |
| ៣. លោក **វៀម វណ្ណារី** | នាយករដ្ឋបាល | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. លោក **គឹម សុខ** | ក្រុមប្រឹក្សាស្រុក | សមាជិក |
| ៥. លោក **លឿង សុង** | ក្រុមប្រឹក្សាស្រុក | សមាជិក |
| ៦. លោក **ប៉ៅ ឈិន** | ក្រុមប្រឹក្សាស្រុក | សមាជិក |
| ៧. លោក **ឯម វុទ្ធី** | ក្រុមប្រឹក្សាស្រុក | សមាជិក |
| ៨. លោក **ថៅ ប៊ុនធឿន** | អនុប្រធានការិយាល័យស្រុក | សមាជិក |
| ៩. លោកស្រី **ម៉ែន សយ** | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ | សមាជិក |
| ១០. លោក **យុគ សុផុន** | ប្រធានការិ.អប់រំយុវជននិងកីឡាស្រុក | សមាជិក |
| ១១. លោក **សំរិទ្ធ វីរៈ** | អនុប្រធានការិ.ស្រុកប្រតិបត្តិ | សមាជិក |
| ១២. លោក **នៅ ណារិន** | ប្រធានការិ.កសិកម្ម | សមាជិក |
| ១៣. លោក **ភឹម សារិន** | ប្រធានការិ.សង្គមកិច្ចអតីតយុទ្ធជន | សមាជិក |
| ១៤. លោកស្រី **ឡេង ចានធួន** | មន្ត្រីការិ.ធម្មការនិងសាសនា | សមាជិក |
| ១៥. លោក **ចាន់ ញ៉ឹប** | អនុប្រធានការិ.សាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១៦. លោក **ទូច សារុន** | ប្រធានការិ.ដ.ន.ស.ភ | សមាជិក |
| ១៧. លោក **នៅ ចាន់ណា** | ប្រធានការិ.វប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១៨. លោក **សូ វ៉ាត** | ប្រធានការិ.ឧស្សាហកម្ម | សមាជិក |
| ១៩. លោក **សោ ស៊ីណា** | ប្រធានការិ.ឧស្សាហកម្មសិប្បកម្ម | សមាជិក |
| ២០. លោក **ខាត់ ប៊ុនធឿន** | មន្ត្រីការិ.បរិស្ថាន | សមាជិក |
| ២១. លោក **យុន ណារ៉ន** | ប្រធានការិ.អភិវឌ្ឍន៏ជនបទ | សមាជិក |

| | | |
|---|---|---|
| ២២. លោក **គាំ កាណន់** | ប្រធានការិ.ទេសចរណ៍ | សមាជិក |
| ២៣. លោក **ង៉ែត ស្រស់** | ប្រធានការិ.រដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ២៤. លោក **គង់ សំរិទ្ធ** | អនុប្រធានការិ.អន្តរវិស័យស្រុក | សមាជិក |
| ២៥. កញ្ញា **សំអុល ទិត្យសុគន្ធារី** | ប្រធានការិ.ផែនការនិងគាំទ្រឃុំ | សមាជិក |
| ២៦. លោក **ឡៅ ហ៊ត** | ប្រធានការិ.ធនធានទឹក | សមាជិក |
| ២៧. លោកស្រី **មុំ សោភ័ណ្ឌ** | អនុការិ.កិច្ចការនារីស្រុក | សមាជិក |
| ២៨. លោក **ចាន់ យ៉ែម** | មេឃុំចំបក់ | សមាជិក |
| ២៩. លោក **ហង់ វ៉ៃ** | មេឃុំចំប៉ី | សមាជិក |
| ៣០. លោក **ណុច ទូច** | មេឃុំដូង | សមាជិក |
| ៣១. លោក **ស្រី សំបូរ** | មេឃុំកណ្តឹង | សមាជិក |
| ៣២. លោក **ចាន់ សុខន** | មេឃុំកុមាររាជា | សមាជិក |
| ៣៣. លោក **ទូច សឿន** | មេឃុំក្រាំងលាវ | សមាជិក |
| ៣៥. លោក **ឆេ សយ** | មេឃុំលំពង់ | សមាជិក |
| ៣៦.លោក **វង់ វ៉ាន** | មេឃុំពារាម | សមាជិក |
| ៣៧. លោក **ភួន ឈៀង** | មេឃុំពត់សរ | សមាជិក |
| ៣៨. លោក **ជា សុងហៀង** | មេឃុំសូរភី | សមាជិក |
| ៣៩. លោក **ទីវ ហួន** | មេឃុំត្រពាំងដូង | សមាជិក |
| ៤០. លោក **អ៊ុក សំបូរ** | មេឃុំត្នោត | សមាជិក |
| ៤១. លោក **ពេជ សារ៉ា** | មេឃុំត្រពាំងសាប | សមាជិក |

សមាសភាព អនុប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាស្រុកត្រូវស្នើដោយអភិ-បាលស្រុក។ ក្រុមប្រឹក្សាស្រុក ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាព ប្រធានអនុប្រធាននិងសមាជិក គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក។ សេចក្តីសម្រេចនេះត្រូវចុះហត្ថលេខា ដោយប្រធាន ក្រុមប្រឹក្សាស្រុក។

**ក.២. តួនាទី ភារកិច្ចគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសមានតួនាទី និងភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សាស្រុក និង

គណៈអភិបាលស្រុក លើកិច្ចការសំខាន់ៗដូចខាងក្រោមៈ

### ក.២.១. ផែនការអភិវឌ្ឍន៏ និងថវិកា

- ការដាក់បញ្ចូលផែនការអភិវឌ្ឍន៍ និងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរការិយាល័យ អង្គភាពនានា របស់រាជរដ្ឋាភិបាល ដែលបានផ្តល់សេវាសម្ភារៈឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ច របស់ក្រុមប្រឹក្សាស្រុកទៅក្នុង ៖
  - ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់ក្រុមប្រឹក្សាស្រុក
  - កម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាស្រុក
  - ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ក្រុមប្រឹក្សាស្រុក
  - គម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាស្រុក
- សេចក្តីព្រាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំ ឆ្នាំរបស់ ក្រុមប្រឹក្សាស្រុក និងធ្វើបច្ចុប្បន្នភាព
- សេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាស្រុក
- សេចក្តីព្រាងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ក្រុមប្រឹក្សាស្រុក និងការធ្វើបច្ចុប្បន្នភាព
- សេចក្តីព្រាងគម្រោងវិភាជន៍មូលនិធិវិនិយោគស្រុក ដើម្បីគាំទ្រដល់កម្មវិធីនានា របស់ស្រុក
- របាយការណ៍រីកចម្រើននានា ទាក់ទងដល់ការងារផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងថវិការបស់ក្រុមប្រឹក្សាស្រុក។

## ខ. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

ក្រុមប្រឹក្សាស្រុកត្រូវរៀបចំឲ្យមានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ( គ.ក.ស.ក) ដែលមានសិទ្ធិ និងមានភារៈកិច្ចផ្តល់យោបល់ និងលើកអនុសាសន៍ជូនក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក អភិបាលស្រុក និងគណៈកម្មាធិកាដទៃទៀតរបស់ក្រុមប្រឹក្សាស្រុក លើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ និងកុមារ ដែលស្ថិតនៅក្នុងអំណាចមុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សាស្រុក។

### ខ.១. សមាភាពនៃ គ.ក.ស.ក

គណៈកម្មាធិការ ពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សា-ខណ្ឌត្រូវរៀបចំទៅតាមការកំណត់ដូចក្នុងមាត្រា ៣ នៃប្រកាសលេខ ៤២៧៥.ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅក្នុងក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - សមាសជិកក្រុមប្រឹក្សាជាស្ត្រី ដែលជ្រើសរើសដោយក្រុមប្រឹក្សា | ប្រធាន |
| - សមាជិកក្រុមប្រឹក្សា ដែលជ្រើសរើសដោយក្រុមប្រឹក្សា | អនុប្រធាន |
| - អភិបាលរងជាស្ត្រី០១រូប | អនុប្រធាន |
| - ប្រធាន ឬអនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(បើមាន) | អនុប្រធាន |
| - ប្រធាន ឬអនុប្រធានមន្ទីរកិច្ចការនារី | អនុប្រធានអចិន្ត្រៃយ៍ |
| - នាយករដ្ឋបាល ០១រូប | សមាជិក |
| - ប្រធាន ឬអនុប្រធានមន្ទីរផែនការ | សមាជិក |
| - ប្រធាន ឬអនុប្រធានមន្ទីរសុខាភិបាល | សមាជិក |
| - ប្រធាន ឬអនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ (បើមាន) | សមាជិក |
| - ប្រធាន ឬអនុប្រធានមន្ទីរអប់រំ យុវជននិងកីឡា | សមាជិក |
| - ប្រធាន ឬអនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (បើមាន) | សមាជិក |
| - ប្រធាន ឬអនុប្រធានមន្ទីរកសិកម្ម | សមាជិក |
| - ស្នងការ ឬតំណាងស្នងការដ្ឋាននគរបាល | សមាជិក |
| - នាយក ឬនាយករងទីចាត់ការអន្តរវិស័យ | សមាជិក |
| - ប្រធាន ឬអនុប្រធានសហគមន៍ក្រុមប្រឹក្សាឃុំ សង្កាត់នៃរាជធានី ខេត្ត | សមាជិក |
| - តំណាងពីស្ថាប័ន ឬអង្គភាពផ្សេងទៀត តាមការចាំបាច់ | សមាជិក |

ជាក់ស្តែងដោយផ្អែកយោងទៅតាមសេចក្តីសម្រេចលេខ ០៨ សសរ របស់ប្រធានក្រុមប្រឹក្សាស្រុក ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៩ស្តីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារស្រុកបាទីខេត្តតាកែវ មានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. លោកស្រី **ឈឹន សុវណ្ណា** | សមាជិកក្រុមប្រឹក្សាស្រុក | ប្រធាន |
| ២. លោកស្រី **ម៉ែន សយ** | សមាជិកក្រុមប្រឹក្សាស្រុក | អនុប្រធាន |
| ៣. លោកស្រី **ជា ណាវ៉េម** | អភិបាលរងស្រុក | អនុប្រធាន |
| ៤. លោក **ភឹម សារិន** | ប្រធានការិ.សង្គមកិច្ចនិងអតីតយុទ្ធជន | អនុប្រធាន |
| ៥. លោកស្រី **ប្រាក់ សុជាតិ** | ប្រធានការិ.កិច្ចការនារីស្រុក | អនុប្រធានអចិន្ត្រៃយ៍ |
| ៦. លោក **អ៊ុច ឈឹង** | នាយករដ្ឋបាល | សមាជិក |
| ៧. លោក **ថៅ ប៊ុនធឿន** | ប្រធានការិ.ផែនការស្រុក | សមាជិក |

| | | |
|---|---|---|
| ៨. លោក **សំរិទ្ធិ វីរៈ** | ប្រធានផ្នែករដ្ឋបាលការិ.សុខាភិបាលស្រុកប្រតិបត្តិ | សមាជិក |
| ៩. លោក **យុន សារ៉ន** | ប្រធានការិ.អភិវឌ្ឍន៍ជនបទ | សមាជិក |
| ១០. លោក **យុគ សុផុន** | ប្រធានការិ.អប់រំយុវជននិងកីឡា | សមាជិក |
| ១១. លោក **នៅ ណារិន** | ប្រធានការិ.កសិកម្ម | សមាជិក |
| ១២. លោក **ឆេង សុខា** | អធិការរងនគរបាលស្រុក | សមាជិក |
| ១៣. លោក **ង៉ែត ស្រស់** | ប្រធានការិ.រដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ១៤. លោក **អ៊ុក ហូរីហ្សា** | មន្ត្រីការិ.អន្តរវិស័យ | សមាជិក |
| ១៥. កញ្ញា **សំអុល ទិត្យសុគន្ធារី** | ប្រធានការិ.ផែនការនិងគាំទ្រឃុំ | សមាជិក |
| ១៦. លោកស្រី **ឡេង ចាន់ធួន** | មន្ត្រីការិ.ធម្មការ និងសាសនា | សមាជិក |
| ១៧. លោកស្រី **អ៊ូ សុខន** | សមាជិកក្រុមប្រឹក្សាឃុំចំប៉ី | សមាជិក |
| ១៨. លោក **សោម បូរិន** | ជនបង្គោលទទួលបន្ទុកកិច្ចការស្ត្រីនិងកុមារឃុំដូង | សមាជិក |
| ១៩. លោកស្រី **ឡាយ បូរិន** | សមាជិកក្រុមប្រឹក្សាឃុំ កណ្ដឹង | សមាជិក |
| ២០. លោកស្រី **ណើ សារ៉ន** | សមាជិកក្រុមប្រឹក្សាឃុំកុមាររាជា | សមាជិក |
| ២១. លោកស្រី **ប៊ូ ខន** | សមាជិកក្រុមប្រឹក្សាឃុំក្រាំងលាវ | សមាជិក |
| ២២. លោកស្រី **នូ សុខនា** | ជំទប់ទី១ឃុំក្រាំងធ្នង់ | សមាជិក |
| ២៣. លោកស្រី **ប៊ុន ភិន** | សមាជិកក្រុមប្រឹក្សាឃុំលំពង់ | សមាជិក |
| ២៤. លោកស្រី **សួង ហឿន** | សមាជិកក្រុមប្រឹក្សាឃុំពារាម | សមាជិក |
| ២៥. លោកស្រី **ម៉ុន ស្រីនី** | សមាជិកក្រុមប្រឹក្សាឃុំពត់សរ | សមាជិក |
| ២៦.លោកស្រី **ឈឹន គឹមស្រៀង** | សមាជិកក្រុមប្រឹក្សាឃុំសូរភី | សមាជិក |
| ២៧. លោកស្រី **ប្រុក ស៊ីវន** | ជនបង្គោលទទួលបន្ទុកកិច្ចការស្ត្រីនិងកុមារតាំងដូង | សមាជិក |
| ២៨. លោកស្រី **សំ សុគាំ** | សមាជិកក្រុមប្រឹក្សាឃុំត្នោត | សមាជិក |
| ២៩. លោកស្រី **ប៉េង សាវឿន** | ជំទប់ទី១ ឃុំត្រពាំងក្រសាំង | សមាជិក |
| ៣០. លោកស្រី **ហ៊ុន អុន** | សមាជិកក្រុមប្រឹក្សាឃុំត្រពាំងសាប | សមាជិក |
| ៣១. លោកស្រី **កែវ ស៊ីថា** | សមាជិកក្រុមប្រឹក្សាឃុំចំបក់ | សមាជិក |

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវចេញសេចក្ដី

សម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកទាំងអស់នៃគណៈ កម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ខ្លួន ។

ក្រុមប្រឹក្សាមិនមានសមាជិកជាស្ត្រី ត្រូវជ្រើសរើសយកអភិបាលរងជាស្ត្រី ដើម្បីធ្វើជាប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ។

### ខ.២. ភារៈកិច្ចនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ មានភារៈកិច្ចដូចខាងក្រោម :

- ចូលរួមក្នុងការកសាងចក្ខុវិស័យជាយុទ្ធសាស្ត្រ សម្រាប់ការអភិវឌ្ឍនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សានិងដើម្បីធ្វើឲ្យសម្រេចបាននូវសមភាពយេនឌ័រ និងការផ្តល់សេវាផ្សេងៗដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ
- ប្រមូល និងវិភាគព័ត៌មាន និងទិន្នន័យដែលទាក់ទងនឹងយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារ ដើម្បីដាក់បញ្ចូលព័ត៌មានទាំងនេះទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំ រំកិលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដើម្បីបញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិការបស់ក្រុមប្រឹក្សា
- ចូលរួមក្នុងការរៀបចំតាក់តែង ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា ទាក់ទងនឹងការលើកកម្ពស់ និងការឆ្លើយតបលើបញ្ហាសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ
- សហការ និងផ្តល់ការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាប្រភេទផ្សេងៗទៀតក្នុងការដោះស្រាយបញ្ហា ឬសំណូមពរ ឬសំណើរនានាដែលគណៈកម្មាធិការនៃក្រុមប្រឹក្សាប្រភេទផ្សេងនោះមិនអាចដោះស្រាយបានក្នុងការអនុវត្តមុខងាររបស់ខ្លួន
- ស្វែងរក និងទទួលបានព័ត៌មានដែលពាក់ព័ន្ធនិងការងាររបស់គណៈកម្មាធិការ
- ជម្រុញការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយនានា ទាក់ទងនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យនិងកុមារដល់សហគមន៍នានានៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- លើកយោបល់ និងផ្តល់អនុសាសន៍អំពីការពង្រឹងទំនាក់ទំនង កិច្ចសហការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាប្រភេទផ្សេងទៀត មន្ទីរអង្គភាពពាក់ព័ន្ធនឹងនានា អ្នកផ្តល់សេវាអង្គការមិនមែនរាជរដ្ឋាភិបាល ក្រុមអ្នកស្មគ្រ័ចិត្ត និងសហគមន៍ ដើម្បីធានាថាសកម្មភាពទាំងឡាយត្រូវបានគាំទ្រដល់ស្ត្រីយុវវ័យ និង

កុមារ

- រាយការណ៍ជូនក្រុមប្រឹក្សាលើបញ្ហាដែលទាក់ទងនឹងសមភាពយេនឌ័រការបង្កើនសមត្ថភាពដល់ស្ត្រី និង បញ្ហារបស់យុវវ័យ និងកុមារ
- គាំទ្រគ្រប់កិច្ចខិតខំប្រឹងប្រែង ដើម្បីកៀរគរមូលនិធិសំរាប់ការងារសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់ក្រុមប្រឹក្សា។

### គ. គណៈកម្មាធិការលទ្ធកម្ម

យោងតាមមាត្រា១១៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងថាគ្រប់ក្រុមប្រឹក្សារាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ មានកាតកិច្ចបង្កើត គណៈកម្មាធិការលទ្ធកម្ម។[16] ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការលទ្ធកម្មត្រូវកំណត់ដោយប្រកាសអន្តរ ក្រសួងរវាងក្រសួងមហាផ្ទៃនិងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[17]

#### គ.១ សមាសភាព

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវមានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| - អភិបាលក្រុង ស្រុក ខណ្ឌ | ប្រធាន |
| - អភិបាលរក្រុង ស្រុក ខណ្ឌ ០១រូប | អនុប្រធាន |
| - សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌយ៉ាងច្រើន០៣រូប | សមាជិក |
| - នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ | សមាជិក |
| - ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | សមាជិក |
| - ប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក | ខណ្ឌលេខាធិការ |

សមាសភាពអនុប្រធានគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ ត្រូវស្នើដោយអភិបាល ក្រុង ស្រុក ខណ្ឌ។ សមាសភាពនៃគណៈកម្មាធិការលទ្ធកម្មក្រុង ស្រុក ខណ្ឌ ដែលជាសមាជិកក្រុមប្រឹក្សាក្រុង

[16] មាត្រា ១១៤ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០០៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

[17] មាត្រា១៣៧ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០០៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ស្រុក ខណ្ឌត្រូវជ្រើសរើសដោយក្រុមប្រឹក្សាក្រុងស្រុក ខណ្ឌ។[18]

សមាសភាពជាក់ស្តែង ដោយផ្អែកទៅតាមសេចក្តីសម្រេចលេខ ០៦សសរ របស់ប្រធានក្រុមប្រឹក្សាស្រុក ចុះថ្ងៃទី២៧ ខែ សីហា ឆ្នាំ ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិកាលទ្ធកម្មស្រុកបាទី មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក **ភួន ឈឹម** | អភិបាលស្រុក | ប្រធាន |
| ២. លោក **ហ៊ូ វណ្ណៈ** | អភិបាលរងស្រុក | អនុប្រធាន |
| ៣. លោក **សុខ សារ៉ាន់** | សមាជិកក្រុមប្រឹក្សាស្រុក | សមាជិក |
| ៤. លោក **ឡាំង វាសនា** | សមាជិកក្រុមប្រឹក្សាស្រុក | សមាជិក |
| ៥. លោក **វៀម វណ្ណារី** | នាយករដ្ឋបាលសាលាស្រុក | សមាជិក |
| ៦. លោក **ង៉ែត ស្រស់** | ប្រធានការិ.រដ្ឋបាលនិងហិរញ្ញវត្ថុស្រុក | សមាជិក |
| ៧. លោក **ផេ គឹមសាន** | អនុប្រធានអង្គភាពលទ្ធកម្មសាលាស្រុក | លេខាធិការ |

**គ.២ តួនាទី ភារកិច្ច**

គណៈកម្មាធិការលទ្ធកម្មមានសិទ្ធិ និងភារកិច្ចធានាឲ្យសកម្មភាពកិច្ចការលទ្ធកម្មទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រព្រឹត្តទៅឡើងប្រកបដោយភាពស្មោះត្រង់បើកចំហ តម្លាភាព មិនលំអៀងដោយអនុឡោមតាមច្បាប់ បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដើម្បីការពារផលប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន។[19] ដូច្នេះហើយ គណៈកម្មាធិការលទ្ធកម្មបង្កើតឡើងក្នុងគោលបំណង ការពារផលប្រយោជន៍រួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងប្រជាពលរដ្ឋរបស់ខ្លួន។ គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលស្រុកមានភារកិច្ចសំខាន់ៗដូចខាងក្រោម[20]៖

- គោរពឲ្យបានខ្ជាប់ខ្ជួនតាមក្រមសីលធម៌
- ពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដែលរៀបចំដោយអង្គភាពលទ្ធកម្មដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងឯកភាពនឹងផ្ញើរជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ នឹងអនុម័ត។

[18] ប្រកាស ៧ នៃប្រកាសអន្តរក្រសួង លេខ ៣២៤សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋាភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

[19] មាត្រា ១៣៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

[20] ប្រកាស ១២ នៃប្រកាសអន្តរក្រសួង លេខ ៣២៤សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋាភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

- ណែនាំឲ្យអង្គភាពលទ្ធកម្មអនុវត្តឲ្យបានត្រឹមត្រូវតាមផែនការលទ្ធកម្ម
- ប្រជុំវាយតម្លៃកំណត់បុរេលក្ខណៈសម្បត្តិចំពោះកិច្ចលទ្ធកម្មដែលមានលក្ខណៈស្មុគស្មាញ
- ត្រួតពិនិត្យឡើងវិញលើទំហំទឹកប្រាក់នៃកញ្ចប់លទ្ធកម្មនីមួយៗ មុននឹងចាប់ផ្តើមដំណើរការលទ្ធកម្ម
- ត្រួតពិនិត្យនិងផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃដែលស្ថិតក្នុងសិទ្ធិសម្រេចរបស់ខ្លួន
- ប្រជុំបើកសំណើរដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឫចរចាថ្លៃ
- ប្រជុំវាយតម្លៃកិច្ចសន្យា
- ត្រួតពិនិត្យ និងវាយតម្លៃឡើងវិញលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃនាំមុខមុនការសម្រេចប្រគល់កិច្ច-សន្យា
- ជូនដំណឹង ស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅឲ្យអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់
- ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ
- រាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនអំពីដំណើរការកិច្ចលទ្ធកម្មក្នុងកិច្ចប្រជុំសាមញ្ញ ឫវិសាមញ្ញតាមការចាំបាច់ និងការកំណត់របស់ក្រុមប្រឹក្សា
- ផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីរបាយការណ៍នោះត្រូវបានអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួន
- ដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាមសមត្ថកិច្ចរបស់ខ្លួន។

## ផ្នែកទី៣៖ គណៈអភិបាលស្រុកបាទី

### កថាខណ្ឌទី១៖ គណៈអភិបាលស្រុក និងទិសហមជ្ឈការ

ក្រោយពេលច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ បានចូលជាធរមានមកនៅក្នុងបញ្ញត្តិនៃច្បាប់នេះបានកំណត់ឲ្យមានការរៀបចំជាគណៈអភិបាល សម្រាប់ធ្វើការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយក្នុងនោះមានប្រធាន០១រូប ដែលហៅថាអភិបាល និង អភិបាលរងមួយចំនួនទៀត។ ចំណែកឯនៅស្រុកបាទីក៏មានអភិបាលរបស់ខ្លួនចំនួន០១រូប នឹងអភិបាលរងចំនួន០១ផងដែរ។

### ក.សមាសភាព លក្ខខណ្ឌនៃការជ្រើសតាំង និងការបញ្ចប់តួនាទី

#### ក.១.សមាសភាពគណៈអភិបាលស្រុកបាទី

យោងអនុក្រឹត្យលេខ ១៥១ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ចនិងការតែងតាំងមន្ត្រីរាជការចុះថ្ងៃទី១៩ខែមិថុនា

២០១៨ និងប្រកាសលេខ៣៧៦៦ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ចុះថ្ងៃទី០៣ ខែឧសភាឆ្នាំ២០១៦ហើយនិង ប្រកាសលេខ៤៦៩៧ស្តីពីការផ្ទេរភារកិច្ច និងការតែងតាំងមន្ត្រីរាជការចុះថ្ងៃទី៥ខែតុលាឆ្នាំ២០១៧។ដែលមាន សមាសភាពដូចខាងក្រោម:

១. លោក **ភួន ឈឹម** អភិបាលស្រុក ប្រធាន

២. លោក **ជា ណារ៉ម** អភិបាលរងស្រុក អនុប្រធានប្រចាំការ

៣. លោក **ខៀវ សុផល** អភិបាលរងស្រុក អនុប្រធាន

៤. លោក **ហង្ស វិច្ឆិការាស្សី** អភិបាលរងស្រុក អនុប្រធាន

### ក.២ លក្ខខណ្ឌនៃការជ្រើសតាំង និង ការបញ្ចប់តួនាទី នៃគណៈអភិបាល

ដើម្បីទទួលបាននូវមុខតំណែងក្នុងនាមជា អភិបាល អភិបាលរងស្រុក មន្ត្រីរាជការនៅក្នុងក្រសួងមហាផ្ទៃ ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពេញលេញដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ស្រុក ខណ្ឌ ឆ្នាំ ២០០៨ ។

#### a) លក្ខខណ្ឌនៃការជ្រើសតាំងអភិបាលស្រុក

អភិបាលស្រុក ត្រូវធ្វើការជ្រើសរើសក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខខណៈសម្បត្តិ ដូចខាងក្រោម[21]៖

- មានឋានន្តរសក្តិចាប់ពីអនុមន្ត្រីឡើង
- មានអាយុចាប់ពីសាមសិបឆ្នាំ(៣០)ឡើង គិតដល់ថ្ងៃតែងតាំង
- មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំ(០៥)ឆ្នាំឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា
- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

#### b) លក្ខខណ្ឌនៃការជ្រើសតាំងអភិបាលរងស្រុក

អភិបាលរងស្រុកត្រូវធ្វើការជ្រើសរើសក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម[22]៖

---

[21] មាត្រា ១៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

[22] មាត្រា ១៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

- មានឋានន្តរសក្តិចាប់ពីនាយក្រមការឡើង
- មានអាយុចាប់ពីម្ភៃប្រាំ(២៥) ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង
- មានបទពិសោធន៏ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនបី(០៣) ឆ្នាំឬ/និងមានសញ្ញាបត្របរិញ្ញាបត្ររងដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជននិងកីឡា
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយះពេលនៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

c) **ការបញ្ចប់មុខដំណែង**

អភិបាល អភិបាលរង ត្រូវបញ្ចប់មុខតំណែងនៅមុនពេលបញ្ចប់អាណត្តិការងារប្រសិនបើសាមីខ្លួនបានដាក់ពាក្យលាលែងជាលាយលក្ខណ៍អក្សរជូនទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ ត្រូវដកហូតមុខតំណែង។[23]

ប្រសិនបើក្នុងករណីអភិបាល អភិបាលរងណាមួយត្រូវដកហូតពីតំណែងមុនពេលបញ្ចប់អាណត្តិការងារ គឺបណ្តាលមកពីកត្តាមួយចំនួនដូចខាងក្រោមៈ[24]

- បាត់បង់លក្ខណៈសម្បត្តិអភិបាល ឬអភិបាលរង
- អសមត្ថភាព
- បំពេញការងារមិនបានល្អ
- មានបញ្ហាសុខភាព ឬ បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ស្ថាប័នមានសមត្ថកិច្ច
- បោះបង់ចោលការងារ
- ប្រព្រឹត្តខុសឆ្គងពីក្រមសីលធម៌វិជ្ជាជីវៈ។

**ខ. តួនាទី ភារកិច្ចរបស់គណៈអភិបាលស្រុក**

គណៈអភិបាលស្រុកត្រូវធ្វើការសិក្សាស្រាវជ្រាវដើម្បីផ្តល់យោបល់ជូន ក្រុមប្រឹក្សា ស្រុក អំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ ក្រុមប្រឹក្សាស្រុក ដើម្បីក្រុមប្រឹក្សាស្រុកធ្វើការពិភាក្សាអនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញ ទាក់ទងនឹង

- នៅពេលបានទទួលរបាយការណ៍ ឬព័ត៌មាន អំពីការរំលោភអំណាច គណៈអភិបាលស្រុក ត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថាមានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលស្រុកត្រូវធ្វើ

[23] មាត្រា ១៥០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

[24] មាត្រា ១៥១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

សេចក្តីរាយការណ៍ជាបន្ទាន់ទៅក្រុមប្រឹក្សាស្រុក និងធ្វើសេចក្តីរាយការណ៍ ជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្ត ធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អភិបាលស្រុក មានតួនាទីជាតំណាងក្រសួងស្ថាប័ននានា របស់រាជរដ្ឋាភិបាលក្នុងស្រុក។ ក្នុងតួនាទីជា-តំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល អភិបាលស្រុកត្រូវ ៖

- ថែរក្សាសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹង របស់ប្រជាពលរដ្ឋក្នុងស្រុកអំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារ និងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋ ទាំងអស់នៅក្នុងស្រុក
- ធ្វើជាប្រធានគណៈបញ្ជាការឯកភាពស្រុក ក្នុងការដឹកនាំសម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធនានា និងសង្កាត់នៅក្នុងស្រុកដើម្បីធានារក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងស្រុក
- ណែនាំដល់ការិយាល័យអង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដែលប្រចាំនៅស្រុកឱ្យអនុ-វត្តន៍តួនាទី និងភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ស្របតាមច្បាប់ គោលនយោបាយជាតិ។[25]

**គ.វិសហមជ្ឈការនៃគណៈអភិបាលស្រុក**

អភិបាលស្រុកបាទី ត្រូវតែងតាំង ដោយអនុក្រឹត្យតាមសំណើររបស់ក្រសួងមហាផ្ទៃ។ អភិបាលស្រុកជាតំណាងរាជរដ្ឋាភិបាលក្នុងការសម្របសម្រួលសកម្មភាពសេវាសាធារណៈនៅថ្នាក់មូលដ្ឋាន។

វិសហមជ្ឈការ គឺជាការផ្ទេរអំណាចសម្រេចខ្លះទៅឲ្យភ្នាក់ងាររបស់អំណាចកណ្តាល ដែលប្រចាំនៅតាមមណ្ឌលរដ្ឋបាលផ្សេងៗលើផ្ទៃប្រទេស។

វិសហមជ្ឈការ ផ្តល់ទៅឲ្យប្រជាជននូវរដ្ឋបាលមួយ ដែលមិនលំអៀងពីព្រោះវាមិននៅក្រោមឥទ្ធិពលនៃអំណាចមូលដ្ឋាន។ រដ្ឋបាលនេះស្ថិតនៅជិតបញ្ហាមូលដ្ឋានដែលជៀសវាងការបញ្ជូនសំណុំឯកសារមករាជធានី។ លើសពីនេះសកម្មភាពរបស់រដ្ឋអាចធ្វើឡើង ដោយសម្របទៅតាមស្ថានភាពរបស់មូលដ្ឋាន។[26]

ដោយឡែកបើតាមសទ្ធានុក្រមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨ បានឲ្យនិយមន័យថា វិសហមជ្ឈការ ថារាជរដ្ឋាភិបាល ឬក្រសួងស្ថាប័ន ធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធានទៅឲ្យអង្គភាពក្រោមបង្គាប់ ឬ ទៅក្រុមប្រឹក្សាប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តក្នុងនាមរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន។ អង្គភាព ឬ ក្រុមប្រឹក្សា ដែលទទួលបានការធ្វើប្រតិភូកម្មនោះ ត្រូវមាន ភាពចំពោះរាជរដ្ឋាភិ-

[25] សៀវភៅណែនាំស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលស្រុក(ទំព័រទី២៥ដល់ទំព័រទី២៦)

[26] សៀវភៅនីតិរដ្ឋបាលរបស់ សាស្ត្រាចារ្យ យូ តូនី ឆ្នាំ ២០១៩(ទំព័រទី៣៤)

បាល ឬ ក្រសួង ស្ថាប័ន ឲ្យស្របទៅតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។

សរុបសេចក្តីមកវិសហមជ្ឍការ គឺជាការរំលែកអំណាចដែលធ្វើឡើងក្នុងក្របខ័ណ្ឌរដ្ឋបាលកណ្តាលរបស់រដ្ឋមន្ត្រី ឬក្រសួង ស្ថាប័ន អង្គភាព ដែលទទួលបន្ទុកលើកម្រិតផ្សេងៗគ្នាឲ្យទៅអាជ្ញាធរថ្នាក់ក្រោមជាតិ ក្នុងការធ្វើសេចក្តីសម្រេច និងអំណាចក្នុងការចុះហត្ថលេខាកាន់តែច្រើនឡើងៗហើយត្រូវស្ថិតក្រោមការរៀបចំគ្រប់គ្រងដោយរដ្ឋបាលកណ្តាលរបស់រដ្ឋដដែល ។

### គ.១. ចរិតលក្ខណៈ

ក្នុងការគ្រប់គ្រងរដ្ឋបាលតាមបែបវិសហមជ្ឍការ គឺជាការគ្រប់គ្រងតាមឋានានុក្រមរដ្ឋបាល ដែលអំណាចកណ្តាលបានផ្តល់ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមសម្រេចតាមលំដាប់ថ្នាក់រៀងៗខ្លួន។ គ្រប់លំដាប់ថ្នាក់នេះ គឺតាំងតំណាងរបស់អំណាចកណ្តាលដោយគ្មានការបោះឆ្នោតជ្រើសរើសតាំងទេ។ ពោលគឺអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមទាំងនេះ កើតមានឡើងនូវសិទ្ធិក្នុងការសម្រេច គឺអាស្រ័យដោយសប្បុរសធម៌របស់អាជ្ញាធររដ្ឋបាលកណ្តាលប៉ុណ្ណោះ។ ការប្រើប្រាស់ថវិកាវិញ គឺថវិកាជាតិដែលបានផ្តល់ឲ្យដោយអាជ្ញាធររដ្ឋបាលកណ្តាល ដើម្បីបំពេញនូវសេចក្តីត្រូវការរបស់រាជប្រជាស្របតាមដំណើរការប្រព្រឹត្តទៅរបស់រដ្ឋបាលថ្នាក់ក្រោម។ និយាយរួម អាជ្ញាធរថ្នាក់-ក្រោមជាតិ មិនទាន់មានសិទ្ធិក្នុងការទទួលចំណូល ដើម្បីធ្វើការចំណាយដោយខ្លួនឯងទេ។ ប្រសិនបើមានវិញលុះត្រាតែអាជ្ញាធរនៃអំណាចកណ្តាលប្រគល់សិទ្ធិឲ្យ(វិមជ្ឈការហិញ្ញវត្ថុ) ។

ការរំលែកអំណាចកណ្តាលបែងចែកក្នុងការសម្រេច គេប្រើវិធីសាស្ត្រមួយហៅថាប្រតិភូកម្ម។ ប្រតិភូតកម្មចែកចេញជាពីរគឺៈ

- **ប្រតិភូកម្មអំណាច**

ប្រតិភូតកម្មអំណាចគឺជាការផ្ទេរសមត្ថកិច្ចមួយផ្នែកទៅឲ្យអាជ្ញាធររដ្ឋបាលទាំងឡាយនៅក្នុងឋានានុក្រមរដ្ឋបាលរបស់ខ្លួនតែប៉ុណ្ណោះ។ ប្រតិកម្មអំណោចនេះ ធ្វើទៅបានលុះត្រាតែមានលិខិតបទដ្ឋានគតិយុត្តប៉ុណ្ណោះ។ ប្រតិភូកម្មអំណាចនេះ ពុំអាចធ្វើតាមការនឹកឃើញហើយ ក៏ពុំអាចធ្វើទាំងស្រុងដែរ។ ម្យ៉ាងទៀតនីតិវិធីនៃការធ្វើប្រតិភូតកម្មអំណាចនេះ គឺត្រូវផ្សព្វផ្សាយជាសាធារណៈហើយយុទ្ធសាស្ត្រទាមទារ ឱ្យមានការសរសេរជាលាយលក្ខណ៏អក្សរឲ្យបានច្បាស់លាស់។ ពីព្រោះវិបាកនៃប្រតិភូកម្មអំណាចនេះវាជាក់លាក់ណាស់ដូចជាៈ

- វានាំឲ្យផ្ទេរអំណាចមួយផ្នែកយ៉ាងពិតប្រាកដ គឺថាប្រតិភូនាយក(អ្នកផ្ទេរអំណាច)ក្លាយទៅជាអសមត្ថកិច្ចលើផ្នែកដែលបានផ្ទេរហើយអំណរតទៅវាជាសិទ្ធិក្នុងការសម្រេចរបស់ប្រតិភូ(អ្នកទទួលការផ្ទេរអំណាច )។
- សេចក្តីសម្រេចរបស់ប្រតិភូលើផ្នែកដែលបានផ្ទេរមកនេះ គឺមានអានុភាពគតិយុត្តស្មើរថ្នាក់របស់ខ្លួន។

➢ **ប្រតិភូកម្មហត្ថលេខា**

ប្រតិភូកម្មហត្ថលេខា គឺជាវិធីមួយដែលតាមរយៈនេះអាជ្ញាធររដ្ឋបាលនីមួយៗបានប្រគល់ទៅឲ្យ សហការីណាម្នាក់របស់ខ្លួននូវការចុះហត្ថលេខាជំនួស ទៅលើសេចក្ដីសម្រេចខ្លះៗ ដែលនេះជាភាពងាយស្រួលមួយផ្នែកការងារគ្រប់គ្រងរដ្ឋបាល ដោយពុំចាំបាច់ធ្វើប្រតិភូកម្មអំណាចទៀតទេ។ សហការី មិនអាចផ្ទេរការចុះហត្ថលេខាជំនួសនេះទៅឲ្យជនទីបីបានឡើយ។

**គ.២. គុណសម្បត្តិ និង គុណវិបត្តិ**

**១. គុណសម្បត្តិ**

- កាត់បន្ថយការប្រើអំណាចជ្រុលហួសហេតុរបស់អាជ្ញាធរនៃប្រព័ន្ធមជ្ឈការ
- អាជ្ញាធរថ្នាក់ក្រោម សម្រេចបញ្ហានៅនឹងកន្លែងនូវកិច្ចការមួយចំនួនតាមការកំណត់
- ការងារឆាប់រហ័ស ចំណេញពេលវេលា នឹង ការចំណាយ។

**២.គុណវិបត្តិ**

ខ្វះលទ្ធិប្រជាធិបតេយ្យដដែល ព្រោះវិសហមជ្ឈការនេះអាជ្ញាធររដ្ឋបាលកណ្ដាលនៅតែរក្សាអំណាតែងតាំង និង អំណាចាត់ចែងថវិកា។[27]

**កថាខណ្ឌទី២៖ ទំនាក់ទំនងរវាងគណៈអភិបាលស្រុក និងក្រុមប្រឹក្សាស្រុក**

រាល់កិច្ចការងាររបស់ គណៈអភិបាលតែងតែមានទំនាក់ទំនងជាមួយក្រុមប្រឹក្សានៅក្នុងកិច្ចការងាររដ្ឋបាល ហើយក្រុមប្រឹក្សា ក៏តែងតែមានទំនាក់ទំនង ជាមួយគណៈអភិបាលយ៉ាងស្អិត រមួតទាក់ទងទៅនឹងកិច្ចការងារចេញដីកា ឬសេចក្ដីសម្រេច ក្នុងកិច្ចការប្រជុំៗទៀតនៅពេលមានករណីចាំបាច់នឹងបន្ទាន់ណាមួយ។ ទំនាក់ទំនងនេះនិងត្រូវបង្ហាញដូចខាងក្រោម៖

**ក. ទំនាក់ទំនងរវាងគណៈអភិបាលស្រុក និងក្រុមប្រឹក្សាស្រុក**

ទំនាក់ទំនងរវាងគណៈអភិបាលស្រុក និងក្រុមប្រឹក្សាស្រុក មានដូចខាងក្រោម[28]៖

- អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាស្រុកបានសម្រេច ហើយគណៈអភិបាលត្រូវទទួលខុសត្រូវក្នុង ការចាត់ចែងអនុវត្ត ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ ដូច្នេះអភិបាលស្រុកគឺជាអ្នកអនុវត្តន៍ទាំងសេចក្ដីសម្រេចខាងបញ្ញត្តិ និងសេចក្ដីសម្រេចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សាស្រុក។

[27] សៀវភៅ នីតិរដ្ឋបាលទូទៅរបស់សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពលើកទី៥ ឆ្នាំ ២០១៩ (ទំព័រទី១៥៤រហូតដល់១៥៩)
[28] សៀវភៅណែនាំស្ដីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលស្រុក(ទំព័រទី៣៣ដល់ទំព័រទី៣៤)

- ក្រុមប្រឹក្សាស្រុក ត្រូវតាមដាន ត្រួតពិនិត្យ នឹងវាយតម្លៃលើកិច្ចការ ដែលអនុវត្តដោយគណៈអភិបាលស្រុក ដើម្បីធានាថា គណៈអភិបាលស្រុកអនុវត្តកិច្ចការទាំងនោះបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សាស្រុក។
- គណៈអភិបាលស្រុក ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សា។
- គណៈអភិបាលស្រុកត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាអំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាស្រុក និងមានគណនេយ្យភាព ចំពោះរាជរដ្ឋាភិបាលអំពីការ អនុវត្តតាមរដ្ឋធម្មនុញ្ញច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាន គតិយុត្តនានា។
- អភិបាលស្រុក ដោយមាននាយករដ្ឋបាលសាលាស្រុកជាជំនួយការត្រូវធ្វើសេចក្តីរាយការណ៍អំពីសកម្ម-ភាពនិងលទ្ធផលអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័ននានា ព្រមទាំងស្ថានភាពនៃការងារទាំងនោះក្នុងរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាស្រុករបស់ខ្លួន។

**ខ.ទំនាក់ទំនងរវាងគណៈអភិបាល និងក្រុមប្រឹក្សាស្រុក**

ទំនាក់ទំនងរវាងគណៈអភិបាល និងក្រុមប្រឹក្សាស្រុកមានដូចតទៅៈ

- គណៈអភិបាលស្រុក ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាស្រុករបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សាស្រុក ផ្តល់យោបល់ជូនក្រុមប្រឹក្សារាយការណ៍ ជូនក្រុមប្រឹក្សានិងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។ គណៈអភិបាលត្រូវផ្តល់យោបល់ជូន ក្រុមប្រឹក្សារាយការណ៍ជូនក្រុមប្រឹក្សា និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។ គណៈអភិបាល ត្រូវជួយក្រុមប្រឹក្សា ដើម្បីឱ្យក្រុមប្រឹក្សាសម្រេចបាននូវការអនុវត្តមុខងារ សិទ្ធអំណាច និងភារកិច្ចរបស់ខ្លួន ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្តក្រុង ស្រុក ខណ្ឌ។ [29]
- គណៈអភិបាលស្រុក ត្រូវផ្តល់អនុសាសន៍ និងដាក់ជូនក្រុមប្រឹក្សាស្រុកដើម្បី ពិភាក្សាសម្រេចអំពី ៖
    - ការបង្កើត ឬ រំសាយអង្គភាព
    - ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក
    - ការតែងតាំង ការដំឡើងឋានន្តរស័ក្តិ និងការបញ្ឈប់បុគ្គលិក ដោយផ្អែកតាមបទប្បញ្ញត្តិនៃការ

[29] មាត្រា ១៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

គ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សា

- ការកំណត់លក្ខណៈសម្បត្តិនៃការជ្រើសរើស ការតែងតាំងការកំណត់ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗទៀតនៃបុគ្គលិករបស់ក្រុមប្រឹក្សា
- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុ សម្រាប់អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិករបស់ខ្លួន។ [30]

- គណៈអភិបាល ត្រូវលើកសំណើទៅក្រុមប្រឹក្សា ដើម្បីកំណត់អំពីយុទ្ធសាស្ត្រ និងរបៀបនៃការពិគ្រោះយោបល់លើបញ្ហាចាំបាច់ផ្សេងៗរួមទាំងផែនការ អភិវឌ្ឍជាមួយ៖[31]
  - ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
  - ផ្នែកផ្សេងទៀតរបស់ក្រុមប្រឹក្សាដែលអនុវត្តមុខងារ និងភារកិច្ចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
  - ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល
  - ដៃគូពាក់ព័ន្ធដទៃទៀត។
- គណៈអភិបាល ត្រូវពិគ្រោះយោបល់ជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីធានាឲ្យផែនការសកម្មភាព និងថវិការបស់បណ្ដាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលដែលបានផ្ដល់សេវា សម្ភារៈនិងហេដ្ឋារចនាសម្ព័ន្ធ ដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា បានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបី ឆ្នាំរំកិលប្រចាំឆ្នាំព្រមទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។[32]
- អភិបាល និងអភិបាលរងអាចចូលរួមប្រជុំ និងមានសិទ្ធិបញ្ចេញមតិក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាបាន តែមិនអាចធ្វើការបោះឆ្នោតបានឡើយ។[33]
- គណៈអភិបាល ត្រូវធានាឲ្យមានក្ដារបិទផ្សាយពត៌មាន និងមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗតាមតម្រូវការរបស់ក្រុមប្រឹក្សាស្រុករបស់ខ្លួន។ រាល់ឯកសារទាំងអស់ត្រូវបានបោះពុម្ពផ្សាយស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តែត្រូវបិទផ្សាយលើក្ដារព័ត៌មាន ឬ ត្រូវផ្សាព្វផ្សាយតាមមធ្យោបាយ ផ្សេងៗទៀត និងត្រូវធានាថែរក្សាការពារសុវត្ថិភាពក្ដារព័ត៌មាន ក្នុងដែនសមត្ថកិច្ចរបស់ក្រុម

[30] មាត្រា ១៦២ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

[31] មាត្រា ១៦៤ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

[32] មាត្រា ១៦៦ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

[33] មាត្រា ១៤៩ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

ប្រឹក្សាស្រុក។[34]

## ផ្នែកទី៤៖ អង្គភាពចំណុះសាលាស្រុកបាទី

### កថាខណ្ឌទី១៖ នាយករដ្ឋបាល និងនាយករងរដ្ឋបាលសាលាស្រុក

ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុកត្រូវមាននាយករដ្ឋបាលមួយរូប ហៅថានាយករដ្ឋបាលសាលាស្រុក។ នាយករដ្ឋបាលសាលាស្រុក ត្រូវមាននាយករងរដ្ឋបាលយ៉ាងច្រើនពីររូបជាជំនួយការ។[35]

### ក.លក្ខខណ្ឌជ្រើសរើស

ក្រុមប្រឹក្សាស្រុក ត្រូវមាននាយករដ្ឋបាល០១រូបនិងនាយករងរដ្ឋបាលសាលាស្រុករដ្ឋបាលយ៉ាងច្រើន០២រូប ដែលត្រូវបានតែងតាំងដោយក្រសួងមហាផ្ទៃឲ្យបំពេញការងារជាមួយក្រុមប្រឹក្សា។ នាយករដ្ឋបាល និងនាយករងរដ្ឋបាលសាលាស្រុក ត្រូវបានតែងតាំងដោយក្រសួងមហាផ្ទៃ តាមសំណើររបស់អភិបាលស្រុក និងមានការឯកភាពពីក្រុមប្រឹក្សាស្រុក។[36] សាលាស្រុកបាទីមាននាយករដ្ឋបាល ០១រូប គឺលោក **រៀម វណ្ណារី** ។

### ខ.តួនាទី ភារៈកិច្ច

នាយករដ្ឋបាលស្រុកមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ជាជំនួយការរបស់ ក្រុមប្រឹក្សាស្រុកគណៈអភិបាលស្រុក និងអភិបាលស្រុកក្នុងការចាត់ចែងកិច្ចការរដ្ឋ-បាល និងការធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាស្រុក។ ក្នុងតួនាទីនេះនាយករដ្ឋបាលស្រុកត្រូវ

➢ ធ្វើរបាយការណ៍ និងត្រូវមានគណនេយ្យភាពចំពោះគណៈអភិបាលរដ្ឋបាលស្រុក អភិបាលស្រុក និងក្រុមប្រឹក្សារបស់ខ្លួន។

➢ រៀបចំ និងដាក់ជូនគណៈអភិបាលស្រុក ពិនិត្យ សម្រេចនូវកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាស្រុក ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់គណៈអភិបាលស្រុក ហើយត្រូវធានាថាកិច្ចការទាំងនោះត្រូវបានរៀបចំឡើងស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងទម្រង់បែបបទនៃលិខិតស្នាមរដ្ឋបាល

➢ រៀបចំ និងដាក់ជូនគណៈអភិបាលស្រុកនូវវិធាន និងគោលការណ៍ក្នុងការអនុវត្តន៏ដីកា និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាស្រុក

➢ ធ្វើសេនាធិការជូនគណៈអភិបាលស្រុកនិងប្រធានក្រុមប្រឹក្សាស្រុកក្នុងការត្រៀមរៀបចំសេចក្តីព្រាង របៀបវារៈ

---

[34] មាត្រា ១៦៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

[35]សៀវភៅណែនាំស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលស្រុក(ទំព័រទី៥៦)

[36] មាត្រា ១៨៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨

នៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាស្រុករួមទាំងការសម្របសម្រួលក្នុងការរៀបចំឯកសារ និងខ្លឹមសារសម្រាប់របៀបវារៈនីមួយៗនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាស្រុក ស្របតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សារបស់ខ្លួន។ សេចក្តីព្រាងរបៀបវារៈឯកសារ និងខ្លឹមសារទាំងអស់ ដែលនាយករដ្ឋបាលសាលាស្រុកបានរៀបចំសម្រាប់ដាក់ជូននិច្ចប្រជុំក្រុមប្រឹក្សាស្រុក ត្រូវដាក់ជូនគណៈអភិបាលស្រុក ដើម្បីពិនិត្យ និងផ្តល់យោបល់ជាមុន លើកលែងមានការកំណត់ផ្សេងដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

- ធ្វើជាសេនាធិការជូនក្រុមប្រឹក្សាក្នុងការរៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំ ការរៀបចំទីកន្លែងប្រជុំ និងការកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាស្រុក
- ត្រៀមរៀបចំកិច្ចការនានា សម្រាប់បម្រើឲ្យកិច្ចប្រជុំទាំងអស់ របស់គណៈអភិបាលស្រុកតាមការណែនាំរបស់អភិបាលស្រុក
- ធានាក្នុងការទទួល និងបែងចែកលិខិតស្នាម ឯកសារនានាឲ្យបានត្រឹមត្រូវដល់សមាជិកក្រុមប្រឹក្សាស្រុក ព្រមទាំងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ការិយាល័យ និងអ្នកពាក់ព័ន្ធនានា
- គ្រប់គ្រង និងប្រើប្រាស់ត្រារដ្ឋបាលស្រុកឲ្យបានត្រឹមត្រូវ
- ធានារក្សាទុកដាក់ឲ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារ លិខិត បទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុកនិងរដ្ឋបាលរបស់ខ្លួន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក អភិបាលស្រុក អភិបាលស្រុក ឬដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។
    - មានសិទ្ធចូលរួម និងបញ្ចេញយោបល់គ្រប់កិច្ចប្រជុំក្រុមប្រឹក្សាស្រុកកិច្ចប្រជុំគណៈកម្មាធិការ អនុគណៈ-កម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សាស្រុក និងកិច្ចប្រជុំគណៈអភិបាលស្រុក ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ លើកលែងតែនាយករដ្ឋបាលស្រុកជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយរបស់ក្រុមប្រឹក្សា។
    - ក្នុងការចូលរួមប្រជុំ និងការអនុវត្តការងារប្រចាំថ្ងៃ នាយករដ្ឋបាលសាលាស្រុកអាចផ្តល់យោបល់ដល់ក្រុមប្រឹក្សាស្រុក គណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុករបស់ខ្លួនអំពីបញ្ហាច្បាប់និងបច្ចេកទេស ដើម្បីធានាថាសេចក្តីសម្រេច និងសកម្មភាពនានារបស់ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក និងអភិបាលស្រុកមានលក្ខណៈសមស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបទដ្ឋានជាតិសម្រាប់សុវត្ថិភាព និងគុណភាពដែលបានកំណត់ ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងស្រុក។

គណៈអភិបាលស្រុក និងអភិបាលស្រុកអាចធ្វើប្រតិភូកម្ម ដល់នាយករដ្ឋបាលសាលាស្រុក ឲ្យលើកយោបល់លើកិច្ចការណាមួយ ដែលស្ថិតក្នុងវិសាលភាពនៃតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីគណៈអភិបាលស្រុក ឬអភិបាលស្រុកពិនិត្យសម្រេចតាមការចាំបាច់។[37]

**កថាខណ្ឌទី២៖ ការិយាល័យចំណុះសាលាស្រុក**

សាលាស្រុក គឺជាកន្លែងធ្វើការរបស់ក្រុមប្រឹក្សាស្រុក គណៈគម្មាធិការនានា របស់ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក និងបុគ្គលិករដ្ឋបាលស្រុកដែលត្រូវបានរៀបចំជាការិយាល័យនានាហើយត្រូវបើកធ្វើការអោយបានទៀងទាត់ ប្រាំថ្ងៃក្នុងមួយសប្តាហ៍ ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ និងតាមពេលម៉ោងដូចខាងក្រោម[38]៖

- ធ្វើទំនាក់ទំនាក់ និងធ្វើការងារជាមួយក្រុមប្រឹក្សា និងគណៈអភិបាល
- ទទួលព័ត៌មានអំពីសំណើ និងការងារនានាពីរដ្ឋបាលស្រុក
- ចូលរួមយោបល់ ឬសំណូមពរលើបញ្ហាណាមួយ។

នៅចន្លោះម៉ោងធ្វើការ ឬថ្ងៃឈប់សម្រាកជាផ្លូវការ ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុកត្រូវធានាឲ្យមានមន្ត្រី បុគ្គលិកនៃរដ្ឋបាលខ្លួន ក្នុងចំនួនសមស្របប្រចាំការ ដើម្បីទទួលបាន និងដោះស្រាយសំណូមពរបន្ទាន់ពិសេសនានា។ ក្រៅពីការិយាល័យខាងលើគណៈអភិបាលស្រុក អាចស្នើរទៅក្រុមប្រឹក្សាស្រុកដើម្បីបង្កើត ឬកែ-សម្រួលឬរំសាយការិយាល័យណាមួយឬមួយចំនួនតាមការចាំបាច់។ ក្នុងករណីមានតម្រូវការបង្កើតការិយាល័យនោះមិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយការិយាល័យដែលតម្រូវអោយបង្កើតដោយប្រកាសនេះ ។ ផ្អែកតាមការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលស្រុកត្រូវលើកសំណើមកអភិបាលខេត្ត ដើម្បីស្នើរសុំមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពិនិត្យ សម្រេចក្នុងការបង្កើត ឬការរំសាយ ឬការកែសម្រួលការិយាល័យខាងលើនេះ។[39] ចំពោះស្រុកដែលតម្រូឱ្យបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋត្រូវអនុវត្តតាមលិខិតបទដ្ឋានស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យទាំងនេះ។[40] ផ្អែកតាមគោលការណ៍ដូចមានចែងមាត្រា១៧៣ នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០០៩ ស្តីពីតួនាទី ភារកិច្ចនិងទំនាក់ទំនងការងាររបស់

---

[37] សៀវភៅណែនាំស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលស្រុក(ទំព័រទី៥៦ដល់៥៩)

[38] ប្រការ១៤ ក្រសួងមហាផ្ទៃ លេខ០២០.សណន ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការអនុម័តដីកាស្តីពីវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក

[39] ប្រការ២៩ នៃប្រកាសលេខ២៧៤.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះ ទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយានៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ចរបៀបធ្វើការនៃការិយាល័យទាំងនោះ។

[40] ប្រការ២៧ នៃប្រកាសលេខ២៧៤.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះ ទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយានៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ចរបៀបធ្វើការនៃការិយាល័យទាំងនោះ។

ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក សាលាស្រុកនីមួយៗត្រូវមានការិយាល័យចាំបាច់ចំនួនបី ដោយបានបន្ថែមភាពចាំបាច់ពិសេស ប្រឹក្សាស្រុកបាទីបានបង្កើតការិយាល័យចំនួនពីរទៀត គឺការិយាល័យច្រកចេញចូលតែមួយនិងអង្គភាពលទ្ធកម្ម ។

អាស្រ័យហេតុដូចនេះសាលាស្រុកបាទីមានការិយាល័យចំណុះចំនួន ៥ ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- ការិយាល័យផែនការ និងគាំទ្រឃុំ
- ការិយាល័យអន្តរវិស័យ
- ការិយាល័យច្រកចេញចូលតែមួយ និង
- អង្គភាពលទ្ធកម្ម

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធានការិយាល័យមួយ(០១) រូប និងមានអនុប្រធានការិយាមួយ(០១) រូបជាជំនួយការ ដែលត្រូវតែងតាំងឡើងតាមល័ក្ខខណ្ឌចែងក្នុងលក្ខន្តិៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។[41] ការិយាល័យនីមួយៗត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាលសាលាស្រុក ។

### ក. ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុរបស់រដ្ឋបាលស្រុកបាទី ត្រូវបានដឹកនាំដោយប្រធានគ្រប់គ្រងមួយ(០១) រូប និងអនុប្រធានការិយាល័យ (០១) រូប ដែលមានសមាសភាពជាក់ស្ដែងដូចខាងក្រោម៖

១. លោក **ង៉ែត ស្រស់** ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

២. លោក **ប៊ី សុគន្ធា** អនុប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

ការិយាល័យនេះ ជាសេនាធិការឲ្យក្រុមប្រឹក្សា និងគណៈអភិបាលស្រុក លើកិច្ចការដូចខាងក្រោម៖

- ការងាររដ្ឋបាល និងលិខិតស្នាមផ្សេងៗ ទំនាក់ទំនងសាធារណៈ និងការងារពិធីការ
- គ្រប់គ្រង និងថែរក្សាត្រារដ្ឋបាលស្រុកតាមច្បាប់កំណត់
- ការងារស្ថិតិប្រជាពលរដ្ឋ និងការងារអត្រានុកូលដ្ឋាល
- ការងារបុគ្គលិក ក្របខណ្ឌ បៀវត្ស និងកម្រៃផ្សេងៗរបស់មន្ត្រី បុគ្គលិកសាលាស្រុក

[41] ប្រការ២៦ នៃប្រការលេខ២៧៤.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការបង្កើតការិយាល័យចំណុះ ទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយានៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ចរបៀបធ្វើការនៃការិយាល័យទាំងនោះ។

- សហការរៀបចំនីតិវិធីរដ្ឋបាល នីតិហិរញ្ញវត្ថុ និងលក្ខខណ្ឌការងាររបស់មន្ត្រី បុគ្គលិកសាលាស្រុក
- ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពរបស់មន្ត្រី បុគ្គលិកសាលាស្រុក
- សិក្សា និងលើកយោបល់ទៅលើការបង្កើត ការកែសម្រួល និងការរំសាយការិយាល័យចំណុះសាលាស្រុក និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា
- រៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំ ការរៀបចំទីកន្លែងប្រជុំ និងកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សា គណៈអភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា
- ទទួល និងបែងចែកលិខិតស្នាម ឯកសារនានាឲ្យបានត្រឹមត្រូវដល់សមាជិកក្រុមប្រឹក្សា អភិបាល និងអភិបាលរងស្រុក ព្រមទាំងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ការិយាល័យជំនាញ និងអ្នកពាក់ព័ន្ធ
- រក្សាទុកដាក់ឲ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារ លិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សា គណៈអភិបាល និងរដ្ឋបាលស្រុក
- រៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- រៀបចំ និងបិទផ្សាយពត៌មានលើក្តារពត៌មាននិងស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋនៅក្នុងប្រទេសរបស់ខ្លួន
- សហការក្នុងការត្រៀមរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅតាមសាលាឃុំ និងសង្កាត់នានាក្នុងស្រុក
- សិក្សា និងលើកយោបល់ទាក់ទងនិងការពិនិត្យនីត្យានុកូលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ និងសង្កាត់នានាក្នុងស្រុក
- ការងារហិរញ្ញវត្ថុ ថវិកា និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលស្រុក
- គ្រប់គ្រងបេឡារបស់សាលាស្រុក
- សហការត្រួតពិនិត្យ និងទូទាត់រាល់ការចំណាយ
- ការងារលទ្ធកម្ម សវនកម្ម និងរបាយការណ៍ហិរញ្ញវត្ថុរបស់ស្រុក ។

**ខ.ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់**

ការិយាល័យផែនការ និងគាំទ្រឃុំសង្កាត់របស់រដ្ឋបាលស្រុកបាទីត្រូវបានគ្រប់គ្រងដោយប្រធានការិយាល័យមួយ(០១) រូប និងអនុប្រធានការិយាល័យមួយ (០១)រូបដែលមានសមាសភាពជាក់ស្តែងដូចខាងក្រោមគឺ៖

| | |
|---|---|
| ១. កញ្ញា **សំអួល ទិត្យសុគន្ធារី** | ជាប្រធានការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ |
| ២. លោក **ថៅ ប៊ុនធឿន** | ជាអនុប្រធានការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ |

ការិយាល័យនេះគឺជាសេនាធិការឲ្យក្រុមប្រឹក្សា និងគណៈអភិបាលស្រុក លើកិច្ចការដូចខាងក្រោម៖

- សិក្សា និងរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (០៥) ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ស្រុក
- អនុវត្តគម្រោង កម្មវិធីអភិវឌ្ឍ សម្របសម្រួលកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងការផ្តល់សេវារវាងសង្កាត់នានាក្នុងស្រុក
- ជួយដល់ក្រុមប្រឹក្សាឃុំ និងសង្កាត់ ដើម្បីវិភាគវាយតម្លៃដំណើការអភិវឌ្ឍរបស់ឃុំ និងសង្កាត់ក្នុងស្រុក
- សហការគ្រាំទ្រក្រុមប្រឹក្សាឃុំ និងសង្កាត់ ក្នុងការរៀបចំថវិការឃុំ និងសង្កាត់ក្នុងស្រុក
- សហការពិនិត្យ និងលើកអនុសាសន៍ជូនអភិបាលខេត្តអំពីការធ្វើអនុលោមភាពថវិកាឃុំ និងសង្កាត់ក្នុងស្រុក
- សិក្សាវាយតម្លៃ និងលើកយោបល់ពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ និងសង្កាត់ក្នុងស្រុក និងតម្រូវការគាំទ្រ
- ដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ និងសង្កាត់ក្នុងស្រុក
- គាំទ្រដល់ក្រុមប្រឹក្សាឃុំ និងសង្កាត់ក្នុងស្រុក ក្នុងការកសាង និងអនុវត្តផែនការអភិវឌ្ឍន៍របស់ឃុំ និងសង្កាត់ក្នុងស្រុក
- ទំនាក់ទំនង សហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ ស្តីពីការកែសម្រួលទិន្នន័យ ផែនទី សេចក្តីត្រូវការជាអាទិភាពរបស់ស្រុក ឃុំ និងសង្កាត់ក្នុងស្រុក
- បញ្ចូល និងធ្វើបច្ចុប្បន្នភាពទិន្នន័យ ដែលពាក់ព័ន្ធស្រុក ឃុំ និងសង្កាត់ក្នុងស្រុក
- ពិនិត្យរបាយការណ៍អនុវត្តផែនការអភិវឌ្ឍរបស់ស្រុក ឃុំ និងសង្កាត់ក្នុងស្រុក
- កៀរគរធនធានសម្រាប់អភិវឌ្ឍន៍ស្រុក និងគាំទ្រ សង្កាត់ក្នុងស្រុក
- គាំទ្រឃុំ និងសង្កាត់ក្នុងស្រុក ដើម្បីអាចទទួលបាននូវមុខងារ និងធនធានកាន់តែច្រើនឡើង
- ពិនិត្យ និងវាយតម្លៃការប្រើប្រាស់មូលនិធិវិនិយោគស្រុក ឃុំ និងសង្កាត់ក្នុងស្រុក ។

**គ. ការិយាល័យអន្តរវិស័យ**

ការិយាល័យអន្តរវិស័យរបស់រដ្ឋបាលស្រុកបាទី ត្រូវបានគ្រប់គ្រងដោយអនុប្រធានការិយាល័យមួយរូបដែលមានសមាភាពជាក់ស្តែងគឺ លោក **គង់ សំរិទ្ធ** ។ ការិយាល័យនេះ គឺជាសេនាធិការឲ្យក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក លើកិច្ចការដូចខាងក្រោម៖

- សិក្សា និងលើកយោបល់ទៅលើការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រពន្ធ និងធនធានដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែរបានប្រគល់ ឬបានផ្ទេរស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានកំណត់

- ការងារដីធ្លី និងសំណង់ ដែលរួមមានពាក្យសុំកាន់កាប់ដីធ្លី សាងសង់ រុះរើ ជួលជុល កែលម្អ សំណង់នានា
- ការអនុវត្តមុខងារ ភារកិច្ចនានាដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្ម
- ការងារសណ្តាប់ធ្នាប់សាធារណៈ កិច្ចការច្បាប់ និងសិទ្ធិមនុស្ស
- ការងារសម្រុះសម្រួល ផ្សះផ្សាទំនាស់ផ្សេងៗក្នុងដែនសមត្ថកិច្ចរបស់ស្រុក ស្របទៅតាមច្បាប់ និងនីតិវិធីជាធរមាន
- ការងារសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ សាសនា ការការពារបរិស្ថាន ធនធានធម្មជាតិ បេតិកភ័ណ្ឌរមណីយ
- ដ្ឋាន និងតំបន់ប្រវត្តិសាស្ត្រ ដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

**ឃ.ការិយាល័យច្រកចេញចូលតែមួយ**

ការិយាល័យច្រកចេញចូលតែមួយរបស់រដ្ឋបាលស្រុកបាទី ត្រូវបានដឹកនាំគ្រប់គ្រងដោយប្រធានមួយ រូប និងអនុប្រធានមួយរូប ដែលមានសមាសភាពជាក់ស្តែងដូចខាងក្រោម៖

១. លោក **ចាន់ ហេង** ប្រធានការិយាល័យច្រកចេញចូលតែមួយ

២. លោក **សូ ខៃ** អនុប្រធានការិយាល័យច្រកចេញចូលតែមួយ

ការបង្កើតការិយាល័យច្រកចេញចូលតែមួយ ក្នុងគោលបំណងដើម្បីលើកកម្ពស់គោលការណ៍អភិបាលកិច្ចល្អការកែប្រែ ប្រព័ន្ធរដ្ឋបាលដោយពង្រីកវិសាលភាព សេវាកម្មដែលផ្តល់ដោយរដ្ឋបាលស្រុកឲ្យបានទូទូលាយ តាមរយៈការប្រមូលផ្តុំសេវាកម្មដែលផ្តល់ដោយរដ្ឋបាលស្រុកដែលផ្តល់ជូនអតិថិជននៅកន្លែងតែមួយ។ ការិយាល័យច្រកចេញចូលតែមួយ គឺជាការិយាល័យផ្តល់សេវាកម្មដល់ប្រជាពលរដ្ឋ មានគោលដៅបំរើប្រជា-ពលរដ្ឋ អាជីករ ពាណិជ្ជករ ក្រុមហ៊ុន សហគ្រាស និងអង្គការទាំងឡាយដែលកំពុងធ្វើសកម្មភាពក្នុងមូលដ្ឋានស្រុកក្នុងទិសដៅប្រើប្រាស់អោយមានប្រសិទ្ធិភាពនូវធនធានដែលមានស្រាប់នៅថ្នាក់ស្រុកទៅតាមនីតិវិធីរដ្ឋបាលដែលអាចសម្រេចការងារប្រកបដោយប្រសិទ្ធភាព និងមានរយៈពេលខ្លីជាងមុន។[42] កែលម្អការផ្តល់សេវារដ្ឋ បាលកាត់បន្ថយអំពើពុករលួយ និងបង្កើនជំនឿយកចិត្តទុកដាក់ ដល់ប្រជាពលរដ្ឋនៅពេលកំពុងបំរើ សេវារដ្ឋ បាលជូនប្រជាពលរដ្ឋ។

**ង. អង្គភាពលទ្ធកម្ម**

អង្គភាពលទ្ធកម្ម របស់រដ្ឋបាលស្រុកបាទី ត្រូវបានដឹកនាំគ្រប់គ្រង ដោយអនុប្រធានមួយរូប ដែលមានសមាសភាពជាក់ស្តែងកគឺ លោកស្រី **ឆេ គឹមសាង** ។

[42] ប្រការ ០២-០៣ នៃប្រកាសលេខ៩២៨ ប្រក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុក ខណ្ឌគោលដៅ

លក្ខខណ្ឌនៃការតែងតាំងប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវផ្អែកតាមលក្ខន្តិ:ដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រធានអង្គភាពលទ្ធកម្មត្រូវមានលក្ខណៈសម្បត្តិបន្ថែមដូចខាងក្រោម[43]៖

- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាប័ត្រផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុ
- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ច ឬហិរញ្ញវត្ថុយ៉ាងតិច៣ និង
- ធ្លាប់បានឆ្លងកាត់វគ្គបណ្ដុះបណ្ដាលផ្នែកលទ្ធកម្មសាធារណៈដោយមានវិញ្ញាបនប័ត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- អង្គភាពលទ្ធកម្មរបស់រដ្ឋបាលស្រុកបាទី មានភារកិច្ចដូចខាងក្រោម[44]៖
- រៀបចំសេចក្ដីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ និងផែនការលទ្ធកម្មកែតម្រូវក្នុងករណីចាំបាច់
- រៀបចំឯកសារដេញថ្លៃ សម្រាប់ប្រភេទលទ្ធកម្មនីមួយៗ ផ្អែកតាមគំរូឯកសាដេញថ្លៃដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំ និងផ្សព្វផ្សាយសេចក្ដីជូនដំណឹងអំពីលទ្ធកម្មនីមួយៗ
- លក់ ឬផ្ដល់ឯកសារដេញថ្លៃជូនអ្នកមានបំណងចូលរួមក្នុងកិច្ចលទ្ធកម្ម
- ទទួលសំណើដេញថ្លៃ និងបកស្រាយបំភ្លឺចំពោះអ្នកដេញថ្លៃ ក្នុងករណីមានសំណួរពាក់ព័ន្ធ នឹងការដេញថ្លៃ
- រៀបចំទុកដាក់សំណើដេញថ្លៃដែលបានទទួលឲ្យបានត្រឹមត្រូវមានសុវត្ថិភាព និងត្រូវគ្រប់គ្រងឯកសារ ឬលិខិតស្នាមពាក់ព័ន្ធទាំងអស់មុនពេលបើកសំណើដេញថ្លៃ
- ចាត់ចែងរៀបចំទីកន្លែងសម្រាប់បើកសំណើដេញថ្លៃ
- រៀបចំ បើកសំណើដេញជាសាធារណៈដោយមានការដឹកនាំត្រួតពិនិត្យគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ជួយសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ឆ្លើយតបចំពោះសំណួរពាក់ព័ន្ធនឹងរបាយការណ៍វាយតម្លៃលើសំណើដេញថ្លៃ
- ធ្វើសេចក្ដីព្រាងកិច្ចសន្យាឲ្យសមស្របតាមបទដ្ឋានឯកសារកិច្ចសន្យាដែលបានកំណត់

[43] ប្រការ ១៥ នៃប្រកាសអន្តរក្រសួង ស្ដីពី នីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[44] ប្រការ ១៦ នៃប្រកាសអន្តរក្រសួង ស្ដីពី នីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ
- តាមដានការអនុវត្តកិច្ចសន្យា ដោយសហការជាមួយមន្ត្រីបច្ចេកទេស និងមន្ត្រីជំនាញពាក់ព័ន្ធផ្សេងទៀត
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។

# ជំពូកទី ២

# សមិទ្ធផលដែលទទួលបានពីឆ្នាំ ២០១៧ ដល់ ២០១៩

ស្រុកបាទីជាស្រុកមួយក្នុងចំណោមស្រុកទាំង ០៩ និងក្រុង ០១ មានចំងាយ ៤០គ.ម ពីទីរួមខេត្ត ខេត្តតាកែវ មានព្រំ ប្រទល់ខាងកើត ជាប់ស្រុកស្អាង ខេត្តកណ្តាល ខាងលិចជាប់ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ខាងជើងជាប់ស្រុក កណ្តាលស្ទឹង ខេត្តកណ្តាល ខាងត្បូងជាប់ស្រុកព្រៃកប្បាស និងសំរោង ។ ស្រុកបាទីមានឃុំចំនួន ១៥ ភូមិមានចំនួន ១៦៨ មានផ្ទៃដីចំនួន៣៩៦ គីឡូម៉ែតការ៉េ ផ្ទៃដីសរុប ៣០,៨៧៦.៣៨ ហិកតា ដីលំនៅដ្ឋាន ៣,៤៤០.១៧ ហិកតា មានប្រជាជនសរុបចំនួន ១៥៤,១៨២ នាក់ក្នុងនោះមានស្រីចំនួន ៨០,២១៨ នាក់(កម្មវិធី-វិនិយោគបីឆ្នាំរំកិលស្រុកបាទី២០១៦)។

ដោយមានការកែទម្រង់ជាបន្តបន្ទាប់ក្នុងរយៈពេល៣ឆ្នាំនេះ (២០១៧ ដល់ ២០១៩) ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងការដឹកនាំផ្ទាល់របស់អភិបាលនៃគណៈអភិបាលក្រុមប្រឹក្សា និងបណ្តាដៃគូសហការមានអង្គការរាជរដ្ឋាភិបាល អង្គការក្រៅរាជរដ្ឋាភិបាល ក្នុងការជម្រុញឲ្យមានការអភិវឌ្ឍបាននូវសមិទ្ធផល ក្នុងវិស័យ សំខាន់ៗ ជាច្រើនពិសេស ក្នុងវិស័យ សេដ្ឋកិច្ច វិស័យសង្គមកិច្ច វិស័យរដ្ឋាបាលសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងការរៀបដែនដីនគរូនីយកម្ម និងសំណង់។ សមិទ្ធផលដែលសម្រេចបានទាំងនោះនឹងរៀបរាប់បង្ហាញដូចខាង ក្រោម ៖

## ផ្នែកទី១៖ សមិទ្ធផលដែលសម្រេចបានក្នុងវិស័យសំខាន់ក្នុងឆ្នាំ ២០១៧

យោងតាមរបាយការណ៍ប្រចាំឆ្នាំ ២០១៧ ស្តីពីការអនុវត្តការងាររដ្ឋបាលស្រុកបាទី គឺបានបរិយាអំពីសមិទ្ធផល ការងារប្រចាំឆ្នាំទី៥ នៃអាណត្តិទី១របស់ក្រុមប្រឹក្សាដើម្បីឆ្លើយតបនូវគោលដៅអភិវឌ្ឍន៍រយៈពេល០៥ឆ្នាំ (២០១៥ ដល់ ២០១៩) តាមការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល។ សមិទ្ធផលទាំងនោះមានដូចខាងក្រោម៖

### កថាខណ្ឌទី១៖ លទ្ធផលការងាររដ្ឋបាល និងសន្តិសុខសង្គម

#### ក. ការងាររដ្ឋបាលដែលសម្រេចបាន

នៅក្នុងសមិទ្ធផលការងាររដ្ឋបាលរបស់ស្រុកបាទី និងរដ្ឋបាលឃុំនៃដែនសមត្ថកិច្ចរបស់ខ្លួន គឺទទួលបាននូវលទ្ធផលនៅ ក្នុងចំនុចសំខាន់ៗរួមមាន ការងារផ្តល់អត្រានុកូលដ្ឋាន ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះបោះឆ្នោតសកម្មភាពសេវាសង្គម និងការសម្រុះសម្រួលទំនាស់។ លទ្ធផលទាំងនោះដោយមានការខិតខំប្រឹងប្រែងរបស់សមាជិកគ្រប់ជាន់ថ្នាក់របស់ស្រុកបាទីមានដូចជា៖

**ក.១. លទ្ធផលការងារអត្រានុកូលដ្ឋាន**

- លទ្ធផលការងារអត្រានុកូលដ្ឋានរួមមាន៖

- សេចក្តីចម្លងសំបុត្រកំណើតចំនួន ៥២
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតចំនួន១០៤០
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ចំនួន ៤៦
- សេចក្តីចម្លងសំបុត្រមរណភាពចំនួន ១៤
- សំបុត្រកំណើតចំនួន ៣៣២
- សំបុត្រអាពាហ៍ពិពាហ៍ចំនួន ៥៣
- សំបុត្រមរណភាពចំនួន ១១៦
- សំបុត្របញ្ជាក់កំណើតចំនួន ៣៦៨។[45]

**ក.២. ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត**

- ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មី (គ្មាន)
- ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត (គ្មាន)
- ប្រជាពលរដ្ឋសរុបមានឈ្មោះបោះឆ្នោត (ចាស់ និងថ្មី) ៩៣,៣២២។[46]

**ក.៣. សកម្មភាពសេវាសង្គម និងការសម្រុះសម្រួលទំនាស់**

- មត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការងារដែលគាំទ្រពីឃុំ សង្កាត់ ១៤
- គ្រួសារងាយរងគ្រោះគាំទ្រពីឃុំសង្កាត់សម្រាប់កែសម្រាប់កែលម្អអនាម័យ(ការលាងដៃនឹងសាប៊ូ) ៩៩១
- គ្រួសារងាយរងគ្រោះគ្រាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់
- គ្រួសារងាររងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានបង្គន់អនាម័យប្រើប្រាស់
- គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ចុះកំណត់អត្តសញ្ញាណ
- ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែលទទួលបានការគាំទ្រពីឃុំ សង្កាត់
- ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយឃុំ សង្កាត់ ១៧
- ករណីដែលបានបញ្ជូលទៅស្ថាប័នពាក់ព័ន្ធ។[47]

[45] មាននៅទំព័រ ០២ និង ០៩ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៧

[46] មាននៅទំព័រ ០៩ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៧

[47] មាននៅទំព័រ ០៨ និង ០៩ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៧

**ខ. ការងារសន្តិសុខសណ្តាប់សាធារណៈ**

លទ្ធផលដែលទទួលបានពីការខិតខំប្រឹងប្រែងដោយយកចិត្តទុកដាក់ របស់ថ្នាក់ដឹកនាំគ្រប់ជំនាញគ្រប់ជាន់ថ្នាក់ និងចូលរួម សហការប្រជាពលរដ្ឋ ផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនៃស្រុកបាទីបានចូលរួមដើម្បីបង្រ្កាបបទល្មើសទាំងយប់ទាំងថ្ងៃបាន ទទួលលទ្ធផលដូចខាងក្រោម៖[48]

- **គ្រោះថ្នាក់ចរាចណ៍**៖ កើតមាន ៥០ លើ
  - ស្លាប ៣៨ នាក់ ប្រុស ២៣ នាក់
  - របួសធ្ងន់ ៤៦ នាក់ ស្រី១៣ នាក់
  - របួសស្រាល ២៦ នាក់ ស្រី ៦ នាក់
  - រថយន្តខូចខាតធ្ងន់ ១៦ គ្រឿង
  - រថយន្តខូចខាតស្រាល ២៩ គ្រឿង
  - ម៉ូតូខូចខាតធ្ងន់ ៤៨ គ្រឿង
  - កង់ខូចខាតស្រាល ០១ គ្រឿង
- **សកម្មភាពបទល្មើស**
  - បទល្មើសមជ្ឈិម ១៩ ករណី
  - បទល្មើសគ្រឿងញៀន ៣២ ករណី
  - បទល្មើសលហុ ៣៥ ករណី
- **ការងារកងរាជអាវុធហត្ថស្រុក**
  - សណ្តាប់ធ្នាប់៖ កំលាំងកងរាជអាវុធហត្ថស្រុកបានជួយរៀបចំសណ្តាប់ធ្នាប់ទីប្រជុំជន និងសម្រួលចរាចរភ្ញៀវទេសចណ៍ជាតិ និងអន្តរជាតិ ឆ្លងកាត់ ។
  - ការងារបង្ការ៖ កងកម្លាំងបានល្បាតតាមចំណុចភូមិសាស្ត្រ ។

**កថាខណ្ឌទី២៖ លទ្ធផលទទួលបានក្នុងវិស័យអភិវឌ្ឍន៍ជនបទ និងរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាល**

សាលាស្រុកបាទី បានសម្រេចសមិទ្ធផលជាច្រើនក្នុងវិស័យអភិវឌ្ឍន៍ជនបទ និងរៀបចំដែនដីនគររូបនីយកម្មសំណង់ និងភូមិបាលដែលរួមមាន ការងារអភិវឌ្ឍស្រុក ការងារធនធានធម្មជាតិ ហើយត្រូវបង្ហាញដូចខាង

[48] មាននៅទំព័រ ១៨ និង ១៩ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៧

ក្រោម៖[49]

**ក. លទ្ធផលការងារនៃការអភិវឌ្ឍស្រុក**

លទ្ធផលការងារនៃការអភិវឌ្ឍស្រុក គឺជាកិច្ចការសំខាន់ផងដែរ ហើយការងារទាំងនោះទទួលបានជោគជ័យ និងធ្វើឱ្យកាន់តែមានភាពទាក់ទាញបន្ថែមទៀត ក្នុងនោះរួមមានការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្រុកបាទីទាំងមូលមានភាពល្អប្រសើរ មានការរីកចម្រើន និងមានអភិវឌ្ឍន៍ជាច្រើនទៀតដែលមានដូចខាងក្រោម៖

- គណៈកម្មការថៃទាំផ្លូវ និងប្រជាពលរដ្ឋបានជួសជុលផ្លូវ ចាក់ថ្មពុក និងថ្មផេះ ផ្លូវភូមិ ចេក ផ្លូវភូមិដូង ផ្លូវចូលវត្តប្រាសាទ និងផ្លូវភូមិយុថ្កា ភូមិតានប្រវែងសរុប ៧៩០០ម ថវិកា ៣៣,៦៣០,០០០រៀល។
- ជួសជុលផ្លូវក្រាលគ្រួសក្រហមបាន៣ខ្សែ ២,៥៥០ម៉ែត្រ នៅភូមិទន្លេបាទី និងភូមិហនុមាណ
- បានជួលជុលផ្លូវលំដីសប្រវែង ៩០០ម ថវិកាប្រជាពលរដ្ឋ និងសប្បុរសជន
- បានស្ដាប្រឡាយប្រវែង ៧៥០ម អស់ថវិកា $ ៥,០០០ ចលនាភូមិថ្មី
- របងស្រះទឹក ភូមិក្រាំងធ្នង់ ២៤០ម ថវិកា $ ២០០០
- ដាក់លូកាត់ផ្លូវមុខកាត់ ០.៦មចំនួន ១០កង់ អស់ថវិកា $ ៧៤៥ ចលនាភូមិថ្មី
- ជួសជុលផ្លូវក្រាលគ្រួសភូមិថ្នល់ទក្សិណប្រវែង២,០០០ម៉ែត្រ តម្លៃគម្រោង៩៤,៧១១,០០០រៀលថវិកាមូលនិធិឃុំ។
- ជួយជីកអណ្ដូងបាន ១០អណ្ដូង ស្រះទឹកបាន ៣កន្លែងអស់ថវិកា ២៦,៥០០ដុល្លារ ជាអំណោយអង្គការស្ពានកម្ពុជាហូឡង់។
- ជួយដាក់លូកាត់ផ្លូវ ១៥កន្លែង អស់ថវិកា ៦២៦១ដុល្លារ អង្គការស្ពាន
- ជួសជុលផ្លូវដីស០១ខ្សែប្រវែង២៩៥០ម៉ែត្រភូមិត្រាំត្បាល់និងភូមិត្រពាំងអង្គមានទឹកប្រាក់ចំនួន ៩៣,៣៥៧,០០០៛។
- ជួសជុលផ្លូវខាងលិច និងខាងកើតវត្តដីក្រហម ប្រវែងសរុប ៣១៥០ម៉ែត្រ ថវិកា ៤,២២០,០០០រៀលជាថវិកាអ៊ែអង្គាសសហគមន៍ ។
- បានស្ដាប្រឡាយ ២ខ្សែ ប្រវែង ១៧៥៧ម៉ែត្រ អស់ថវិកា ១៦២,៧៤០,៤៥៧រៀល
- ចាកបេតុងផ្លូវភូមិចំបក់ប្រវែង ៣៥០ម៉ែត្រអស់ថវិកា ១២៧,២១៦,៣៤៦រៀលមូលនិធិឃុំ ឆ្នាំ ២០១៦

[49] មាននៅទំព័រ ១៩ និង ២៥ នៃរបាយការណ៍ស្ដីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៧

- អង្គការសូសលវ៉ែលហ្វែខបឃែលរិនហ្គាំម ជួយសាងសង់ផ្ទះ ២ខ្នងទំហំ ៤×៥ម៉ែត្រនៅភូមិចំបក់អស់ថវិកា ២៥០០ដុល្លារ ។
- អង្គការស្ពានកម្ពុជាហូឡង់បានជួយស្ថាប្រឡាយ០១ខ្សែប្រវែង ១,៦៦០ម៉ែត្រ
- ប្រឡាយ ១ខ្សែប្រវែង ១៣៩៥ម៉ែត្រ ដាក់លូទោល ២កន្លែងអស់ថវិកា ៥៨,១៤០,០០០រៀល។
- បានដាំកូនឈើគ្រប់ប្រភេទតាមទីសាធារណៈចំនួន ២០០ដើម
- បានជួសជុលផ្លូវលំក្រាលគ្រួសក្រហមប្រវែង ៨៥០ម៉ែត្រ នៅភូមិក្រាំងធំ ភូមិថ្មសរ ត្រពាំក្រលោង ឃុំលំពង់អស់ថវិកា ៣.៤៦៥.០០០៛ ។
- ស្តារស្រះទឹកភូមិកញ្ចាង ១កន្លែងអស់ថវិកា ១២,៦០០,០០០រៀល មូលនិធិឃុំ
- ជួសជុលផ្លូវក្រាលគ្រួសធម្មជាតិប្រវែង ៥៤៦ ម៉ែត្រ លូ២កន្លែង អស់ថវិកា ៣៤,២៥១,០០០រៀល
- ជួយដាក់លូ ១កន្លែងនៅតាមភូមិ ឱភាសាំង អស់ថវិកា ៨០០,០០០រៀល ឧបត្ថម្ភដោយ ឯឧត្តម ជាបសត្ថារតន៍ ក្រុមការងារថ្នាក់ជាតិ ចុះជួយឃុំកណ្តឹង។
- ជួសជុលផ្លូវដីស ១ខ្សែវែង ១,២០០ម៉ែត្រ អស់ថវិកា ៤,១០០,០០០រៀល ថវិកាចូលរួមរបស់ប្រជាជន និងសប្បុរសជន

**ខ. ការរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាល**

ការរៀចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាល បានលទទួលលទ្ធផលដូចខាងក្រោមៈ[50]

- បាលចូលរួមសម្របសម្រួលវិវាទដីប្រជាពលរដ្ឋនៅឃុំត្រពាំងលាន ឃុំចំបក់ ១លើក
- ចុះពិនិត្យសំណង់ និងណែនាំឲ្យសុំច្បាប់អនុញ្ញាតសាងសង់ ២លើក
- បានសហការជាមួយក្រសួងទំនាក់ទនង រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចចុះពនិត្យសំណង់ស្ថានីយប្រេងឥន្ទនៈ និងរោងចក្រក្នុងស្រុកបាទីរយៈពេល ២លើក
- ចុះត្រួតពិនិត្យសំណង់ចំនួន ៩លើក
- ទទួលពាក្យសាងសង់ចំនួន ៨លើក
- ផ្ទេរសិទ្ធកាន់កាប់ដីៈ
  - ❖ លក់ផ្តាច់ ចំនួន ៣៦៣ ក្បាលដី
  - ❖ លក់បំបែក ចំនួន ២៩១ ក្បាលដី

[50] មាននៅទំព័រ ១៦ នៃរបាយការណ៍ស្តីពី ការអនុវត្តន៏ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៧

- ❖ អំណោយបំបែក ៦៤ ក្បាលដី
- ❖ អំណោយផ្តាច់ ២២ ក្បាលដី
- ❖ ចុះបញ្ជីបន្ថែម ចំនួន ១៤ ក្បាលដី

## កថាខណ្ឌទី៣៖ លទ្ធផលការងារក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

### ក. ការសម្រេចបានការងារក្នុងវិស័យសេដ្ឋកិច្ច

នៅក្នុងរយៈពេលមួយឆ្នាំនេះការសម្រេចបានការងារខាងវិស័យសេដ្ឋកិច្ច គឺជាវិស័យសំខាន់បំផុត ដែលថ្នាក់ដឹកនាំ និងដៃគូសហការទាំងអស់បានយកចិត្តទុកដាក់លើគ្រប់វិស័យ ។ លទ្ធផលលើវិស័យទាំងនោះមាន ការងារការិយាល័យធនធានទឹក និងការងារការិយាល័យសាធារណៈការណ៍ និងដឹកជញ្ជូន ។ ការងារទាំងអស់នឹងអធិប្បាយដូចខាងក្រោម៖

#### ក.១. ការងារការិយាល័យធនធានទឹក

- ក្រសួងធនធានទឹក និងឧត្តុនិយម បានស្តាប្រឡាយដើមកោះប្រវែង ៥០០០ម៉ែត្រ សង់ស្ពានកាត់ផ្លូវ ៥កន្លែង និងសំណង់ទ្វារទឹក៤កន្លែង
- គណៈកម្មការរៀបចំប្រព័ន្ធអាង ស្ទឹង ទន្លេមេគង បានចុះសិក្សាអាងទឹកទន្លេបាទី ១លើក
- ទំនាក់ទំនងជាមួយការិយាល័យធនធានទឹក ស្រុកកណ្តាលស្ទឹង បើកទឹកចូលអាងទន្លេបាទី ៣លើក
- ចុះពិនិត្យការស្តាប្រឡាយនៅភូមិគ្រួស ឃុំពារាម ១លើកចុះពិនិត្យបោះបង្គោលទីតាំងគម្រោងប្រឡាយបេតុង ៤ខ្សែ នៅឃុំត្នោត និងឃុំដូង ដែលអនុវត្តដោយអង្គការកាវ៉ាក់។[51]

#### ក.២. ការងារការិយាល័យសាធារណៈការ និងដឹកជញ្ជូន

- មន្ត្រីការិយាល័យបានចុះពិនិត្យផ្លូវ ស្ពាន លូ បង្គោលសញ្ញា ស្លាកសញ្ញា និងបង្គោលគីឡូម៉ែត្រ តាមគោលដៅក្នុងស្រុកបាទីបានចំនួន ៣គោលដៅធំៗ ស្មើ ៣៤លើក
- បានចុះកាបឆ្កាព្រៃតាមបណ្តោយផ្លូវជាតិលេខ២ប្រវែង ១៤,៤០០ម លើក
- ចុះ ទំនាក់ទំនងជាមួយក្រុមហ៊ុន អគ្គីសនីក្រុមហ៊ុនខ្សែកាបអុបទិក ក្រុមហ៊ុនអង់តែនទូរស័ព្ទដើម្បីរុះរើបណ្តាញចែកចាយ ដែលប៉ះពាល់ការងារការពង្រីកចញ្ចើមផ្លូវ និងឆ្កាព្រៃចំនួន ១លើក
- មន្ត្រីការិយាល័យ ចូលរួមជាមួយលោកប្រធានការិយាល័យសាធារណៈការនិងដឹកជញ្ជូនខេត្តនិងសហការជាមួយមេឃុំ ចុះឃាត់និងណែនាំ ក្រុមហ៊ុនដឹកជញ្ជូនដីមិនគ្រប់ចំនួន ២លើក។[52]

---

[51] មាននៅទំព័រ ១០ និង ១១ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៧

[52] មាននៅទំព័រ ១៧ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៧

## ខ. ការសម្រេចបានការងារសង្គមកិច្ច និងវប្បធម៌

ក្រោមការប្រឹងប្រែងគ្រប់គ្រង របស់ថ្នាក់ដឹកនាំគ្រប់ថ្នាក់ទាំងអស់លទ្ធផលសម្រេចបានក្នុងកិច្ចការងារសង្គមកិច្ចនិងវប្បធម៌ក្នុងឆ្នាំ២០១៧ រួមមានការងារការិយាល័យកិច្ចការនារី ការងារការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ ការងារការិយាល័យធម្មការ និងសាសនា ។

### ខ.១. ការងារការិយាល័យកិច្ចការនារី

- បើកកិច្ចប្រជុំ គ.ក.ន.ក បាន១១លើក
- ចូលរួមប្រជុំជាមួយ គ.ក.ន.ក បានចំនួន ៤៣លើក
- បានបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាល នៅថ្នាក់ខេត្តបាន ៧លើក
- បានចូលរួមកម្មវិធីការផ្តល់ទុនលើកទី ៣ របស់គម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ចគ្រួសារ ១លើក
- បានចូលប្រជុំប្រចាំឆមាសនៃគម្រោង PADEE នៅខេត្តព្រះស៊ីហនុ ១លើក
- មន្ទីរកិច្ចការនារីខេត្តបានបើកវេទិកាផ្សព្វផ្សាយ អនុសញ្ញាស្តីពី ការលុបបំបាត់គម្រង់ នៃការរើសអើងប្រឆាំងនារីភេទ នៅឃុំកណ្តឹង ១លើក។[53]

### ខ.២. ការងាការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ

- បានចូលរួមប្រជុំរៀបចំសណ្តាប់ធ្នាប់ជូនភ្ញៀវអន្តរជាតិទស្សនា ប្រាសាទតាព្រហ្ម ១១លើក
- ប្រចាំការរៀបចំសណ្តាប់ធ្នាប់នៅប្រសាទតាព្រហ្ម ក្នុងឱកាសបុណ្យជាតិ ២លើក
- បានជួសជុលរបងប្រាសាទតាព្រហ្ម ដោយប្រើប្រាស់ថវិកាមូលនិធិទ្រទ្រង់ប្រាសាទ ១លើក
- នាយកដ្ឋានបុរាណវិទូបានជួសជុលប្រាសាទតាព្រហ្មទន្លេបាទី និងភ្នំថ្មដុះ ១លើក។[54]

### ខ.៣. ការងារការិយាល័យធម្មការ និងសាសនា

- ចូលរួមកម្មវិធីអនាម័យ បរិស្ថាន ៤លើក
- ចូលរួមជាអនុរក្ស ប្រលងវិញ្ញាសាបនប័ត្រពុទ្ធិកបឋមសិក្សា នៅវត្តឈើទាល ១លើក
- ចូលរួមពិនិត្យវាយតម្លៃគុណភាពព្រះវិហារ វត្តឃ្លាំងមឿង ២លើក
- ចូលរួមវគ្គបណ្តុះបណ្តាលអាចារ្យខ្មែរ នៅវត្តប្រាសាទនាងខ្មៅ ១លើក

[53] មាននៅទំព័រ ១១ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៧

[54] មាននៅទំព័រ ១១ និង ១២ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៧

- ចុះពិនិត្យសណ្តាប់ធ្នាប់តាមវត្តត្រៀមរៀបចំបុណ្យចូលឆ្នាំខ្មែរ ១លើក។[55]

## ផ្នែកទី២៖ សមិទ្ធផលដែលសម្រេចបានក្នុងវិស័យសំខាន់ក្នុងឆ្នាំ ២០១៨

យោងតាមរបាយការណ៍ប្រចាំឆ្នាំ ២០១៨ ស្តីពីការអនុវត្តការងាររដ្ឋបាលស្រុកបាទី គឺបានបរិយាអំពីសមិទ្ធផលការងារប្រចាំឆ្នាំទី៥ នៃអាណត្តិទី១របស់ក្រុមប្រឹក្សាដើម្បីឆ្លើយតបនូវគោលដៅអភិវឌ្ឍន៍រយៈពេល ០៥ឆ្នាំ (២០១៥ ដល់ ២០១៩) តាមការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល។ សមិទ្ធផលទាំងនោះមានដូចខាងក្រោម៖

### កថាខណ្ឌទី១៖ លទ្ធផលការងាររដ្ឋបាល និងសន្តិសុខសង្គម

#### ក. ការងាររដ្ឋបាលដែលសម្រេចបាន

នៅក្នុងសមិទ្ធផលការងាររដ្ឋបាលរបស់ស្រុកបាទី និងរដ្ឋបាលឃុំនៃដែនសមត្ថកិច្ចរបស់ខ្លួនគឺទទួលបាននូវលទ្ធផលនៅក្នុងចំនុចសំខាន់ៗ រួមមានការងារផ្តល់អត្រានុកូលដ្ឋានការចុះឈ្មោះ និងការពិនិយត្យបញ្ជីឈ្មោះបោះឆ្នោតសកម្មភាពសេវាសង្គមនិងការសម្រុះសម្រួលទំនាស់។ លទ្ធផលទាំងនោះដោយមានការខិតខំប្រឹងប្រែងរបស់សមាជិកគ្រប់ជាន់ថ្នាក់របស់ស្រុកបាទី ដោយមានការតាំងចិត្តបំពេញនូវភារកិច្ច ការផ្តល់សេវាអោយមានភាពរលូន និងឆាប់រហ័ស ក្នុងនោះដែររួមមានដូចជា៖

##### ក.១.លទ្ធផលការងារអត្រានុកូលដ្ឋាន

លទ្ធផលការងារអត្រានុកូលដ្ឋានរួមមាន៖

- សំបុត្រកំណើត ៤៩១
- សំបុត្របញ្ជាក់កំណើត ៥០៥
- សេចក្តីចម្លងសំបុត្រកំណើត ៣៣៣
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ៩០
- សំបុត្រអាពាហ៍ពិពាហ៍ ១២៦សំបុត្រកំ
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ៥៥
- សំបុត្រមរណភាព ១៨៦
- សេចក្តីចម្លងសំបុត្រមរណភាព ៦៧។[56]

##### ក.២. ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត

- ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មី ( គ្មាន )

---

[55] មាននៅទំព័រ ១៥ និង ១៦ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៧

[56] មាននៅទំព័រ ០២ និង ០៩ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៨

- ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ( គ្មាន )
- ប្រជាពលរដ្ឋសរុបដែលមានឈ្មោះបោះឆ្នោត (ចាស់ និងថ្មី) ៩៩,០៣៩។[57]

**ក.៣. សកម្មភាពសេវាសង្គម និងការសម្រុះសម្រួលទំនាស់**

- មត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការដែលគាំទ្រពីឃុំ សង្កាត់ ១៦
- គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់សម្រាប់កែលម្អអនាម័យ(ការលាងដៃនឹងសាប៊ូ)
- គ្រួសារងាយរងគ្រោះគ្រាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់
- គ្រួសារងាយរងគ្រោះគ្រាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានបង្គន់អនាម័យប្រើប្រាស់
- គ្រួសារងាយរងគ្រោះដែលឃុំ សង្កាត់ចុះកំណត់អត្តសញ្ញាណ
- ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារសែលទទួលការគ្រាំទ្រពីឃុំ សង្កាត់
- ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយឃុំ សង្កាត់ ២១៦
- ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ ២២។[58]

**ខ. ការខារសន្តិសុខសណ្តាប់សាធារណៈ**

លទ្ធផលដែលទទួលបានពីការខិតខំប្រឹងប្រែងដោយយកចិត្តទុកដាក់ របស់ថ្នាក់ដឹកនាំគ្រប់ជំនាញគ្រប់ជាន់ថ្នាក់ និងចូលរួមសហការប្រជាពលរដ្ឋ ផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនៃស្រុបាទីបានចូលរួមដើម្បីបង្ក្រាបបទល្មើសទាំងយប់ទាំងថ្ងៃបានទទួលលទ្ធផលដូចខាងក្រោម៖[59]

**១. គ្រោះថ្នាក់ចរាចរណ៍៖** កើតមាន ៣៧លើកៈ ក្នុងនោះឃុំត្រពាំងសាប ៧លើក ក្រាំលាវ ២លើក កណ្តឹង៥លើក តាំងដូង ១លើក កុមាររាជា ៣លើក ក្រាំងធ្នង់ ៣លើក សូភី ១១លើក លំពង់ ១លើក ចំបក់ ១លើក និងពត់សរ ៣លើក ។

➢ **ករណី៖**

- ស្លាប់ ២២នាក់ ស្រី ១នាក់
- របួសធ្ងន់ ៤០នាក់ ស្រី ៤នាក់
- របួសស្រាល ៣៤នាក់ ស្រី ២៤នាក់
- រថយន្តខូចខាតធ្ងន់ ១៣គ្រឿង

[57] មាននៅទំព័រ ០៩ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៨

[58] មាននៅទំព័រ ០៨ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៨

[59] មាននៅទំព័រ ២៦ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៨

- រថយន្តខូចខាតស្រាល ១២គ្រឿង
- ម៉ូតូខូចខាតធ្ងន់ ៣៦គ្រឿង
- ម៉ូតូខូចខាតស្រាស ៨គ្រឿង
- កង់ខូចខាតស្រាល ១គ្រឿង

**២.ការងារ សភាពការសន្តិសុខសណ្តាប់សង្គម**

- បទល្មើសមជ្ឈឹម ៣១ករណី
- បទល្មើសឧក្រិដ្ឋ ១១ករណី
- បទល្មើសគ្រឿងញៀន(ចែកចាយ និងប្រើប្រាស់ ១៤លើក)
- កម្លាំងនៃអធិការដ្ឋា បានសហការជាមួយជាមួយកម្លាំងប៉ុស្តិ៍នគរបាលទាំង ១៥ឃុំ ចុះដើរល្បាតតាមចំណុចសំខាន់ៗ និងជាទីប្រជុំជននានាពិសេសតាមផ្សារសំរោងយ៉ោង និងត្រាំខ្នារ ។

## កថាខណ្ឌទី២៖ លទ្ធផលទទួលបានក្នុងវិស័យអភិវឌ្ឍន៍ជនបទ និងរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាល

សាលាស្រុកបាទី បានសម្រេចសមិទ្ធផលជាច្រើនក្នុងវិស័យអភិវឌ្ឍន៍ជនបទ និងរៀបចំដែនដីនគររូបនីយកម្មសំណង់ និងភូមិបាលដែលរួមមានការងារ អភិវឌ្ឍស្រុកការងារធនធានធម្មជាតិ ហើយត្រូវបង្ហាញដូចខាងក្រោម៖[60]

### ក. លទ្ធផលការងារនៃការអភិវឌ្ឍស្រុក

លទ្ធផលការងារនៃការអភិវឌ្ឍស្រុក គឺជាកិច្ចការសំខាន់ផងដែរ ហើយការងារទាំងនោះទទួលបានជោគជ័យ និងធ្វើឲ្យកាន់តែមានភាពទាក់ទាញបន្ថែមទៀត ក្នុងនោះរួមមានការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្រុកបាទីទាំងមូលឱ្យមានភាពល្អប្រសើរ មានការរីកចម្រើន និងមានអភិវឌ្ឍន៍ជាច្រើនទៀតដែលមានដូចខាងក្រោម៖

- ជួសជុលដីសប្រវែង ២,៥០០ម៉ែត្រ នៅភូមិក្រាំងធ្នង់អស់ថវិកា ៣.១៧០$ ជាលុយរបស់ចលនាភូមិថ្មី
- ជួសជុលផ្លូវក្រាលថ្មភ្នំ និងប្រឡាយបង្ហូទឹកសងខាងផ្លូវប្រវែង ៨១២ ម៉ែត្រអស់ថវិកា ១១,០០០$ គម្រោងចលនាភូមិថ្មី
- សាងសង់ផ្លូវបេតុងភូមិត្បែងប្រវែង ៣៦៥ម៉ែត្រ អស់ទឹកប្រាក់ ១៤៩,០០០,០០០រៀលមូលនិធិឃុំ

[60] មាននៅទំព័រ ២៦ ដល់ ៣៧ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៨

- ជួសជុលផ្លូវលំដីស ១ខ្សែប្រវែង ៣.៧៥០ម៉ែត្រ នៅភូមិត្រាំសសរ និងភូមិថ្នល់ដាច់ អស់ថវិកាចំនួន ១៤១,១០០,០០០រ
- ស្ពាប្រឡាយប្រវែង ៨០០ម៉ែត្រឆ្លងកាត់ភូមិ កណ្តាល និងភូមិចេកអស់ថវិកា ២៨,០០០,០០០រថវិកាមូលនិធិឃុំ
- បានតបណ្តាញអគ្គីសនីចូលសាលាបឋមសិក្សាត្រគៀត អស់ថវិកា ៤៣៥,០០០រៀល និង ២៤៥ដុល្លារ ឧបត្ថម្ភសាលាដីក្រហម ១០០$ ឧបត្ថម្ភលោក មីញ ចន ដែលមានជំងឺ ចំនួន១៥០$ និង ឧបត្ថម្ភយាយ កាន មានជំងឺ ១០$ ។
- មន្ទីរធនធានទឹកបានស្តារប្រឡាយមេ១ខ្សែប្រវែង៦គីឡូម៉ែត្រ និងស្ពាន៦កន្លែង
- ចូលរួមសម្អាតអនាម័យនៅតាមដងផ្លូវតាមបណ្តោយផ្លូវជាតិលេខ២ ចំនួន ០៣លើក
- ឃុំទទួលបានផ្លូវបេតុងម០១ខ្សែប្រវែង ២,០០០ម៉ែត្រ ដែលជាជំនួយរបស់ ក្រសួងអភិវឌ្ឍន៍ជនបទ ដែលសព្វថ្ងៃកំពុងដំណើការ។
- ដាក់លូរំដោះទឹកបានចំនួន ១១កន្លែងស្មើនឹង០៦ភូមិ
- អង្គការស្ពានកម្ពុជាហូឡង់បានឧបត្ថម្ភ លូចំនួន៧កង់ ស៊ីម៉ង់១០បាវ ឥដ្ឋ១.០០០ដុំ ថ្ម ខ្សាច់ ដើម្បីធ្វើ លូឆ្លង កាត់ប្រឡាយក្នុងភូមិធ្លក ។
- បានជួយជួសជុល ផ្លូវលំ ភូមិ ត្រពាំង យោង ប្រវែង៥០០ម៉ែត្រ និង២៥០ឡាន អស់ទឹកប្រាក់ ៦,២៥០,០០០ រៀល និងបានចាក់ ដីខ្សាច់បន្ថែម ៤៥ឡាន អស់ទឹកប្រាក់ ៤,០០០,០០០រៀល ។
- បានជួសជុលផ្លូវលដីស ភូមិត្រពាំងក្រឡាញ់ប្រវែង១.៦០០ម អស់ថវិកា ២.០០០.០០០រ
- បានជួសជុលផ្លូវ ក្នុងភូមិបចាម បឹងលាច វាលប្រីយ៍ ត្រពាំងត្រយឹង សីហា និងភូមិតានប់ ដែលមានប្រវែង ២,៥០០ម៉ែត្រ អស់ទឹកប្រាក់ ៣,២០០$ ។
- បានជួយជួសជុលស្ពានភូមិថ្មី អស់ទឹកប្រាក់៣៥០,០០០រ
- បានជួសជុលផ្លូវពីរខ្សែនៅភូមិព្រៃខ្លាដើម្បីងាយស្រួលក្នុងការធ្វើដំណើរនៅរដូវវស្សាអស់ទឹកប្រាក់ ១៩,៣០០,០០០រៀល
- អង្គការស៊ីប៊ីអិន(CBN)កម្ពុជាបានឧបត្ថម្ភអណ្តូងទឹក ១៨អណ្តូងក្នុងឃុំ ។
- ជួសជុលផ្លូវលំនៅភូមិសិរីមានជោគ អស់ទឹកប្រាក់១,០៨០,០០០រៀល
- ជួសជុលផ្លូវនៅភូមិព្រៃខ្លា ប្រវែង១,០០០ម៉ែត្រ អស់ទឹកប្រាក់ ៣,០៤០,០០០រៀល
- ជួសជុលផ្លូវលំនៅភូមិត្រពាំងផ្លុង ប្រវែង ២៧៥ម៉ែត្រ អស់ទឹកប្រាក់ ៨០០,០០០រៀល

- ជួសជុលផ្លូវនៅភូមិកញ្ចុំអស់ទឹកប្រាក់ ២,៦០០,០០០រៀល ដោយមានការសហការ ចូលរួមពីប្រជាពលរដ្ឋ និងគ្រឿងចក្រខេត្តឈូសឆាយផ្លូវប្រវែង ២,១០០ម៉ែត្រ
- បានជីកប្រឡាយរំដោះទឹក និងដាក់លូកាត់ផ្លូវ នៅភូមិត្រមូងជ្រំ អស់ទឹកប្រាក់ ១,៦០០,០០០រៀល
- បានសាងសង់ផ្លូវបេតុងនៅភូមិក្រាំងពង្រ ប្រវែង ៣៥២ម៉ែត្រ ជាមូលនិធិឃុំ
- បានជួសជុលផ្លូវលំក្រាលគ្រួសក្រហមប្រវែង ៩០០ម៉ែត្រ អស់ថវិកា ៨,១៧០,០០០៛ និងដាក់លូ ៣កន្លែង អស់ទឹកប្រាក់ ២,១៨១,០០០៛ នៅភូមិសំរោងជ្រៃ ជាថវិការបស់សហគមន៍ភូមិ ។

**ខ. ការរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាល**

ការរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាល បានលទទួលលទ្ធផលដូចខាងក្រោម៖[61]

- បានសហការជាមួយមន្ទីរចុះពិនិត្យសំណង់ ៤លើក
- ចុះបញ្ជីចរន្តការចំនួន១៣១ ក្បាលដី
- ចុះបិទការដ្ឋានសំនង់គ្មានច្បាប់នៅឃុំ កណ្តឹង ១លើក
- បានបំពេញបែបបទផ្ទេរសិទ្ធិ ជូនប្រជាពលរដ្ឋ ។
- បានចុះពិនិត្យតំបន់ផ្សារសំរោងយ៉ោងជាមួយអាជ្ញាធរស្រុក
- បានបន្តចុះបញ្ជីចរន្តការក្នុងសៀវភៅគោលបញ្ជី
- បានចុះណែនាំម្ចាស់សំណង់នៅភូមិផ្សារគុម្ពឫស្សីឲ្យមកធ្វើច្បាប់សាងសង់
- បានចុះវាស់វែងដីទំនាស់ព្រំ នៅភូមិចក និងភូមិពារាម
- បានចុះពិនិត្យសំណង់ចំនួន ០៩ លើក
- ទទួលពាក្យសុំសាងសង់ ០៣ លើក
- ផ្ទេរសិទ្ធិកាន់កាប់ដី៖
  - លក់ផ្តាច់ ចំនួន ១,២៤៥ក្បាលដី
  - លក់បំបែក ចំនួន ៤៦៨ក្បាលដី
  - អំណោយផ្តាច់ ចំនួន ៦៧ ក្បាលដី
  - អំណោយបំបែក ចំនួន ៧៨ក្បាលដី
  - ចុះបញ្ជីបន្ថែម ចំនួន ១០ ក្បាលដី

[61] មាននៅទំព័រ ១៧ នៃរបាយការណ៍ស្តីពី ការអនុវត្តន៏ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៨

## កថាខណ្ឌទី៣៖ លទ្ធផលការងារក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

### ក. ការសម្រេចបានការងារក្នុងវិស័យសេដ្ឋកិច្ច

នៅក្នុងរយៈពេលមួយឆ្នាំនេះការសម្រេចបានការងារខាងវិស័យសេដ្ឋកិច្ច គឺជាវិស័យសំខាន់បំផុត ដែលថ្នាក់ដឹកនាំនិងដៃគូសហការទាំងអស់បានយកចិត្តទុក្ខដាក់លើគ្រប់វិស័យ ។ លទ្ធផលលើវិស័យទាំងនោះមាន ការងារការិយាល័យធនធានទឹក និងការងារការិយាល័យសាធារណៈការ និងដឹកជញ្ជូន ។ ការងារទាំងអស់នឹងអធិប្បាយដូចខាងក្រោម៖

#### ក.១. ការងារការិយាល័យធនធានទឹក

- បានចុះវាស់សំណង់ទ្វាទឹកនៅឃុំក្រាំងធ្នង់ និងឃុំពត់សរ ដែលត្រូវផ្លាស់ប្តូរ។
- ចុះមើលទឹកនៅព្រៃករកា ស្រុកកណ្តាលស្ទឹង ដើម្បីនាំចូលអាងទឹកទន្លេបាទី ។
- ចុះពិនិត្យអាងទឹកទំនប់ថ្នល់ដាច់  កំពង់ដំរី និងពញាពុន
- ចុះសិក្សាប្រឡាយលាវលុង ឃុំពារាម ដែលត្រូវស្តារឆ្នាំ២០១៩
- ចុះពិនិត្យនិងឃាត់  ការចាក់ដីលប់ប្រឡាយ  បាន៣លើក
- ប្រជុំនៅសាលាឃុំព្រៃករកា ស្រុកកណ្តាលស្ទឹង ដើម្បីសុំបើកទ្វារទឹកបញ្ចូលអាងទឹកទន្លេបាទី
- ក្រសួងធនធានទឹកនិងឧតុនិយម បានស្តារប្រឡាយដើមកកោះដែលមានប្រវែង៦,៣០០
- ចុះនាំទឹកពីអាងទន្លេបាទីដើម្បីបើកចូលប្រឡាយហនុមាណ១លើក
- ចុះនាំទឹក ពីអាងកំពង់ទួល មកបញ្ចូលអាងទឹកទន្លេបាទី
- ចុះដាក់ក្តារទ្វាទឹកនៅទំនប់ក្រាំងក្រចាង  ស្វាយខម  ដើម្បីបញ្ចូលទឹកក្នុងទំនប់ ក្រាំងក្រចាង។[62]

#### ក.២. ការងារការិយាល័យសាធារណៈការ និងដឹកជញ្ជូន

- បានចុះមើលផ្លូវ ស្ពាន លូ ផ្លាកសញ្ញាតាមផ្លូវជាតិ ក្នុងស្រុកបាទីចំនួន ១៦លើក
- ចូលរួមក្រុមការងាររបស់មន្ទីរ  ការពង្រីកចិញ្ចើមផ្លូវជាតិលេខ ០២ បាន២លើក
- ទំនាក់ទំនងជាមួយក្រុមហ៊ុនអគ្គសនីក្រុមហ៊ុនខ្សែកាបអុបទិក  ដើម្បីរុះរើបណ្តាញចែកចាយដែលប៉ះពាល់ការងារការពង្រីកចិញ្ចើមផ្លូវ និងបោសព្រៃចំនួន ០១លើក។
- ចុះពិនិត្យរថយន្តកែច្នៃខុសបច្ចេកទេស បាន៥១៣គ្រឿង
- ចូលរួមជាមួយមន្ត្រីមកពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចុះកៀរផ្លូវ១ខ្សែ ចាប់ពីផ្លូវវត្ត អង្គសឹង្ហ ទៅដល់វត្តប្រាសាទមានជ័យ១លើក

[62] មាននៅទំព័រ ២១ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៨

- ចុះកាយដីដើម្បីរំដោះទឹកលើផ្លូវជាតិ PK40+00 ផ្លូវជាតិលេខ២
- បានដឹកនាំគ្រឿងចក្ររៀបចំបរិវេណ វេទិការនៅមជ្ឈមណ្ឌលកីឡាបាល់ទាត់ទន្លេបាទី ។
- បានចុះពិនិត្យសំណង់នៅភូមិរុន ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ ត្រង់ចំណុច PK ៤៧+៥០០ម
- បានចុះពិនិត្យមើលសំណង់ដែក សង់លើដីចំណីស្ពាន អន្លង់តាធន់ នៅភូមិត្រពាំងលាន ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ។[63]

## ខ. ការសម្រេចបានការងារសង្គមកិច្ច និងវប្បធម៌

ក្រោមការប្រឹងប្រែង គ្រប់គ្រងរបស់ថ្នាក់ដឹកនាំគ្រប់ថ្នាក់ទាំងអស់លទ្ធផល សម្រេចបានក្នុងកិច្ចការងារសង្គមកិច្ចនិងវប្បធម៌ក្នុងឆ្នាំ ២០១៨ រួមមាន ការងារការិយាល័យកិច្ចការនារី ការងារការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ ការងារការិយាល័យធម្មការ និងសាសនា ។

### ខ.១. ការងារការិយាល័យកិច្ចការនារី

- បានប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារបាន៨លើក
- បានតាមដានការធ្វើបបរគ្រប់គ្រឿង និងសុខភាពអនាម័យ
- បានចុះពិនិត្យនិងណែនាំការអនុវត្តមុខរបរ ក្រៅកសិកម្ម ១លើក
- ប្រជុំផ្សព្វផ្សាយការរស់នៅស្អាតនិងហូបស្អាតដល់ប្រជាពលរដ្ឋឲ្យចេះដាំបន្លែតាមលក្ខណៈគ្រួសារនៅភូមិពូនភ្នំ ។
- ចូលរួមចុះផ្សព្វផ្សាយជាមួយនគរបាល និងប៉ុស្តិ៍រដ្ឋបាលឃុំស្តីពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន និងច្បាប់អំពើហឹង្សាក្នុងគ្រួសារ នៅភូមិតាំងដូង ។
- មន្ទីរកិច្ចការនារីបានបើកវេទិការផ្សព្វផ្សាយស្តីពីការលើកកំពស់សុខមាលភាពសង្គម នៅឃុំពស់សរ ដែលមានអ្នកចូលរួម ៦៩នាក់ ស្រី ៣៦នាក់។[64]

### ខ.២. ការងាការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ

- ធ្វើអនាម័យសំអាតភ្នំថ្មដុះ ៣លើក និងប្រសាទតាព្រហ្ម ប្រាសាទយាយពៅ ៤លើក
- បានចុះពិនិត្យប្រាសាទតាព្រហ្ម ប្រាសាទយាយពៅនិងពិនិត្យដំណើការ និងការរីកចម្រើនរបស់សហ-គមន៍ទេសចរណ៍ទន្លេបាទី ។

---

[63] មាននៅទំព័រ ២២ និង ២៣ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៨

[64] មាននៅទំព័រ ១២ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៨

- នាយកដ្ឋានគាំពារនិងអភិរក្សប្រាសាទបុរាណ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានចុះមកពិនិត្យស្ថានភាពប្រសាទតាព្រហ្ម ប្រាសាទយាយពៅ រូបចម្លាក់ ដើម្បីលើកគម្រោងជួសជុល និងថែទាំ ។
- បានកែលម្អរដាំសួនច្បារមុខប្រាសាទតាព្រហ្ម
- សហការណ៍ជាមួយការិយាល័យសិល្បៈនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តចុះស្រង់ទិន្នន័យបឋម។[65]

### ខ.៣. ការងារការិយាល័យធម្មការ និងសាសនា

- ចូលរួមកម្មវិធីសង្ក្រាន តាព្រហ្មទន្លេបាទី១លើក
- ចុះពង្រឹងផ្នែកពុទ្ធសាសនា ដើម្បីសន្តិភាព ជាមួយក្រុមការងារថ្នាក់ខេត្ត បាន៤វត្ត
- បានប្រជុំតម្រង់ទិសធម្មកឋិកសម្តែងធម៌ទេសនាទូទាំងខេត្តតាកែវនៅមន្ទីរធម្មការនិងសាសនា។
- ចុះពិនិត្យអង្គការសុវណ្ណភូមិវង្សក្រក្រ៏បូរមី ដែលកសាងសមិទ្ធផលនៅជិតវត្តភ្នំតាម៉ៅ ។
- ចូលរួមពិធីសំណេះសំណាលជាមួយមន្ត្រីសង្ឃនិងគណកម្មការអាចារ្យវត្ត តាមវត្ត១១វត្ត
- ចុះពិនិត្យបញ្ជីវត្តមានសាលាពុទ្ធិកបឋមវត្តសុរភី ឃុំកណ្តឹង មួយលើក
- ចូលរួមដាក់បិណ្ឌជាមួយរដ្ឋបាលស្រុកបានចំនួន ០៣វត្ត
- ចុះមើលការរៀបចំពិធីកាន់បិណ្ឌ និងភ្ជុំបិណ្ឌបានចំនួន១១វត្ត។[66]

## ផ្នែកទី២៖ សមិទ្ធផលសម្រេចបានក្នុងវិស័យសំខាន់ៗក្នុងឆ្នាំ២០១៩

យោងតាមរបាយការណ៍ប្រចាំឆ្នាំ ២០១៩ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលស្រុកបាទី គឺបានបរិយាអំពីសមិទ្ធផលប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាស្រុក ដើម្បីឆ្លើយតបទៅផែនការអភិវឌ្ឍន៍ស្រុក ៥ ឆ្នាំ (២០១៦-២០២០) តាមរយៈការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០១៧-២០១៩) របស់ស្រុកបាទី។ សមិទ្ធផលទាំងនោះមានដូចតទៅ៖

### កថាខណ្ឌទី១៖ លទ្ធផលការងាររដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

### ក.ការងាររដ្ឋបាលដែលសម្រេចបាន

នៅក្នុងសមិទ្ធផលនៃការងាររដ្ឋបាលរបស់ស្រុកបាទីដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន គឺទទួលបាននូវលទ្ធិផលនៅក្នុងចំនុចដែរសំខាន់ៗរួមមាន៖ ការងារផ្តល់អត្រានុកូលដ្ឋាន ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត សកម្មភាពសេវាសង្គម និងការសម្រុះសម្រួលទាំនាស់ ។លទ្ធផលទាំងនេះមានដូចខាងក្រោម៖

#### ក.១ លទ្ធផលការងារអត្រាអនុកូលដ្ឋាន

លទ្ធផលការងារអត្រានុកូលដ្ឋានរួមមាន៖

[65] មាននៅទំព័រ ១៧ និង ១៨ នៃរបាយការណ៍ស្តីពី ការអនុវត្តន៏ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៨

[66] មាននៅទំព័រ ១៦ នៃរបាយការណ៍ស្តីពី ការអនុវត្តន៏ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៨

- សេចក្តីចម្លងសំបុត្រកំណើតចំនួន ១២០៣
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតចំនួន២២៧៦
- សេចក្តីចម្លងសំបុត្រអាពាហ៏ពិពាហ៏ចំនួន ១៧២
- សេចក្តីចម្លងសំបុត្រមរណភាពចំនួន ១០២
- សំបុត្រកំណើតចំនួន ២០៨៧
- សំបុត្រអាពាហ៏ពិពាហ៏ចំនួន ៣១០
- សំបុត្រមរណភាពចំនួន ៤០៥
- សំបុត្របញ្ជាក់កំណើតចំនួន ៣៧។[67]

**ក.២ ការចុះឈ្មោះ ការត្រួតពិនិត្យបញ្ជីឈ្មោះបោះឆ្នោត**

- ប្រជាពលរដ្ឋដែលបានចុះឈ្មោះបោះឆ្នោតថ្មី ចំនួន ( គ្មាន )
- ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ចំនួន ( គ្មាន )
- ប្រជាពលរដ្ឋសរុបដែលមានឈ្មោះបោះឆ្នោត( ចាស់ និងថ្មី) ៩៩,០៣៩។[68]

**ក.៣. សកម្មភាពសេវាសង្គម និងការសម្រុះសម្រួលទំនាស់**

- មត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការដែលគាំទ្រពីឃុំ សង្កាត់ ១៦
- គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់សម្រាប់កែលម្អអនាម័យ(ការលាងដៃនឹងសាប៊ូ) 0
- គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់ ១៣
- គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានបង្គន់អនាម័យប្រើប្រាស់ 0
- គ្រួសារងាយរងគ្រោះដែលឃុំ សង្កាត់ចុះកំណត់អត្តសញ្ញាណ ១៧២៧
- ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែលទទួលការគាំទ្រពីឃុំ សង្កាត់ 0
- ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយឃុំ សង្កាត់ ៤៦២
- ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ ៥១។[69]

---

[67] មាននៅទំព័រ ០២ និង០៦ នៃរបាយការណ៏ស្តីពីការអនុវត្តន៏ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៩

[68] មាននៅទំព័រ ០៦ នៃរបាយការណ៏ស្តីពី ការអនុវត្តន៏ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៩

[69] មាននៅទំព័រ ០៦ នៃរបាយការណ៏ស្តីពី ការអនុវត្តន៏ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៩

**ខ.ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**:

លទ្ធផលការងារ ដែលទទួលបានពីការខិតខំប្រឹងប្រែងបំពេញការងារយ៉ាងយកចិត្តទុកដោយពីថ្នាក់ដឹកនាំរបស់មន្ត្រីការិយាជំនាញយ៉ាងមាន ប្រសិទ្ធភាពការងាររួមសហការជាមួយប្រជាពលរដ្ឋ ផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសណ្តាប់ធ្នាប់សង្គម របស់សាលាស្រុកបាទីបាន ខិតខំបំពេញការងារបង្កាប់បទល្មើសទាំងថ្ងៃទាំងយប់ ហើយក៏ទទួលបានលទ្ធផលដូចខាងក្រោម៖[70]

- ចុះជួយរៀបចំសណ្តាប់ធ្នាប់នៅទីប្រជុំជននិងតាមផ្សារ សម្រួលចរាចរណ៍ ប្រើប្រាស់កម្លាំង ២៦០នាក់ មធ្យោបាយម៉ូតូ១២៥ គ្រឿង រថយន្ត១០គ្រឿង
- ធ្វើការចល័តក្តាប់សភាពការក្នុងភូមិសាស្ត្រ៥០លើក
- ចុះជាជាមួយគណៈបញ្ជាការឯកភាពស្រុកផ្តល់ថវិកា អតីតយុទ្ធជន១២លើក
- ចុះជាមួយគណៈបញ្ជាការឯកភាពបង្ក្រាបទីតាំងផលិតស្ករត្នោតខុសច្បាប់២លើក
- បទល្មើសឃាតកម្ម ០២លើក បទល្មើសរំលោភសេពសន្ធវ ០១លើក ករណីជួញដូរគ្រឿងញៀន ០២លើក អំពើលួច០៩ករណី
- ករណីហឹង្សារដោយចេតនា១លើក ករណីអត្តឃាត១៨លើក
- ករណីខ្សែភ្លើងឆក់០៤លើក
- ករណីមុតម៉ូទ័រ០១លើក
- បទល្មើសព្រហ្មទណ្ឌ លួចមាន់ស្ពានទម្ងន់ ប្លន់(២ករណី)លួច១កណី
    - សកម្មភាពបទល្មើស កើតមាន១៣ករណី
        - ❖ **គ្រោះថ្នាក់ចរាចរណ៍**៖ កើតមាន ១១លើកៈ
            - ស្លាប់ ០៤ នាក់ ស្រី ០នាក់
            - របួស ធ្ងន់ ០៥ នាក់ ស្រី ០២នាក់
            - របួសស្រាល ០១ នាក់ ស្រី ០នាក់
            - រថយន្តខូចខាតធ្ងន់ ០៤ គ្រឿង
            - រថយន្តខូចខាតស្រាល ០២ គ្រឿង
            - ម៉ូតូខូចខាតធ្ងន់ ០២ គ្រឿង

[70] មាននៅទំព័រ ១៦ និង ១៧ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៩

## កថាខណ្ឌទី២៖ លទ្ធផលទទួលបានក្នុងវិស័យអភិវឌ្ឍន៍ជនបទ និងរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាល

សាលាស្រុកបាទី បានសម្រេចសមិទ្ធផលជាច្រើនក្នុងវិស័យអភិវឌ្ឍន៍ជនបទ និងរៀបចំដែនដីនគររូបនីយកម្មសំណង់ និងភូមិបាល រួមមានការងារអភិវឌ្ឍស្រុក ហើយមានវិស័យផ្សេងទៀតមានដូចខាងក្រោម៖[71]

### ក.លទ្ធផលការងារនៃការអភិវឌ្ឍស្រុក

លទ្ធផលដែលសម្រេចបាននៃការងារអភិវឌ្ឍន៏ស្រុក គឺជាភារកិច្ចមួយដែរសំខាន់ផងដែរ ហើយការងារមួយដែរទទួលបានជោគជ័យនិងធ្វើឲ្យស្រុកកាន់តែមានសោភ័ណ្ឌភាពបន្ថែមទៀត រួមបន្ថែមការងារកែលម្អ ហេដ្ឋារចនាសម្ព័ន្ធស្រុក និងជួយចូលរួមសម្អាតបរិស្ថានស្រុកឲ្យបានស្អាតទាំងអស់គ្នាផងដែរ។ ជាក់ស្តែងនៅក្នុងស្រុកបាទីទាំងមូលមានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដូចខាងក្រោម៖

- ជួសជុលផ្លូវក្នុងឃុំមានប្រវែង៣៥៨០ម៉ែត្រនិងដឹកដី ចាក់ចំនួន១៤៩ឡានសរុបទឹកប្រាក់ ៤៤,៦២៥ដុល្លា
- សាងសង់លូរំដោះទឹកនៅភូមិខ្នារមានប្រវែង ៤០ ម៉ែត្រទទឹងលូ0,៤ម៉ែត្រ ថវិកាចលនាភូមិនិងសហគមន៍
- សង់ស្ពានបេតុង១កន្លែងនៅភូមិក្រាំងធ្នង់ ទទឹង៧ម៉ែត្របណ្តោយ១២ម៉ែត្រ និងសង់ស្ពានបង្កាន់ដៃ១កន្លែងប្រវែង២០ម៉ែត្រ ថវិកា១៣៧៥០ដុល្លា ថវិកាសម្តេចសង្ឃ ណយ ច្រឹក និង សហគមន៍
- ដាំកូនឈើនៅស្នាក់ការភូមិ ឃុំនិង ប្រសាទតាព្រហ្ម ឧបត្ថម្ភដោយថ្នាក់ក្រសួងនិងសប្បុរស
- សម្អាតបរិស្ថានតាមផ្លូវជាតិនិងកើបសម្រាមចេញបានចំនួន១២ឡានឧបត្ថម្ភដោយថ្នាក់ស្រុកឃុំ
- ធ្វើផ្លូវចាក់បេតុងអាមេ១ខ្សែប្រវែង ៣០០ម៉ែត្រ ភូមិរូងអស់ទឹកប្រាក់ ១៤១,៨៦១,១៤៧រ។
- អង្គការស្ពានកម្ពុជា ហូឡង់ បានជួយដូចខាងក្រោម៖
- អណ្តូងទឹកលូចំរុះចំនួន៩ អស់ទឹកប្រាក់៣៦០០ដុល្លារ។
- ធុងចំរោះទឹកស្អាតចំនួន ៣០ធុង អស់ទឹកប្រាក់ ៦០០ដុល្លារ។
- ជួយដាក់លូកាត់ផ្លូវចំនួន ៥កន្លែង អស់លូ២៤ កង់ ស៊ីម៉ង់ ថ្ម អិដ្ឋ ខ្សាច់ អស់ទឹកប្រាក់ ២៩០០ដុល្លារ។
- ជួសជុលផ្លូវក្រាលគ្រួសក្រហម១ខ្សែប្រវែង២០០ម៉ែត្រ ស្ថិតនៅភូមិត្រពាំងឫស្សី ទឹកប្រាក់ ១.៣២០.000 (ជាថវិកាសប្បុរសជន)
- ជួសជុលផ្លូវក្រាលថ្មពុកប្រវែង៥៨០ម៉ែត្រ ស្ថិតនៅភូមិសំរោង អស់ថវិកា ៨.៤៥០.000រៀល ជាថវិកាសប្បុរសជន និងសហគមន៍
- ស្តាប្រឡាយរំដោះទឹកស្អុយភូមិត្រាំខ្នារ អស់ថវិកា៥00.000រៀល

[71] មាននៅទំព័រ ១៧ និង ២៦ នៃរបាយការណ៍ស្តីពី ការអនុវត្តន៏ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៩

- មូលនិធិរបស់សាធារណៈរដ្ឋប្រជាមានិត្យបានផ្តល់អណ្តូងស្នប់ ៤ ក្នុងនោះភូមិភ្នំតូច ៣អណ្តូង និងព្រហែក០១
- អង្គការពុទ្ធិបណ្ណាល័យកម្ពុជា បានផ្តល់អាងស្តុកទឹក ដល់សាលាបឋមសិក្សាត្រាំខ្នារ និងវិទ្យាល័យ ត្រាំខ្នារ បឋមសិក្សាភ្នំតូច សរុបថវិកា៧៤០០ដុល្លា ។
- ជួសជុលផ្លូវលំដីស០៤ខ្សែ ប្រវែង២៤១៥ម៉ែត្រ នៅភូមិកណ្តឹងធំ ភូមិកណ្តឹងតូច និងភូមិត្រពាំងលើក ចំណាយថវិកាអស់ ១៤,៧៤០,០០០(ប្រជាជន និងសប្បុរសជន)។
- ជួសជុលផ្លូវលំចំនួន០៦ខ្សែ ប្រវែង៤០០០ម៉ែត្រ ស្ថិតក្នុងភូមិកណ្តឹងតូច ឃុំកណ្តឹង អនុវត្តដោយ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ ។
- ជួសជុលផ្លូវលំក្រួសក្រហម ០១ខ្សែ ប្រវែង១០០ម៉ែត្រ ចំណាយថវិកាអស់ ២,៧៦០,០០០៛ នៅភូមិព្រះម្លប់ បានទទួលការឧបត្ថម្ភពីប្រជាជន និងសប្បុរសជន។
- ជីកអណ្តូងស្នប់បាន៣កន្លែង ក្រោមជំនួយឧបត្ថម្ភរបស់មូលនិធិដើម្បី សន្តិភាពនិងការអភិវឌ្ឍតាមរយៈវេទិការ សម្ព័ន្ធ សង្គមស៊ីវិល អណ្តូងស្នប់(មិត្តភក្តិនៅលើផ្លូវសូត្រ)។
- ដាក់លូកាត់ផ្លូវ០១កន្លែង នៅភូមិព្រះម្លប់ ដោយអង្គការ ស្ពាន កម្ពុជា ហូឡង់។
- ក្រុមប្រឹក្សាឃុំដឹកនាំប្រជាពលរដ្ឋក្នុងភូមិស្តុកប្រិយ៍កាយប្រឡាយសងខាងផ្លូវ២០០ម៉ែត្រ។
- ការដាំកូនឈើក្រញូងនៅភ្នំចំបាប់ចំនួន៤០៣ដើម
- សម្អាតបរិស្ថានតាមដងផ្លូវ១២៣ចំនួន០៣លើកអ្នកចូលរួម២៨៨នាក់
- ជួសជុលផ្លូវលំក្រាល ថ្មពុកប្រវែង៩០០ម៉ែត្រ
- អង្គការស្ពានកម្ពុជាហូឡង់ ឧបត្ថម្ភអង្ករ ដល់កុមារកំព្រា និងអ្នកជម្ងឺអេដស៍ចំនួន២០០គីឡូ និងប្រាក់ចំនួន ៤២០ដុល្លារដាក់លូកាត់ផ្លូវ០២កន្លែងទឹកប្រាក់៣៥០ដុល្លារ។
- សហគមន៍បានស្តាប្រឡាយទឹកប្រវែង៣៨០ម៉ែត្រអស់ទឹកប្រាក់៥.០៦៥.០០០រៀល
- ឃុំបានទទួលការឧបត្ថម្ភកង់ពីអង្គការដៃគូរផ្តល់មេត្តា ចំនួន១៥កង់ សម្រាប់សិស្សឧបត្ថម្ភ កន្លែងលាងដៃសម្អាតសម្រាប់ សិស្សានុសិស្ស ។
- រដ្ឋបាលឃុំបាទទួលអណ្តូងស្នប់បានចំនួន០៩ អណ្តូង ជាអំណោយរបស់មិត្តភក្តិនៅលើផ្លូវសូត្រកម្ពុជាចិន គម្រោងអណ្តូងទឹកស្អាត។
- បានដាំកូនឈើតាមខ្នងប្រឡាយចំនួន ៩០០ដើម ដាំក្នុងវត្តបទុមសុរិយា ចំនួន២០០ដើម វត្តឃ្លាំងមឿង ចំនួន២០០ដើម និងវត្តកោះប៊ុនលី មានចំនួន២០០ដើម សរុបស្មើចំនួន១៥០០ដើម។

- បានកសាងផ្លូវចូលភូមិមួយខ្សែប្រវែង៧០០ម៉ែត្រនៅភូមិរកាពក ៥,០០០,០០០រៀល សប្បុរសជន ។
- បានទទួលអណ្តូងទឹកចំនួន០៦អណ្តូង ដែលជាអំណោយមិត្តភាពកម្ពុជាចិន ។
- ស្រុកបានផ្តល់ផ្លូវបេតុង អន្តរឃុំពារាម ត្នោតប្រវែង៧៥៩ម៉ែត្រ ទទឹង០៤ម៉ែត្រ ។
- បានចុះណែនាំពីអនាម័យបរិស្ថានដល់ ម្ចាស់កសិដ្ឋានចិញ្ចឹម មាន់ចំនួន ២ កន្លែង ។
- បានទទួលអណ្តូងស្នប់ចំនួន ៥ ពីសមាគមន៍ចិន
- ចាក់ថ្មភ្នំក្រាលផ្លូវក្នុងភូមិខ្នារទង់២ខ្សែ ប្រវែង១,៤៣០ម អស់ថវិកា២,៣៤០,០០០រៀល ៥០ដុល្លា
- ឈូសឆាយផ្លូវលំប្រវែង២,២៨០ម កាត់ភូមិថ្មី ត្រពាំងផ្លុង ព្រៃខ្លា និង សិរីមានជោគ អស់ប្រាក់ ១,២០០,០០០រៀល
- នៅភូមិត្រពាំងផ្លុងបានរបងព័ទ្ធជុំវិញស្រះទឹកប្រវែង២២០ម និងធ្វើជណ្តើរចុះទៅស្រះប្រវែង៧ម ព្រមទាំងដាក់លូបង្ហូទឹកបាន១៨កង់
- ស្ពាននៅភូមិកញ្ចុំបានសាងសង់រួចរាល់ជាស្ថាពរដោយទទួលបានការឧបត្ថម្ភពីអង្គការស្ពានកម្ពុជាហូឡង់ និងការចូលរួមពីប្រជាពលរដ្ឋ។

## ខ. ការរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាល

- បានចុះពិនិត្យសំណង់ ៣៤លើក
- ប្រជុំរៀបចំឯកសាររចនាសម្ព័ន្ធថ្នាក់ស្រុក
- ចុះវាស់ដីចំណីផ្លូវជាមួយអាជ្ញាធរស្រុក
- ទទួលពាក្យសាងសង់ផ្លូវ១៦លើក
- ចុះវាស់វែងដីប្រជាពលរដ្ឋតាមការស្នើសុំ
- បានបំពេញបែបផ្ទេរសិទ្ធជូនប្រជាពលរដ្ឋ
- ផ្ទេរសិទ្ធិកាន់កាប់ដី
    - លក់ផ្តាច់ ចំនួន ៤,៨២៥ លើក
    - លក់បំបែក ចំនួន ២,០១៤ លើក
    - អំណោយផ្តាច់ ចំនួន ៣១១ លើក
    - អំណោយបំបែក ចំនួន ២៧៣ លើក

- ចុះបញ្ជីបន្ថែម ចំនួន ១០ ក្បាលដី។[72]

**កថាខណ្ឌទី៣៖ លទ្ធផលការងារក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

**ក.ការងារសម្រេចបានក្នុងវិស័យសេដ្ឋកិច្ច**

ការងារដែលសម្រេចបាននៅក្នុងវិស័យសេដ្ឋកិច្ចនេះ គឺវាពិតជាមានសារៈសំខាន់បំផុតដែលពុំអាចខានបាន ដែលមន្រ្តីថ្នាក់ដឹកនាំ ត្រូវមានការយកចិត្តទុកដាក់អោយបានខ្ពស់បំផុតដើម្បីអោយមានចម្រើនកាន់តែទៅមុនបន្ថែមទៀត ។ លទ្ធផលនៃវិស័យនេះមានដូចជា ការងារកសិកម្ម ការងារធនធានទឹក និងឧតុនិយម និងការងារសាធារណៈការ និងដឹកជញ្ជូន ។ ការងារនេះត្រូវបានអនុវត្តដូចខាងក្រោម៖

**ក. ១ ការិយាល័យធនធានទឹក និងឧតុនិយម**

- ក្រសួងបាន ស្តារ ប្រឡាយ មេ ដើម កកោះ ឃុំត្នោត ៣រាម ដូងមានប្រវែង ៦០០០ម៉ែត្រ មានសំណង់ទ្វាទឹកចំនួន ៦ សំណង់ស្ទះទឹកតូច ២១កន្លែង ខ្នងប្រឡាយក្រាលគ្រួសក្រហម សម្រេចបាន១០០% ។
- មន្ទីរធនធានទឹក បានជួសជុល ទំនប់ទឹកក្រាំងក្រចាង មានប្រវែង ៣៨០ម៉ែត្រ ក្រាលគ្រួសក្រហម និងជួសជុលទ្វាទឹកខូច ។
- ក្រសួងធនធានទឹក និងឧត្តុនិយម បានផ្តល់ប្រេងម៉ាស៊ូតសម្រាប់អន្តរាគមន៍បូមទឹកសង្គ្រោះដំណាំស្រូវវស្សានៅស្ថានីយ៍ ទី២២ ,២៣៧,៨ ។
- ក្រសួងធនធានទឹក និងឧត្តុនិយម បានជួសជុលខ្នងប្រឡាយស្ថានីយ៍ទី៨ ប្រវែង១០០ម៉ែត្រ ជួសជុលទំនប់ទឹកស្វាយខម ប្រវែង ៤៥០០ម៉ែត្រ និងទ្វាទឹក៣កន្លែងទៀត ។
- មន្ទីរបានសហការជាមួយអង្គកា កាវ៉ាក់ ធ្វើប្រឡាយរង បេតុងនៅភូមិថ្មី ឃុំត្នោត និងភូមិប្រមូលសុខ នៅឃុំដូងសរុបប្រវែង ១៣០០ ម៉ែត្រ ។
- មន្ទីរបានផ្តល់ប្រេង ម៉ាស៊ូត អន្តរគមន៍បូមទឹកនៅ ស្ថានីយ៍២២ ,២៣និងទី៨
- ការិយាល័យធនធានទឹកបានចាក់ដី៤ឡាន ស្តារប្រលាយនៅឃុំ៣រាម។[73]

**ក.២ ការិយាល័យសាធារណៈការ និងដឹកជញ្ជូន**

- បានចុះមើលផ្លូវ ស្ពាន លូ ផ្លាកសញ្ញាតាមផ្លូវជាតិ ក្នុងស្រុកបាទីចំនួន ៣២លើក
- បានចុះមើលផ្លូវ ស្ពាន លូ ផ្លាកសញ្ញាតាមផ្លូវជាតិលេខ២ តាមដងផ្លូវ ខេត្តចំនួន ៣៧ លើក

[72] មាននៅទំព័រ ១២ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៩

[73] មាននៅទំព័រ ១៤ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៩

- ចុះវាស់ វែង និងជូនដំណឹងដល់ប្រជាពលរដ្ឋមិនអោយឃឹតយ៉ាវ ឬសាងសង់សំណង់មកប៉ះពាល់លើដីចំណីផ្លូវ មកប៉ះពាល់លើដំណើរផ្លូវជាតិ និងខេត្តចំនួន៩លើក ។
- បានចូលរួមសហការណ៍ជាមួយ មូលដ្ឋាននិងលោកអភិបាលស្រុកកបាទី ចុះរៀបចំសណ្តាប់ធ្នាប់នៅផ្សារ សំរោង យោងមួយលើក ។
- ចុះស្រង់ស្ថិតិយានដ្ឋានជួសជុលរថយន្តក្នុងស្រុកបានចំនួន៧លើក
- ចុះពន្យល់និងណែនាំដល់ម្ចាស់យានដ្ឋាន ជួសជុលនិងកែច្នៃរថយន្តចង្កូតស្តាំ ខុសលក្ខណៈបច្ចេកទេសក្នុង ស្រុកបានចំនួន៤លើក
- ចូលរួមប្រជុំនៅសាលាស្រុកបាន ៣៣ លើក
- ចុះផ្សព្វផ្សាយការងារ ការិយាល័យច្រកចេញចូលតែមួយបានចំនួន ៣ ឃុំ។[74]

## ខ. ការងារសម្រេចបានក្នុងវិស័យសង្គមកិច្ច

ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ បានធ្វើការខិតខំប្រឹងប្រែង មិននឿយណាយក្នុងការបំពេញតួនាទី និងភារៈកិច្ច ដើម្បីសម្រេចបាននូវលទ្ធផលក្នុងការងារសង្គមកិច្ច និងវប្បធម៌ តាមរយៈឆ្នាំនេះផងដែរ(២០១៩) រួមមាន ការងារ កិច្ចការនារី ការងារវប្បធម៌ និងវិចិត្រសិល្បះ ។

### ខ.១ ការងារការិយាល័យកិច្ចការនារី

- គ.ក.ស.ក និងការិយាល័យកិច្ចកានារីស្រុក បានចុះតាមឃុំ ក្នុងកម្មវិធីពិសារនំបញ្ចុក សម្តេច តេជោ សាមគ្គី សន្តិភាព និងឯករាជ្យជាតិ ។
- បានចូលរួមផ្សព្វផ្សាយច្បាប់អំពើហឹង្សារក្នុងគ្រួសារដល់ប្រជាពលរដ្ឋបាន ០២លើក
- បានចូលរួមពិធីអកអំបុកដើម្បីការពារ ជាតិ សាសនា ព្រះមហាក្សត្រ ១លើក
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី សិទ្ធិកុមារ និងការការពារកុមារ ជាមួយអង្គការអាយស៊ីស៊ី នៅ ការិយាល័យអប់រំ ចំនួន២ថ្ងៃ។
- មន្ទីរកិច្ចការនារីខេត្ត និងការិយាល័កិច្ចការនារីស្រុក បានចូលរួមប្រជុំជាមួយក្រុមមុខរបរក្រៅកសិកម្មធ្វើ អំបោស នៅភូមិពានមាសកើត ឃុំលំពង់ដែលមានអ្នកចូលរួម ៤៧នាក់ស្រី ៣៨នាក់។
- ចូលរួមផ្សព្វផ្សាយទប់ស្កាត់គ្រឿងញៀននិងអំពើហឹង្សាក្នុងគ្រួសារ
- ចូលរួមប្រជុំប្រចាំខែនិងកិច្ចប្រជុំនានាជាមួយអង្គការដៃរគូរផ្តល់មេត្តា ។

[74] មាននៅទំព័រ ១៥ នៃរបាយការណ៍ស្តីពី ការអនុវត្តន៏ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៩

- មន្ទីរកិច្ចការនារី បានសហការជាមួយការិយាល័យអប់រំយុវជននិងកីឡានឹងការិយាល័យកិច្ចការនារីស្រុក បានបើកវេទិការផ្សព្វផ្សាយស្តីពីការលើកកម្ពស់ សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរដែលធ្វើនៅ វិទ្យាល័យសុខអានត្រាំខ្នារដែលមានអ្នកចូលរួម ៥០០នាក់។[75]

### ខ.២ ការងារអប់រំយុវជននិងកីឡា

- ចូលរួមប្រជុំប្រចាំខែ កិច្ចការនារីនៅសាលាស្រុក
- ចុះត្រួតពិនិត្យនិងសាលាក្នុងកម្រង ចាន់សារុន សម្តេចពិញ្ញាណ
- ធ្វើបញ្ជីរាយនាមគ្រូបង្រៀនសម្រាប់ថ្ងៃព្រហស្បតិ៍ប្រមូលរបាយការណ៍ថ្នាំព្រូន ស្ថិតិសិស្សពិការ កន្លែងកាងសំអាតដៃ និងអណ្តូងទឹកស្អាត មើលបរិស្ថាននៅមធ្យមសិក្សាទាំង១៥។[76]

### ខ.៣ ការងារការិយាល័យធម្មការនិងសាសនា

- ប្រជុំថ្នាក់ខេត្តបាន ៣៣ លើក និងជាមួយមន្ត្រីសង្ឃ ៩ លើក
- ប្រឡងវិញ្ញាបនប័ត្រ ធម្មវិន័យ និងប្រលងរង លើក
- ដោះស្រាយអធិករណ៍ ១១ លើក និងជាមួយពាហិរៈសាសនា ២ លើកចូលរួមគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនៈកោដិ គម្រប់ខួប ៧ ឆ្នាំ ១ លើក
- ប្រមូល និងពិនិត្យពាក្យ និងដាក់ពាក្យសាមណៈសិស្សប្រឡងធម្មវិន័យ (ត្រីទោឯក) និងប្រឡងពុទ្ធិកៈបឋមចំនួន ១៤២ អង្គ ។
- ចុះតាមវត្តអារាមពេលដាក់បិណ្ឌបានចំនួន ១៨ វត្ត
- ទទួលត្រៃ និងថវិកាពីឯកឧត្តម កិតិនិត្តិកោសល្យបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកស្តីទីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារចុះមូលដ្ឋានខេត្ត តាកែវ ចំនួន ៨ ត្រៃធំ និងថវិកា ៨ លានរៀល។[77]

### ខ.៤ ការងារ ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ

- ចូលរួមកិច្ចប្រជុំ នានាថ្នាក់ស្រុក២១លើក
- ចូលរួមកិច្ចប្រជុំនៅមន្ទីរវប្បធម៌ខេត្តចំនួន៨លើក
- ទទួលសិស្សសាលាហារ៉េត ចំនួន១០០នាក់ មកធ្វើទស្សនៈកិច្ចសិក្សា នៅប្រាសាទតាព្រហ្មទន្លេបាទី និង ប្រាសាទយាយពៅ ១ថ្ងៃ

---

[75] មាននៅទំព័រ ១០ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៩

[76] មាននៅទំព័រ ១១ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៩

[77] មាននៅទំព័រ ១១ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៩

- មន្ត្រីការិយាល័យចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេសនៃការផ្តល់សេវា តាមវិស័យមួយដែលបានធ្វើប្រតិភូកម្ម ច្រកចេញចូលតែមួយ នៅខេត្តតាកែវ
- ដាក់ស្លាកហាមចាក់សម្រាម នៅតាមផ្លូវខាងលិចប្រាសាទអស់ថវិកា ១២០.០០០រៀល
- នាយកដ្ឋានគាំពារនិងអភិរក្សសំណង់បុរាណនៃក្រសួង វប្បធម៌និងវិចិត្រសិល្បៈបានសហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈស្រុករដ្ឋបាលស្រុកបាទីធ្វើការ ជួសជុលប្រាសាទ តាព្រហ្ម ដំណាក់កាលទី២ ដាក់ទម្រដែកនិងឈើ តាមច្រកប្រាសាទចំនួន០៧កន្លែង ។
- សហការណ៍ជាមួយ រដ្ឋបាលស្រុក ការិយាល័យបេតិកភ័ណ្ឌរបស់មន្ទីរ វប្បធម៌ និងវិចិត្រសិល្បៈខេត្ត ចុះទប់ស្កាត់ការកសាងសាលាបុណ្យ នៅភូមិទួលអង្គតាឯក ស្ថិតនៅភូមិតាំងឬស្សី ឃុំពត់សរ ១លើក។[78]

[78] មាននៅទំព័រ ១២ នៃរបាយការណ៍ស្តីពី ការអនុវត្តន៍ការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៩

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីការបកស្រាយរបស់យើងខ្ញុំទាក់ទងនឹងប្រធានបទស្តីពី **រដ្ឋបាលស្រុកបាទី និងសមិទ្ធផលដែលទទួលបានពីឆ្នាំ ២០១៧ ដល់ ២០១៩** រួចមកយើងសបញ្ជាក់ឲ្យឃើញថា ការអភិវឌ្ឍន៍ ភូមិ ឃុំ និងការកែទម្រង់រដ្ឋបាលទូទាំងស្រុកបាទី គឺមានការរីកចម្រើនដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលមានបំណងអភិវឌ្ឍស្ថានភាព ហេដ្ឋារចនាសម្ព័ន្ធអនុវត្តតាមគោលនយោបាយដែលបានដាក់ចេញ។ តាមរយៈគោលនយោបាយនេះរាជរដ្ឋាភិបាលបានរៀបចំបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក ព្រមទាំងស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នេះឡើងដើម្បីធ្វើឲ្យការអភិវឌ្ឍក៏ដូចជា ទម្រង់រដ្ឋបាលបានសម្រេចបានជោគជ័យស្របតាម យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ការគ្រប់គ្រងដឹកនាំ យ៉ាងយកចិត្តទុកដាក់ របស់រដ្ឋបាលស្រុកបាទី អនុវត្តតាមបទប្បញ្ញត្តិច្បាប់លិខិតបទដ្ឋានគតិយុទ្ធនានាមានការកែតម្រូវបានយ៉ាងល្អប្រាកដនិងច្បាស់លាស់។ តាមការកំណែទម្រង់រដ្ឋបាល ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក និងមានការសហការគ្នាបានល្អទៅតាមតួនាទីមុខងាររៀងៗខ្លួនហើយយ៉ាងណាឲ្យទទួលបាននូវប្រសិទ្ធភាពខ្ពស់ ដោយមានការដឹកនាំរបស់ គណៈអភិបាលដាក់ភារកិច្ចបន្តឲ្យទៅបុគ្គលិកក្រោមឱវាទ ដើម្បីអនុវត្តតាមគោលដៅ ដែលស្ថិតនៅដែនសមត្ថកិច្ចរបស់ខ្លួនក្នុងការត្រួតពិនិត្យ និងដឹកនាំអនុវត្តផែនការយុទ្ធសាស្ត្រ ។ ដូច្នេះហើយទើបការគ្រប់គ្រងរបស់រដ្ឋបាលស្រុកបាទីមានភាពប្រសើរល្អឡើង ព្រោះដោយមានការដឹកនាំល្អពីថ្នាក់ដឹកនាំ និងមានការសហការខ្ពស់ពីមន្ត្រីជំនាញ ធ្វើឲ្យបង្កើនការលូតលាស់ជាលំដាប់ដោយមន្ត្រីក្រោមឱវាទគ្រប់ជាន់ថ្នាក់ គោរពតួនាទី ភារកិច្ចរបស់ខ្លួនបានយ៉ាងខ្ជាប់ខ្ជួនគ្រប់ៗគ្នាផងដែរ ។

តាមរយៈការគ្រប់គ្រងខាងលើយើងសង្កេតឃើញថា មានសមិទ្ធផលជា ច្រើនដែលមានការរីកលូតលាស់គួរឲ្យកត់សម្គាល់ដោយដាក់ចេញនូវគោលនយោបាយល្អៗសម្រាប់ការអភិវឌ្ឍស្រុកបាទី ក៏ដូចមន្ត្រីគ្រប់ជាន់ថ្នាក់នៅក្នុងស្រុកបាទី ជាពិសេស គណៈអភិបាល ក្រុមប្រឹក្សា ព្រមទាំងមានការសហការពីប្រជាពលរដ្ឋនៅតាមមូលដ្ឋានជាច្រើនឆ្នាំ គឺកំណត់សម្គាល់ក្នុងឆ្នាំ ២០១៧ ដល់ ២០១៩ ។ ក្នុងឆ្នាំនោះដែរស្រុកបាទីបានសម្គាល់ឃើញថាការងាររដ្ឋបាលមានភាពល្អប្រសើរ ដោយមានការទទួលបានពីយន្តការច្រកចេញចូលតែមួយមានភាពងាយស្រួលនិងសេវាសាធារណៈជូនប្រជាពលរដ្ឋបានល្អ ។ ចំពោះសន្តិសុខសាធារណៈមានភាពជាដៃគូរសហការបានល្អដើម្បីអនុវត្តភារកិច្ចតាម ភូមិ ឃុំ បានយ៉ាងល្អ ។ ម៉្យាងវិញទៀត គណៈអភិបាល និងមន្ត្រីផ្សេងទៀត បានចុះជួយដល់ប្រជាពលរដ្ឋដូចជា៖ ផ្តល់អំណោយដល់គ្រួសារក្រីក្រ ស្ត្រីមេម៉ាយ កុមារកំព្រា ជាមួយនឹងថវិកា ទៅតាមភូមិឃុំនីមួយៗ បន្ទាប់ពីនោះមានការ កៀរផ្លូវ កាប់ឆ្ការព្រៃតាមដងផ្លូវ ដាក់លូ ជីកអណ្តូង ស្រះ កសាងផ្លូវគ្រួស កៅស៊ូបេតុង ផ្លូវលំ ស្ពាន -ល- ។

ហេតុនេះហើយទោះបីជាការអនុវត្តខាងលើរៀបចំបានល្អក៏ដោយចុះ ក៏ប្រទេសកម្ពុជាស្ថិតក្នុងប្រទេសកំពុងអភិវឌ្ឍស្ថានភាពសេដ្ឋកិច្ចនូវមានកម្រិតនៅឡើយ ប៉ុន្តែទោះជាយ៉ាងណាថ្នាក់ដឹកនាំ នឹងខិតខំប្រឹងប្រែងតស៊ូដើម្បីឲ្យប្រទេសជាតិមានការអភិវឌ្ឍខ្លាំងដូចគ្នាប្រទេសដទៃទៀត គឺមានន័យថា ៖ ចំណូលតិចតម្រូវការច្រើនធ្វើឲ្យខ្វះថវិកា ដើម្បីអភិវឌ្ឍ មន្ត្រីរដ្ឋបាលមួយចំនួននៅប្រកាន់បក្សពួកគិតប្រយោជន៍ជាធំ គិតតែអំណាច បុណ្យសក្តិកម្រិតជីវភាពទន់ខ្សោយចំណូលទាប ឧបត្ថម្ភពីបរទេសច្រើន កម្ចីបរទេស ។

ដូចច្នេះរដ្ឋបាលល្អ ត្រូវមានទំនួលខុសត្រូវខ្ពស់ ព្យាយាមយ៉ាងមុតមាំក្នុងការដឹកនាំការងារ គិតពីប្រយោជន៍ប្រជាពលរដ្ឋជាធំមានគោលដៅច្បាស់លាស់ក្នុងការអនុវត្តការងារ និងមានគំនិតច្នៃប្រឌិត ដើម្បីវិវត្តន៍ខ្លួនឲ្យល្អប្រសើរ ព្រមទាំងកាន់ខ្ជាប់ដោយនីតិរដ្ឋ ។ យ៉ាងណាមិញ ក្នុងនាមយើងជាប្រជាពលរដ្ឋត្រូវចេះសហការគ្នាដើម្បីអភិវឌ្ឍប្រទេស ចូលរួមគោរពច្បាប់ឲ្យបានល្អ ហើយយើងខ្ញុំសង្ឃឹមថា ការរួមចំណែកមួយនេះនឹងទទួលបានលទ្ធផលល្អនៅថ្ងៃខាងមុខ និងជួយកសាងប្រទេសជាតិឲ្យឈានទៅរកភាពរីកចម្រើនលូតលាស់ រុងរឿង មានឈ្មោះល្បាញល្បីនៅលើសកលលោក ដូចសម័យមហានគរ ។

# អនុសាសន៍

បន្ទាប់ពីការបកស្រាយកិច្ចការស្រាវជ្រាវ និងសន្និដ្ឋានរួចមក យើងខ្ញុំសូមចូលរួមចំណែកជាគំនិតដើម្បីចែករំលែកជួយកសាងសង្គមជាតិ ចូលរួមស្ថាប័នាកែលម្អជាមួយថ្នាក់ដឹកនាំអាជ្ញាធរសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ទាំងអស់ក្នុងព្រះជាណាចក្រកម្ពុជា ការជួយថែរក្សា អភិរក្សដែនដីមាតុប្រទេស ជាពិសេសវិស័យរដ្ឋបាលសាធារណៈព្រោះផ្នែករដ្ឋបាល គឺជាស្នូលដ៏សំខាន់សម្រាប់ប្រទេសទាំងមូល បើសិនជាផ្នែករដ្ឋបាលមានភាពរីកចម្រើននោះប្រទេសជាតិក៏មានការីកចម្រើន ។ ដូចនេះហើយក្នុងនាមយើងខ្ញុំសូមផ្តល់អនុសាសន៍ខ្លះៗដើម្បីកសាងប្រទេសមួយចំនួនដូចជា៖

- សំណូមពរដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងស្រុកបាទីជួយដាក់កម្លាំងប្រជាការពារភូមិឲ្យបានខ្ជាប់ខ្ជួន ដើម្បីឲ្យផ្តល់នៅសន្តិសុខសុវត្ថិភាពដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។
- សំណូមពរដល់អាជ្ញាធរមានសម្ថតកិច្ចពង្រឹង និងអនុវត្តគោលការណ៍ដែលរាជរដ្ឋាភិបាលដាក់ចេញមកឲ្យបានច្បាស់លាស់
- សំណូមពរដល់មន្ត្រីគ្រប់ជាន់ថ្នាក់ត្រូវទំនួលខុសត្រូវចំពោះការងារ គោរពពេលវេលា ក្រមសីលធម៌ល្អ និងមានតម្លាភាព
- សំណូមពរដល់ អាជ្ញាធរមូលដ្ឋានក្នុងស្រុកបាទី ធ្វើការផ្សព្វផ្សាយអំពីច្បាប់ចរាណ៍ក៏ដូចជាច្បាប់របស់ប្រទេសជាតិដល់ប្រជាពលរដ្ឋឲ្យគាត់យល់ដឹងកាន់តែច្បាស់បន្ថែម ។
- សំណូមពរដល់អាជ្ញាធរមូលដ្ឋានក្នុងស្រុកបាទី និងបង្កើតតុលាការរដ្ឋបាល ដើម្បីដោះស្រាយសំណុំរឿងវិវាទរដ្ឋបាល ។
- សំណូមពរដល់អាជ្ញាធរមូលដ្ឋានក្នុងស្រុកបាទី បង្កើនការយល់ដឹងជុំវិញបញ្ហាទាក់ទងទៅនឹងអនាម័យនៅក្នុងមូលដ្ឋាន ក៏ដូចជាអនាម័យតាមផ្លូវសាធារណៈ ។
- សំណូមពរឲ្យរាជរដ្ឋាភិបាល និងគ្រប់ក្រសួង ស្ថាប័នទាំងអស់ប្រកាន់ខ្ជាប់នូវ នីតិរដ្ឋ ។

# ឯកសារយោង

## ១. ឯកសារជាលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨
- អនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- អនុក្រឹត្យលេខ ២១៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក
- អនុក្រឹត្យលេខ ៧៤៨ អនក្រ តត.ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៩ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកបាទី នៃខេត្តតាកែវ
- អនុក្រឹត្យលេខ ១៥១ អនក្រ.តត ចុះថ្ងៃទី១៩ ខែ មិថុនា ២០១៨ ស្តីពី ការផ្ទេរភារកិច្ច និងការតែងតាំងមន្ត្រីរាជការ
- ប្រកាសលេខ ៣៧៨៦ ប្រក របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការតែងតាំងមន្ត្រីរាជការ
- ប្រកាសលេខ ៤៦៩៧ ប្រក ក្រសួងមហាផ្ទៃ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ២០១៧ ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រី រាជការ
- ប្រកាសអន្តរក្រសួងលេខ ៣២៤សហរ.ប្រក រវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋាភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- ប្រកាសលេខ ៤២៧៥.ប្រក ក្រសួងមហាផ្ទៃ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅក្នុងក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

- ប្រកាសលេខ ៩២៨ ប្រក ក្រសួងមហាផ្ទៃ ចុះថ្ងៃទី ១២ ខែមិនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយ នៅ ក្រុង ស្រុក ខណ្ឌ គោលដៅ
- សេចក្តីសម្រេចលេខ០៦ ស.ស.រ របស់ប្រធានក្រុមប្រឹក្សាស្រុក ចុះថ្ងៃទី២៧ ខែ សីហា ឆ្នាំ ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការលទ្ធកម្មស្រុកបាទី
- សេចក្តីសម្រេចលេខ ០៧ ស.ស.រ របស់ប្រធានក្រុមប្រឹក្សាស្រុក ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៩ ស្តីពីការទទួលស្គាល់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សា ស្រុកបាទី
- សេចក្តីសម្រេចលេខ ០៨ស.ស.រ របស់ប្រធានក្រុមប្រឹក្សាស្រុក ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រីនិងកុមារស្រុកបាទី ខេត្ត តាកែវ

## ២. ឯកសារជាសៀវភៅ

- សៀវភៅណែនាំស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលស្រុក
- សៀវភៅ នីតិរដ្ឋបាលទូទៅរបស់សាស្ត្រាចារ្យ **ហៀង សាង** បោះពុម្ពលើកទី៥ ឆ្នាំ ២០១៩
- សៀវភៅនីតិរដ្ឋបាលរបស់ សាស្ត្រចារ្យ **យូ តូនី** បោះពុម្ពឆ្នាំ ២០១៩
- សៀវភៅនីតិរដ្ឋបាលទូទៅរបស់សាស្ត្រចារ្យ **ឌឿក ពិដោរ** បោះពុម្ពលើកទី២(មិនបានបញ្ជាក់ឆ្នាំ)
- សៀវភៅរដ្ឋបាលសាធារណៈទំនើប **កៅ មុយថង** ឆ្នាំ ២០០៧

## ៣. របាយការណ៍

- របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៧
- របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៨
- របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៩

# បញ្ជីឧបសម្ព័ន្ធ


| ល.រ | ឈ្មោះឯកសារ | ទំព័រ |
|---|---|---|
| ១. | អនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក | ១ |
| ២. | ប្រកាសអន្តរក្រសួង លេខ ៣២៤សហវ.ប្រករវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្ដីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋាភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ | ៧៣ |
| ៣. | អនុក្រឹត្យលេខ ១៥១ អនក្រ.តត ចុះថ្ងៃទី១៩ ខែ មិថុនា ២០១៨ ស្ដីពី ការផ្ទេរភារកិច្ច និងការតែងតាំងមន្ត្រីរាជការ | ៨៣ |
| ៤. | អនុក្រឹត្យលេខ ៧៤៨ អនក្រ តត.ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៩ ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកបាទី នៃខេត្តតាកែវ | ៨៥ |
| ៥. | សេចក្តីសម្រេចលេខ១១២ សសរ របស់ប្រធាន គ.ជ.អ.ប ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ស្ដីពីការផ្ទេរសមាហរណកម្មបុគ្គលិក និងរៀបចំមុខដំណែងគ្រប់គ្រងនៅក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលស្រុកបាទីនៃខេត្តតាកែវ | ៨៨ |
| ៦. | សេចក្តីសម្រេចលេខ ០៦ ស.ស.រ របស់ប្រធានក្រុមប្រឹក្សាស្រុក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០១៩ ស្ដីពីការបង្កើតគណៈកម្មាធិការលទ្ធកម្មស្រុកបាទី | ៩៣ |
| ៧. | សេចក្តីសម្រេចលេខ ០៧ ស.ស.រ របស់ប្រធានក្រុមប្រឹក្សាស្រុក ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៩ ស្ដីពីការទទួលស្គាល់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សា ស្រុកបាទី | ៩៦ |
| ៨ | សេចក្តីសម្រេចលេខ ០៨ស.ស.រ របស់ប្រធានក្រុមប្រឹក្សាស្រុក ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៩ ស្ដីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារស្រុកបាទី ខេត្ត តាកែវ | ៩៩ |

| | | |
|---|---|---|
| ៩ | ផែនទីរដ្ឋបាលស្រុកបាទី | ១០៣ |
| ១០ | រចនាសម្ព័ន្ធនៃរដ្ឋបាលស្រុកបាទី | ១០៤ |
| ១១ | កម្រងរូបភាពសមិទ្ធផលស្រុកបាទី | ១០៥ |
| ១២ | របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៧ | ១០៨ |
| ១៣ | របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៨ | ១៣៤ |
| ១៤ | របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររដ្ឋបាលស្រុកបាទី ឆ្នាំ ២០១៩ | ១៦១ |